# ទស្សនាវដ្ដី កសិកម្ម

# THE AGRICULTURE MAGAZINE




ឆ្នាំទី ២០ ត្រីមាសទី ៣ (កក្កដា-កញ្ញា) ឆ្នាំ ២០២១ លេខ ៧៩

អាសយដ្ឋានលេខ:២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (០២៣) ២១១ ៣៥១/ទូរសារលេខ : (៨៥៥)២៣ ២១៧ ៣២០
គេហទំព័រ : http://www.maff.gov.kh
e-mail : info@maff.gov.kh

# មាតិកា ទំព័រ


- ព្រះរាជសារ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តមសីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ផ្ញើជូន ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ........ ០១
- អបអរសាទរ "ទិវាមច្ឆជាតិ ១ កក្កដា ឆ្នាំ២០២១"........ ០២
- អបអរសាទរ "រុក្ខទិវា ៩ កក្កដា ឆ្នាំ២០២១"........ ០៤
- ជំនួយស្មារតីឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមហ៊ុន Lexmin Pty Ltd Cambodia........ ០៦
- ចំណាប់អារម្មណ៍ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្លែងក្នុងពិធីចុះអនុស្សរណៈយោគយល់ រវាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជានិង អគ្គលេខាធិការដ្ឋាន នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម........ ១១
- ឧបករណ៍នេសាទទឹកសាប នៃព្រះរាជាណាចក្រកម្ពុជា........ ១៤
- ការកែច្នៃដើមឫស្សីនៅខេត្តមណ្ឌលគិរី........ ២៤
- ចំណេះដឹងស្តីអំពីសុខភាពសត្វ(បន្តពីទស្សនាវដ្តីកសិកម្ម លេខ៧៨)........ ៣០
- ការធ្វើឱ្យប្រសើរឡើងនូវបច្ចេកវិទ្យាចិញ្ចឹមដង្កូវនាង និងការផលិតសូត្រចេញពីដង្កូវនាងកូនកាត់ពូជ $Ck_1$-7-4........ ៣៧
- របាយការណ៍ស្តីពីសភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំឆមាសឆ្នាំ២០២១ និងទិសដៅអនុវត្តបន្ត........ ៤៤
- សកម្មភាពថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ........ ៦១






សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតា
នរោត្តម មុនិនាថ សីហនុ
នៃព្រះរាជាណាចក្រកម្ពុជា

ជូន ឯកឧត្តម វេង សាខុន
រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឯកឧត្តម

ខ្ញុំ សូមអរគុណដ៏ជ្រាលជ្រៅ ចំពោះលិខិតថ្វាយព្រះពររបស់ឯកឧត្តម នៅក្នុងឱកាសបុណ្យចម្រើនជន្មាយុ ខ្ញុំ គម្រប់៨៥ យាងចូល ៨៦ព្រះវស្សា ដែលផ្តល់យុត្តិធម៌ដល់ ខ្ញុំ ក្នុងការបំរើប្រជាជាតិ និងប្រជារាស្ត្រកម្ពុជា ។

សូមឯកឧត្តម ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានប្រកបតែនឹងព្រះពុទ្ធពរគ្រប់ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមឯកឧត្តម ទទួលនូវសេចក្តីរាប់អាន អំពីខ្ញុំ ។

ន មុនិនាថសីហនុ

នរោត្តម មុនិនាថ សីហនុ

ភ្នំពេញ ថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០២១

# អបអរសាទរ ទិវាមច្ឆជាតិ ០១ កក្កដា ឆ្នាំ២០២១

ថ្ងៃទី០១ ខែកក្កដា ជាទិវាដ៏មហានក្ខត្តឫក្ស ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទតែងតែប្រារព្ធ "ទិវា-មច្ឆជាតិ" ជារៀងរាល់ឆ្នាំពុំដែលអាក់ខានឡើយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងស្មារតីចូលរួមផ្សព្វផ្សាយ គ្រប់គ្រង ការពារ អភិរក្សធនធានធម្មជាតិ វារិជាតិ និងអភិវឌ្ឍន៍ធនធានជលផលឱ្យបានស្ថិតស្ថេរ និងនិរន្តរភាព សម្រាប់កូនចៅជំនាន់ក្រោយ។

សូមរំឮកជូនថា ចាប់តាំងពីឆ្នាំ២០០៣ "ទិវាមច្ឆជាតិ" ត្រូវបានប្រារព្ធជារៀងរាល់ឆ្នាំ ដោយមានការលែងមេពូជត្រី កូនត្រី និងវារីសត្វ ពូជក្នុងស្រុកប្រមាណ៥លានកូនក្នុង១ឆ្នាំ ចូលទៅក្នុងដែនទឹកធម្មជាតិ ដើម្បីបង្កើនផលស្តុកមច្ឆជាតិឱ្យកើនឡើង សម្រាប់ជួយទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

ប៉ុន្តែដោយសារហានិភ័យបណ្ដាលមកពីជំងឺឆ្លងកូវីដ-១៩ ដែលបាននឹងកំពុងរាតត្បាតជាសកល និងក្នុងព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលបានសម្រេចផ្អាកការរៀបចំ "ទិវាមច្ឆជាតិ" នេះ ចាប់ពីឆ្នាំ២០២០មកទល់ពេលនេះ ក្នុងគោលបំណងទប់ស្កាត់ការរាតត្បាតជំងឺឆ្លងជាសកលនេះនៅក្នុងសហគមន៍។ ទោះជាមានបញ្ហាដូចនេះក្តីការលែងកូនត្រីទៅក្នុងដែនសហគមន៍មានលក្ខណៈទ្រង់ទ្រាយតូចអាចប្រព្រឹត្តទៅបាន ប៉ុន្តែត្រូវអនុវត្តវិធានការសុខាភិបាលឱ្យបានខ្ជាប់ខ្ជួន។ ជាមួយនឹងការអបអរសាទរ "ទិវាមច្ឆជាតិ ០១ កក្កដា" ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមអំពាវនាវដល់បងប្អូនជនរួមជាតិ និងប្រជានេសាទទាំងអស់ត្រូវចងចាំ និងបន្តអនុវត្តនូវអនុសាសន៍ដ៏ត្រចះត្រចង់ទាំង៧ចំណុចរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ឱ្យបានខ្ជាប់ខ្ជួន៖

១. សូមកុំប្រើឧបករណ៍នេសាទខុសច្បាប់ សម្រាប់ធ្វើនេសាទដូចជា ថ្មស្អុយ ឧបករណ៍ឆក់ត្រី ស្បៃមុង គ្រឿងផ្ទុះ អ្វីក៏ដោយដែលឧបករណ៍នេសាទហាមឃាត់។
២. សូមកុំចាប់ត្រីក្នុងរដូវហាមឃាត់ គឺរដូវត្រីពង (ពីថ្ងៃទី០១ ខែមិថុនា ដល់ថ្ងៃទី៣១ ខែតុលា)សូមមេត្តារួមគ្នា ដើម្បីទុកត្រី ទុកឱ្យវាធំ ឱ្យវាពង ឱ្យវាញាស់ឡើង កុំចាប់វា កុំបំផ្លាញវា។
៣. សូមមេត្តាកុំកាប់ព្រៃលិចទឹក ដែលជាជម្រកត្រីពងកូន ជម្រកត្រី និងជាកន្លែងស្វែងរកចំណី ហើយក៏សុំជួយដាំព្រៃលិចទឹកឡើងវិញផងដែរ។
៤. ត្រូវជួយការពារតំបន់អភិរក្ស រាប់ទាំងការជួយផ្តល់ព័ត៌មានអំពីជនខិលខូច ឬមន្ត្រីខិលខូចចូលទៅបំផ្លាញក្នុងតំបន់អភិរក្ស។
៥. កុំយកបឹង ព្រែក ប្រើប្រាស់ខុសគោលដៅនេសាទគ្រួសារដូចជា ការដាំឈូក ឬចាក់ដីចូលលុបដើម្បីកសាងសំណង់ផ្សេងៗ។
៦. សូមកុំឱ្យមានទំនាស់រវាងប្រជាជន និងប្រជាជនលើបញ្ហាអ្នកនេសាទជាមួយអ្នកធ្វើស្រែប្រាំង និងទំនាស់ដែនទឹករវាងឃុំ និងឃុំ ស្រុក និងស្រុក ខេត្ត និងខេត្ត។
៧. ស្នើចូលរួម "ទិវាមច្ឆជាតិ ០១ កក្កដា" ជំរុញការចិញ្ចឹមត្រី ការធ្វើវារីវប្បកម្ម ការរក្សាទុកពូជត្រីធំៗ ឬជិតផុតពូជ។












អបអរសាទរ “ទិវាមច្ឆជាតិ ០១ កក្កដា” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# អបអរសាទរ រុក្ខទិវា ០៩ កក្កដា ឆ្នាំ២០២១

ថ្ងៃទី០៩ ខែកក្កដា ជាទិវាដ៏មហានក្ខត្តឫក្សដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានរដ្ឋបាលព្រៃឈើជាសេនាធិការ តែងតែសហការយ៉ាងល្អប្រសើរជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិប្រារព្ធពិធី "រុក្ខទិវា" ជារៀងរាល់ឆ្នាំក្រោមព្រះរាជវត្តមានដ៏ថ្លៃថ្លារបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យឆ្លៀតព្រះវរោកាសដ៏មានតម្លៃយាងជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុតក្នុងពិធី "រុក្ខទិវា" នេះ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមរំឭកជូនអំពីទស្សនវិស័យ និងព្រះរាជបញ្ញាញាណដ៏ភ្លឺស្វាងបំផុតរបស់ **ព្រះករុណាព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ ព្រះបរមរតនកោដ្ឋ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលព្រះអង្គបានបំផុសចលនាដាំដើមឈើ ហៅថា "រុក្ខទិវា" នេះឡើងតាំងពីទសវត្សរ៍ទី៣០ ដោយមានការចូលរួមយ៉ាងរស់រវើកពីប្រជា-ពលរដ្ឋគ្រប់ស្រទាប់ទាំងអស់ ហើយទីបំផុតត្រូវបានទទួលស្គាល់ជាពិធីប្រពៃណីជាតិមួយដែលកំណត់ដោយព្រះរាជក្រឹត្យលេខ៧៣៨ នស.រកត ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៥២។ ព្រះអង្គបានបណ្តុះនូវស្មារតីដល់កូនចៅគ្រប់ៗរូបឱ្យយល់ដឹងអំពីបរិស្ថាន អត្ថប្រយោជន៍នៃព្រៃឈើ ជីវៈចម្រុះគ្រប់ប្រភេទ ហើយព្រះអង្គមានព្រះរាជបន្ទូលថា "ការចូលរួមចំណែកការពារ និងថែរក្សាព្រៃឈើ ជាកាតព្វកិច្ចចាំបាច់របស់ពលរដ្ឋគ្រប់ៗរូប ហើយករណីយកិច្ចនេះគឺតកូន តចៅ និងបានបង្កឱ្យអាកាសធាតុមានប្រក្រតីភាពជាវិជ្ជមាន ចំពោះវិស័យកសិកម្ម និងមនុស្សជាតិ"។ ផ្អែកលើចក្ខុវិស័យដ៏ត្រចះត្រចង់នេះ និងដើម្បីបន្តស្នាព្រះហស្តដ៏ថ្លៃថ្លារបស់ **ព្រះករុណាព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ ព្រះបរមរតនកោដ្ឋ** រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃបំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានប្រកាសបង្កើតឡើងវិញនូវ "រុក្ខទិវា" តាមសេចក្តីសម្រេចលេខ០៨ ស.ស.រ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ១៩៩០ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលត្រូវប្រារព្ធឡើង នៅថ្ងៃទី០៩ ខែកក្កដា ជារៀងរាល់ឆ្នាំរហូតមក។ ជាក់ស្តែង គិតចាប់ពីឆ្នាំ១៩៩២ រហូតមកដល់ឆ្នាំ២០១៩ "ពិធីរុក្ខទិវា" បានប្រារព្ធធ្វើនៅតាមបណ្តារាជធានី-ខេត្តចំនួន១៤ទូទាំងប្រទេស សរុបចំនួន ២៦លើក នៅលើផ្ទៃដីទំហំ ៤៧០ហិកតា៦៥។ ប៉ុន្តែដោយសារហានិភ័យបណ្តាលមកពីជំងឺឆ្លងកូវីដ១៩ ដែលបាននឹងកំពុងរាតត្បាតជាសកល និងក្នុងព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលបានសម្រេចផ្អាកការរៀបចំ "រុក្ខទិវា" នេះ ចាប់ពីឆ្នាំ២០២០ មកទល់ពេលនេះ ក្នុងគោលបំណងទប់ស្កាត់ការរាតត្បាតជំងឺឆ្លងជាសកលនេះនៅក្នុងសហគមន៍។

ក្នុងនាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទយើង ខ្ញុំសូមអបអរសាទរ "រុក្ខទិវា ០៩ កក្កដា" ក្នុងស្មារតីចូលរួមផ្សព្វផ្សាយ ថែរក្សា ការពារ អភិរក្ស និងអភិវឌ្ឍន៍ធនធានព្រៃឈើ សត្វព្រៃគ្រប់ប្រភេទឱ្យបានស្ថិតស្ថេរ និងនិរន្តរភាពសម្រាប់កូនចៅរបស់យើងទាំងអស់គ្នាដោយអនុវត្តវិធានបច្ចេក-ទេសវៃឆ្លាត និងមានឆន្ទៈចូលរួមទប់ស្កាត់បទល្មើសព្រៃឈើតាមនីតិវិធីជាធរមាន។ ទន្ទឹមនឹងនេះ ខ្ញុំសង្ឃឹមថា បងប្អូនជនរួមជាតិទាំងអស់នឹងចងចាំជានិច្ចនូវព្រះរាជានុសាសន៍ដ៏ថ្លៃថ្លារបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលព្រះអង្គទ្រង់មានព្រះរាជបន្ទូលថា "រុក្ខទិវា" ជាពិធីមួយបានបង្ហាញឱ្យឃើញនូវទម្លាប់ដ៏ល្អប្រពៃរបស់ប្រជាជនយើង សហការសាមគ្គីគ្នា ការពារ ថែរក្សាព្រៃឈើ និងដាំដើមឈើ ដើម្បីបរិស្ថានធម្មជាតិល្អ សម្រាប់ជាឧត្តមប្រយោជន៍របស់យើងទាំងអស់គ្នាផង និងជាការសន្សំបុណ្យកុសលដ៏ធំធេងសម្រាប់មនុស្សជាតិគ្រប់រូបផង។

ជាមួយនឹងការអបអរសាទរ «រុក្ខទិវា ០៩ កក្កដា» ក្នុងនាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខ្ញុំសូម «អរគុណសន្តិភាព» និងអន្តរស្ថាប័នពាក់ព័ន្ធទាំងអស់ដែលបានចូលរួមយ៉ាងសកម្មតាមអភិក្រម«រដ្ឋ ឯកជន ដៃគូអភិវឌ្ឍន៍ និងសហ-គមន៍» ក្នុងការអភិវឌ្ឍវិស័យកសិកម្មនៅកម្ពុជាក្នុងបរិបទនៃបច្ចេកវិទ្យាឌីជីថលឱ្យទទួលបានជោគជ័យដើម្បីប្រែក្លាយជា "កសិកម្មទំនើបមានលក្ខណៈប្រកួតប្រជែង បរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាព ដែលនាំដល់ការកើនឡើងប្រាក់ចំណូលគ្រួសារកសិករ ប្រកបដោយវិបុលភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា" ។








**ព្រះរាជសកម្មភាពរបស់ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តមសីហមុនី** ព្រះមហាក្សត្រ
នៃព្រះរាជាណាចក្រកម្ពុជា យាងក្នុងពិធីអបអរសាទរ «រុក្ខទិវា ០៩ កក្កដា»

# ជំនួយស្មារតី
# ឯកឧត្តម វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមហ៊ុន Lexmin Pty Ltd Cambodia

ថ្ងៃសុក្រ ១៣ រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្ងៃទី៦ ខែសីហា ឆ្នាំ២០២១

## I- សេចក្តីផ្តើម

### ១. បដិសណ្ឋារកិច្ចចំពោះ៖

- ឯកឧត្តម តំណាងស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា
- តំណាងក្រុមហ៊ុន Lexmin Pty Ltd Cambodia
- ឯកឧត្តម លោកជំទាវ សមាជិក សមាជិកា នៃអង្គពិធីទាំងមូលដែលបានឆ្លៀតឱកាសអញ្ជើញចូលរួមក្នុងពិធីចុះអនុស្សរណៈយោគយល់គ្នានាពេលនេះ។




*ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីក្នុងពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមហ៊ុន Lexmin Pty Ltd Cambodia*

### ២. សារគារ និងកិច្ចសហប្រតិបត្តិការជាមួយប្រទេសអូស្ត្រាលី

គួររំឭកជូនថា ក្នុងរយៈពេលជាង៣០ឆ្នាំកន្លងមកនេះ គឺចាប់តាំងពីឆ្នាំ១៩៨៧មក ជំនួយគាំទ្ររបស់រដ្ឋាភិបាលអូស្ត្រាលីដល់ការអភិវឌ្ឍវិស័យកសិកម្មនៅកម្ពុជាបានផ្តោតជាសំខាន់លើការពង្រឹងការស្រាវជ្រាវ អភិវឌ្ឍន៍ សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ប្រព័ន្ធផលិតកម្មស្រូវពូជ និងខ្សែសង្វាក់ផលិតកម្មកសិកម្ម តាមរយៈការអនុវត្តគម្រោងជាច្រើនមានជាអាទិ៍៖ គម្រោងកម្ពុជា-អ៊ីរី-អូស្ត្រាលី (CIAP) គម្រោងផ្សព្វផ្សាយកសិកម្មកម្ពុជា-អូស្ត្រាលី (CAAEP) គម្រោងកែលម្អគុណភាពកសិកម្ម គម្រោងគាំទ្រវិទ្យាស្ថានស្រាវជ្រាវ និងអភិ-វឌ្ឍន៍កសិកម្មកម្ពុជា (CARDI-AP) កម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា (CAVAC) គម្រោងស្រាវជ្រាវ អភិវឌ្ឍកសិកម្មនានា ដែលគាំទ្រដោយមជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ស្រាវជ្រាវកសិកម្មអន្តរជាតិ (ACIAR Research Projects) ព្រមទាំងការកសាងហេដ្ឋារចនាសម្ព័ន្ធ និងអភិវឌ្ឍធនធានមនុស្សក្នុងវិស័យកសិកម្មនៅកម្ពុជា។ សមិទ្ធផលសំខាន់ៗដែលទទួលបានពីជំនួយរបស់រដ្ឋាភិបាលអូស្ត្រាលី ពិតជាបានបង្កើតនូវមូលដ្ឋានគ្រឹះ និងពង្រឹងរចនាសម្ព័ន្ធស្ថាប័នដ៏រឹងមាំលើការស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្ម ការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ការចែកចាយ និងផ្គត់ផ្គង់ធាតុចូលកសិកម្ម ខ្សែសង្វាក់ផលិតកម្មកសិកម្ម និងទីផ្សារកសិកម្ម ព្រមទាំងបានបង្កើតបណ្តាញទំនាក់ទំនងខ្សែសង្វាក់ផលិតកម្មកសិកម្ម និងទីផ្សារកសិកម្មនៅកម្ពុជាក្នុងសកម្មភាពមួយដ៏រស់រវើកប្រកបដោយមោទនភាព។ សូមរំឭកជូនថា កម្មវិធី CAVAC ជំហានទី១ បានចាប់ផ្តើមពីឆ្នាំ២០១០-២០១៥ និងមកទល់បច្ចុប្បន្ននេះ យើងកំពុងបន្តអនុវត្តកម្មវិធី CAVAC ជំហានទី២។

ជារួម បរិវិសទាននៃកម្មវិធី និងគម្រោងទាំងឡាយរបស់រដ្ឋាភិបាលអូស្ត្រាលីតាមរយៈការបញ្ជ្រាបបច្ចេកវិទ្យាទំនើបការបង្កើនធាតុចូល ទុនផលិត ការប្រើប្រាស់ធនធានដី និងទឹកប្រកបដោយនិរន្តរភាព ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ កែលម្អពូជដំណាំ ការកាត់បន្ថយការបាត់បង់ក្រោយពេលប្រមូលផល



*ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្លែងក្នុងពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមហ៊ុន Lexmin Pty Ltd Cambodia*

ការប្រកួតប្រជែងទីផ្សារប្រកបដោយគុណភាព និងសុវត្ថិភាព ដែលជាតម្រូវការចាំបាច់របស់កសិករពិតជាបានចូលរួមអនុវត្តនូវចក្ខុវិស័យ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការធ្វើទំនើបកម្មវិស័យកសិកម្មកម្ពុជា ក្នុងវិសាលភាព និងល្បឿនថ្មី ដើម្បីសម្រេចគោលដៅនៃការធ្វើសមាហរណកម្មទៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន និងសាកលភាវូបនីយកម្ម។

## II. គោលនយោបាយ

រាជរដ្ឋាភិបាលកម្ពុជា មានចក្ខុវិស័យរយៈពេលវែងក្នុងការប្រែក្លាយកម្ពុជាទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។ ឆ្លើយតបទៅនឹងចក្ខុវិស័យដ៏ត្រចះត្រចង់នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជាក៏មានមហិច្ឆតាក្នុងការធ្វើទំនើបកម្មវិស័យកសិកម្មឱ្យកាន់តែមានភាពប្រកួតប្រជែងប្រកបដោយបរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងមាននិរន្តរភាព ដែលនឹងនាំមកនូវការបង្កើនប្រាក់ចំណូលគ្រួសារកសិករ វិបុលភាព និងសុខុមាលភាពយូរអង្វែងសម្រាប់ប្រជាជនកម្ពុជា។ ម៉្យាងទៀត គោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២១-២០៣០ ត្រូវបានរៀបចំស្របតាមចក្ខុវិស័យរយៈពេលវែងនេះ ដែលមានគោលដៅចម្បង គឺបង្កើនតម្លៃបន្ថែមសរុបនៃវិស័យកសិកម្មឱ្យកើនយ៉ាងតិច៣% ក្នុងមួយឆ្នាំ និងបង្កើនផលិតភាពពលកម្មកសិកម្ម តាមរយៈការផ្ដល់សេវាកម្មដែលមានគុណភាព ដែលនឹងផ្ដល់មកវិញនូវការផ្គត់ផ្គង់ស្បៀងអាហារមានសុវត្ថិភាព និងមានអាហារូបត្ថម្ភគ្រប់គ្រាន់ ឆ្លើយតបទៅនឹងតម្រូវការក្នុងស្រុក និងកាត់បន្ថយការនាំចូល ព្រមទាំងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងដី ធនធានព្រៃឈើ និងជលផលប្រកបដោយចីរភាព។ ជាពិសេស ក្នុងបរិបទដែលប្រទេសជាតិយើងកំពុងទទួលរងនូវហានិភ័យនៃជំងឺឆ្លងកូវីដ-១៩នេះ និងក្រោយពេលវិបត្តិជាសាកលនេះបានស្រាកស្រាន្តទៅវិញ ឱ្យស្របនឹងការរីកលូតលាស់នៃសេដ្ឋកិច្ចជាតិ ក្នុងបរិបទនៃបដិវត្តន៍ឧស្សាហកម្មទី៤ និងបច្ចេកវិទ្យាឌីជីថល។

## III. ស្ថានភាពរួម

- កម្ពុជាសម្រេចបានសន្តិសុខស្បៀងនៅក្នុងឆ្នាំ១៩៩៥ និងក្នុងពេលបច្ចុប្បន្នមានអតិរេកផលិតផលកសិកម្មសម្រាប់នាំចេញរាប់លានតោនក្នុងមួយឆ្នាំៗ។ ជាក់ស្ដែងឆ្នាំ២០២០ កន្លងមក កម្ពុជានាំចេញផ្លូវការសរុបបានជិត៥លានតោន រីឯក្នុងរយៈពេល៧ខែដើមឆ្នាំ២០២១នេះ ការនាំចេញផលិតផលកសិកម្មសម្រេចបានជាង៥លានតោន។ ផ្ទុយមកវិញ ក្រៅពីការនាំចេញកសិផលបានក្នុងចំនួនដ៏ច្រើនយ៉ាងនេះក្ដីក៏កម្ពុជានៅមានការនាំចូលប្រភេទបន្លែ ផ្លែឈើ និងដំណាំស្បៀងមួយចំនួន ដើម្បីបំពេញទៅនឹងតម្រូវការជាក់ស្ដែងក្នុងស្រុកនេះផងដែរ។ ម៉្យាងទៀត ក្ដីកង្វល់របស់អ្នកបរិភោគអំពីសុវត្ថិភាពចំណីអាហារ ពិសេសសំណល់សារធាតុគីមីលើសកម្រិតនៅក្នុងកសិផលដូចជា ថ្នាំសម្លាប់សមាសភាពចង្រៃ និងសារធាតុគីមីផ្សេងទៀតដែលប្រើប្រាស់ពុំត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសក្នុងផលិតកម្មអំឡុងពេលដាំដុះ បានក្លាយជាបញ្ហាមានការចាប់អារម្មណ៍ខ្ពស់របស់ប្រជាពលរដ្ឋនៅក្នុងសង្គមនាពេលបច្ចុប្បន្ន។
- ស្ថិតិដំណាំបន្លែក្នុងឆ្នាំ២០២០ បានបង្ហាញថា ផ្ទៃដីផលិតកម្មសរុបមានចំនួន៥៧ ២០៨ ហិកតា ដែលទទួលបានបរិមាណផលសរុប ៦៨១ ០៩៩តោន។
- ទោះជាកម្ពុជានៅមានការនាំចូលបន្លែ និងផ្លែឈើមួយចំនួនពីប្រទេសជិតខាង ប៉ុន្តែកម្ពុជាក៏បាននឹងកំពុងនាំចេញផលិតផលបន្លែទៅកាន់ទីផ្សារអឺរ៉ុបផងដែរ ក្នុងបរិមាណប្រហែល២០០តោនក្នុងមួយឆ្នាំ។ ក្នុងឆ្នាំ២០២០ ដោយសារបញ្ហាការរាតត្បាតជំងឺកូវីដ-១៩ ការនាំចេញបន្លែទៅទីផ្សារអឺរ៉ុប មានការថយចុះដែលសម្រេចបានតែចំនួនជាង១០៥តោនប៉ុណ្ណោះ។

### ការអនុវត្តប្រព័ន្ធផលិតកម្មដំណាំធានាស្តង់ដារគុណភាព និងសុវត្ថិភាពចំណីអាហារ



ភ្ញៀវកិត្តិយស អញ្ជើញចូលរួមក្នុងពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមហ៊ុន Lexmin Pty Ltd Cambodia

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជំរុញការអនុវត្តប្រព័ន្ធផលិតកម្មនេះតាមរយៈការដាក់ចេញនូវប្រកាសពាក់ព័ន្ធចំនួន២រួមមាន៖ (១) ប្រកាសស្ដីពីវិធាននៃការអនុវត្តកសិកម្មល្អកម្ពុជា (CamGAP) ឆ្នាំ២០១០ និង(២) ប្រកាសស្ដីពី កសិកម្មសរីរាង្គកម្ពុជា លេខ១៦៣ ប្រក.កសក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២០ (CamOrg) ដែលជាយន្តការបច្ចេកទេសក្នុងការជំរុញ និងលើកកម្ពស់ផលិតកម្មកសិកម្មស្របតាមស្តង់ដារគុណភាព និងសុវត្ថិភាពចំណីអាហារ។
- មានដៃគូអភិវឌ្ឍន៍ និងគម្រោងអភិវឌ្ឍន៍ជាច្រើនបានសហការជាមួយ MAFF ក្នុងការជំរុញអនុវត្តប្រព័ន្ធផលិតកម្មទាំង២នេះដូចជា អង្គការFAO, GIZ, គម្រោងASPIRE, CASDP, LEAP, AVIP, CAVAC, CHAIN, CHQ (Cambodia Quality Horticulture) Project គាំទ្រដោយប្រទេសញូស៊ីលែន។ល។
- លទ្ធផលការងារសំខាន់ៗទាក់ទងនឹងការងារទាំង២នេះ ដែលអគ្គនាយកដ្ឋានកសិកម្មសម្រេចបានមានដូចខាងក្រោម៖
  - ឯកសារស្ដីពីវិធាននៃការអនុវត្តកសិកម្មល្អកម្ពុជា និងផែនទីបង្ហាញផ្លូវ៥ឆ្នាំ
  - ឯកសារស្ដីពីវិធានកសិកម្មសរីរាង្គកម្ពុជា និងផែនទីបង្ហាញផ្លូវ៥ឆ្នាំ
  - ឯកសារគោលការណ៍ស្ដីពីប្រព័ន្ធវិញ្ញាបនបត្រនៃការអនុវត្តកសិកម្មល្អកម្ពុជា
  - ប្រព័ន្ធ QR Code នៃការអនុវត្ត CamGAP សម្រាប់តាមដានប្រភពដើមកសិផល
  - បណ្តុះបណ្តាលមន្ត្រី កសិករ សហគមន៍កសិកម្មក្រុមហ៊ុនឯកជនបានរាប់ម៉ឺននាក់
  - បានចុះបញ្ជីកសិដ្ឋានបន្លែ និងផ្លែឈើនៃការអនុវត្តកសិកម្មល្អកម្ពុជា ចំនួន២៤៣ កសិដ្ឋាន ដែលអាចផ្គត់ផ្គង់បន្លែ និងផ្លែឈើ ដែលសមស្របតាមស្តង់ដារសុវត្ថិភាពចំណីអាហារសម្រាប់ការប្រើប្រាស់ក្នុងស្រុក និងជំរុញការនាំចេញបានកាន់តែច្រើនឡើង។ គួរកត់សម្គាល់ថាលក្ខខណ្ឌតម្រូវមួយនៃការអនុវត្តពិធីសារ ស្តីពីការនាំចេញផលិតផលកសិកម្មទៅកាន់ប្រទេសចិន ប្រទេសវៀតណាម ដូចជាផ្លែចេកស្រស់ និងផ្លែស្វាយ សុទ្ធតែតម្រូវឱ្យនាំចេញតែពីកសិដ្ឋានដែលត្រូវបានចុះបញ្ជីទទួលស្គាល់ការអនុវត្ត CamGAP តែប៉ុណ្ណោះ។

### ការពង្រឹងភាពជាដៃគូរវាងរដ្ឋ ឯកជន និងសហគមន៍/បណ្តុំកសិករផលិត

- ក្នុងទិសដៅជំរុញផលិតកម្មស្របតាមស្តង់ដារគុណភាព និងសុវត្ថិភាពចំណីអាហារ និងលក្ខខណ្ឌតម្រូវភូតគាមអនាម័យ តាមរយៈថវិកាកម្មវិធីរដ្ឋ និងគម្រោងដៃគូមួយចំនួន MAFF បាននឹងកំពុងជំរុញលើកទឹកចិត្តកសិករឱ្យផលិតបន្លែសុវត្ថិភាពដើម្បីកាត់បន្ថយការនាំចូលបន្លែពីប្រទេសជិតខាង និងដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងស្រុក។ ក្នុងចំណោមសហគមន៍កសិកម្មចំនួន ១ ១៩០សហគមន៍ មានសហគមន៍កសិកម្មផលិតបន្លែប្រមាណ ២៥៩សហគមន៍ និងមានក្រុមកសិករចំនួន ៤៣២ក្រុម កំពុងផលិតបន្លែសុវត្ថិភាព។ ជាមួយគ្នានេះ ក៏មានកសិករ ពាណិជ្ជករបន្លែ និងក្រុមហ៊ុនឯកជនមួយចំនួន បាននឹងកំពុងចូលរួមជំរុញផលិតកម្មបន្លែសុវត្ថិភាពដោយអនុវត្តតាមបច្ចេកទេសកសិកម្មទំនើបដោយប្រើប្រាស់ផ្ទះសំណាញ់ និងHydroponic។

## IV. សកម្មភាពរបស់ក្រុមហ៊ុន Lexmin Pty Ltd.

- ក្រុមហ៊ុនបាននឹងកំពុងអភិវឌ្ឍកសិដ្ឋានកសិកម្មសរីរាង្គលើផ្ទៃដី ២២ហិកតា មានទីតាំងនៅក្នុងតំបន់អភិវឌ្ឍន៍ តេជោសែន ក្នុងស្រុកឈូក ខេត្តកំពត ដែលដាំដុះប្រភេទដំណាំសម្រាប់កែច្នៃផលិតជាអាហារបំប៉នសុខភាពដូចជារុក្ខជាតិម្រុំស្លឹកគ្រៃ និងខ្ញីខ្មៅដែលកំពុងតែមានទីផ្សារខ្ពស់នៅក្រៅស្រុក និងមានគម្រោងបន្តពង្រីកផលិតកម្មការដាំដុះ បន្លែតាមស្តង់ដារសរីរាង្គសម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និងការនាំចេញផងដែរ។
- ក្រុមហ៊ុនបានរៀបចំខ្សែច្រវាក់ផលិតកម្ម និងកែច្នៃដែលត្រូវបានពិនិត្យវាយតម្លៃទទួលស្គាល់អនុលោមភាពតាម



*ភ្ញៀវកិត្តិយស អញ្ជើញចូលរួមក្នុងពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមហ៊ុន Lexmin Pty Ltd Cambodia*

ស្តង់ដារជាតិ និងអន្តរជាតិពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពអនាម័យ រួមមានទាំងស្តង់ដារសហភាពអឺរ៉ុប អាមេរិក អូស្ត្រាលី កាណាដា។ល។

◆ កន្លងមក ក្រុមហ៊ុនបានកែច្នៃជាផលិតផលសម្រេចសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក និងនាំចេញភាគច្រើនទៅកាន់ទីផ្សារប្រទេសអូស្ត្រាលី។ ថ្មីៗនេះ ក្រុមហ៊ុនបានសម្រេចកិច្ចព្រមព្រៀងក្នុងការផ្គត់ផ្គង់ផលិតផលសរីរាង្គចំនួន៥០តោនឱ្យដល់ដៃគូក្នុងស្រុកដ៏មានសក្តានុពលមួយគឺក្រុមហ៊ុន La Plantation ដែលជាក្រុមហ៊ុនមួយបាននឹងកំពុងដើរតួនាទីយ៉ាងសកម្មនៅក្នុងការដាំដុះ និងកែច្នៃម្រេចកំពតសម្រាប់នាំចេញទៅកាន់ទីផ្សារសហភាពអឺរ៉ុប។

◆ ក្រុមហ៊ុនបានសម្តែងនូវការប្តេជ្ញាចិត្តខ្ពស់ និងចូលរួមចំណែកជាមួយMAFF ក្នុងការលើកកម្ពស់ផលិតកម្មកសិកម្មសរីរាង្គ ស្របតាមប្រកាស ស្តីពីវិធានកសិកម្មសរីរាង្គកម្ពុជា និងរូបសញ្ញាជាតិសម្រាប់អនុវត្តក្នុងផលិតកម្ម និងការកែច្នៃបឋមដំណាំស្មៀង។ ស្របតាមគោលបំណងនេះ ក្រុមហ៊ុននឹងបន្តអភិវឌ្ឍប្រែក្លាយកសិដ្ឋានរបស់ខ្លួនឱ្យក្លាយជាកសិដ្ឋានគំរូមួយសម្រាប់ធ្វើជាថ្នាលបណ្តុះបណ្តាលផលិតកម្មកសិកម្មសរីរាង្គនៅក្នុងប្រទេសកម្ពុជា និងមានការទទួលស្គាល់ក្នុងតំបន់ផងដែរ។

◆ ក្រុមហ៊ុនក៏មានបំណងចូលរួមជាមួយMAFF ក្នុងការពង្រឹងសមត្ថភាពរបស់កសិករកម្ពុជាឱ្យទៅបំពេញការងារក្នុងកសិដ្ឋាននៅប្រទេសអូស្ត្រាលី ដោយពង្រីកសមត្ថភាពរបស់ពួកគេលើបច្ចេកទេសកសិកម្មទំនើប ទាន់សម័យ និងនាំយកត្រឡប់មកវិញនូវរាល់ចំណេះដឹងនិងបទពិសោធន៍ដ៏មានតម្លៃមកអភិវឌ្ឍន៍វិស័យកសិកម្មកម្ពុជានាពេលអនាគត។

## V. អនុសាសន៍

១. អគ្គនាយកដ្ឋានកសិកម្ម ត្រូវចងក្រងឯកសារគោលការណ៍ លិខិតបទដ្ឋានគតិយុត្តដែលចាំបាច់នានា សម្រាប់បម្រើដល់ការលើកកម្ពស់ការអនុវត្តវិធាននៃការអនុវត្តកសិកម្មល្អកម្ពុជា(CamGAP) និងវិធានកសិកម្មសរីរាង្គកម្ពុជា(CamOrg) ដោយបង្កើនកិច្ចសហការជាមួយគ្រប់ដៃគូពាក់ព័ន្ធ ដើម្បីជំរុញការលើកកម្ពស់ការអនុវត្តវិធាននៃការអនុវត្តកសិកម្មទាំង២ឱ្យកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផល។

២. ត្រូវបន្តពង្រឹងយន្តការផ្តល់សេវាកម្មត្រួតពិនិត្យ និងបញ្ជាក់គុណភាពសុវត្ថិភាពផលិតផលកសិកម្ម ដែលផលិតតាមស្តង់ដារ CamGAP&CamOrg ឱ្យបានកាន់តែរឹងមាំ ដើម្បីបង្កើនជំនឿទុកចិត្តពីអ្នកពាក់ព័ន្ធទាំងអស់។ ទន្ទឹមគ្នានេះ ត្រូវបន្តជំរុញការបញ្ជ្រាបការអនុវត្ត CamGAP&CamOrg ឱ្យបានកាន់តែទូលំទូលាយនៅទូទាំងប្រទេស ជាពិសេសតាមរយៈបណ្តុំកសិករ និងសហគមន៍កសិកម្ម ដើម្បីងាយស្រួលតាមដាន និងគ្រប់គ្រងនូវប្រភពបន្លែច្បាស់លាស់ ធានានូវគុណភាព និងសុវត្ថិភាព និងផ្សារភ្ជាប់ផលិតផលជាមួយទីផ្សារក្នុងស្រុក និងក្រៅស្រុក។

៣. ស្នើដល់ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងគ្រប់ភាគីពាក់ព័ន្ធ ចូលរួមផ្សព្វផ្សាយ និងគាំទ្រការអនុវត្ត CamGAP &CamOrg ឱ្យបានទូលំទូលាយ ព្រមទាំងត្រូវបន្តជំរុញការដាំដុះបន្លែ និងផ្លែឈើ ដែលមានឧត្តមភាពប្រកួតប្រជែងឱ្យបានគ្រប់រដូវ គោរពតាមស្តង់ដារអនាម័យខ្ពស់ ដើម្បីលើក



*ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញចូលរួមក្នុងពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមហ៊ុន Lexmin Pty Ltd Cambodia*




*ភ្ញៀវកិត្តិយស អញ្ជើញចូលរួមក្នុងពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមហ៊ុន Lexmin Pty Ltd Cambodia*

កម្ពស់ផលិតផលក្នុងស្រុក បង្កើនទំនុកចិត្តដល់អ្នកបរិភោគលើគុណភាព និងសុវត្ថិភាព និងភាពប្រកួតប្រជែង។

៤. អគ្គនាយកដ្ឋានកសិកម្ម ត្រូវបន្តពង្រឹងសមត្ថភាពរបស់ក្រុមផលិត បណ្ដុំកសិករ និងសហគមន៍កសិកម្ម ដែលអាចផលិតបន្លែក្នុងទ្រង់ទ្រាយធំ ដើម្បីធានានិរន្តរភាពនៃការផ្គត់ផ្គង់ដល់ទីផ្សារ និងអ្នកបញ្ជាទិញ និងបង្កើតបរិយាកាសពាណិជ្ជកម្ម តាមរយៈយន្តការអនុវត្តកសិកម្មតាមកិច្ចសន្យា។

## VI. សេចក្ដីបញ្ចប់

១. និយាយរួម ការរៀបចំព្រឹត្តិការណ៍នាពេលនេះ គឺពិតជាឆ្លើយតបទៅនឹងអភិក្រម “រដ្ឋ-ឯកជន-ដៃគូអភិវឌ្ឍន៍ និងសហគមន៍” ដែលជាយន្តការមួយក្នុងការចូលរួមដោះស្រាយនូវបញ្ហាប្រឈមដែលកសិករជួបប្រទះ ដោយមិនមើលរំលងអំពីការអនុវត្តកសិកម្មតាមកិច្ចសន្យា ក្រោមការជួយសម្របសម្រួលគាំទ្រពីអង្គភាពជំនាញនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីរួមចំណែកបង្កើនផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្មនៅកម្ពុជា ដែលមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា។

២. ជាថ្មីម្ដងទៀត ក្នុងនាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះក្រុមហ៊ុន Lexmin Pty Ltd Cambodia ដែលបានស្រុះស្រួលចុះអនុស្សរណៈយោគយល់គ្នានាថ្ងៃនេះ ដើម្បីចូលរួមលើកកម្ពស់ការអភិវឌ្ឍវិស័យកសិកម្មនៅកម្ពុជាឱ្យទទួលបានជោគជ័យតាមគោលដៅរំពឹងទុក ស្របតាមគោលនយោបាយ និងផែនការយុទ្ធសាស្ត្ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។










*ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីក្នុងពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមហ៊ុន Lexmin Pty Ltd Cambodia*

៣. ជាទីបញ្ចប់ ជាមួយនឹងការអបអរសាទរ “ពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា” នាពេលនេះ ខ្ញុំសូមជូនពរបវរប្រសើរចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកានៃអង្គពិធីទាំងមូល សូមទទួលបាននូវសិរីសួស្ដី ជ័យមង្គល វិបុលសុខគ្រប់ប្រការកុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**

# ចំណាប់អារម្មណ៍
# ឯកឧត្តម វេង សាខុន
# រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ថ្លែងក្នុងពិធីចុះអនុស្សរណៈយោគយល់ រវាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និង អគ្គលេខាធិការដ្ឋាន នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

ថ្ងៃព្រហស្បតិ៍ ៤កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្ងៃទី១២ ខែសីហា ឆ្នាំ ២០២១

**ជាបឋម ខ្ញុំសូមសម្តែងនូវកិច្ចស្វាគមន៍ចំពោះ៖**

- លោកជំទាវ អ៊ុក ម៉ាលី ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា សមាជិក សមាជិកានៃអង្គពិធីជាទីមេត្រី!



*ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីក្នុងពិធីចុះអនុស្សរណៈយោគយល់រវាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងអគ្គលេខាធិការដ្ឋាននៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម*

ថ្ងៃនេះ ខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានចូលរួមក្នុងពិធីចុះអនុស្សរណៈយោគយល់រវាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជានៃធនាគារជាតិកម្ពុជា និងអគ្គលេខាធិការដ្ឋាននៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ ពិតណាស់ថា ការរៀបចំពិធីចុះអនុស្សរណៈយោគយល់នាថ្ងៃនេះ គឺដើម្បីបង្កើតក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមកនូវទិន្នន័យ ការប្រឆាំង ការសម្អាតប្រាក់ ហិរញ្ញប្បទាន ភេរវកម្មដែលប្រើប្រាស់ក្នុងវិស័យកសិកម្ម មានជាអាទិ៍ បទល្មើសព្រៃឈើ បទល្មើសជលផល និងបទល្មើសផ្សេងៗទៀតតាមការចាំបាច់ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលត្រូវបានសង្ស័យ ឬពាក់ព័ន្ធនឹងការសម្អាតប្រាក់ ឬ ហិរញ្ញប្បទានភេរវកម្ម។

ជាមួយនេះដែរ ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះចំណាប់អារម្មណ៍ដ៏មានអត្ថន័យរបស់លោកជំទាវ **អ៊ុក ម៉ាលី** ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា ដែលបានលើកឡើងអំពីទស្សនទាន និងសារៈប្រយោជន៍នៃការចុះអនុស្សរណៈយោគយល់គ្នានាពេលនេះគឺ ដើម្បីលើកកម្ពស់ បង្កើនសមត្ថភាពវិភាគ តាមដាន និងត្រួតពិនិត្យកិច្ចការប្រឆាំង ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មក្នុងបុព្វហេតុផល



*ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្លែងក្នុងពិធីចុះអនុស្សរណៈយោគយល់រវាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និង អគ្គលេខាធិការដ្ឋាននៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម*



*ភ្ញៀវកិត្តិយសអញ្ជើញចូលរួមក្នុងពិធីចុះអនុស្សរណៈយោគយល់រវាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងអគ្គលេខាធិការដ្ឋាននៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម*

ប្រយោជន៍រួមប្រកបដោយសមធម៌ យុត្តិធម៌ និងតម្លាភាពសម្រាប់ព្រះរាជាណាចក្រកម្ពុជា ឆ្លើយតបទៅនឹងគោលនយោបាយកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣+២ ជាពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដ៏ត្រចះត្រចង់របស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា ក្នុងបរិការណ៍នៃបដិវត្តន៍ឧស្សាហកម្មទី៤ និងការរីកចម្រើននៃបច្ចេកវិទ្យាឌីជីថល។

ម្យ៉ាងទៀត យើងទាំងអស់គ្នាបានជ្រាបច្បាស់ហើយថា បញ្ហាជាសាកលដែលបានកើតមានឡើងចាប់តាំងពីដើមឆ្នាំ២០២០នេះគឺការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ បានក្លាយជាបញ្ហាប្រឈមដ៏ធំមួយ និងបានប៉ះពាល់ធ្ងន់ធ្ងរដល់សេដ្ឋកិច្ច-សង្គមនៅក្នុងតំបន់ និងពិភពលោក រួមទាំងកម្ពុជាផងដែរ ហើយរាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការ ដើម្បីជួយស្រោចស្រង់ កាត់បន្ថយផលប៉ះពាល់ និងគាំទ្រលើកស្ទួយនូវកំណើនសេដ្ឋកិច្ច។ ទោះជាយ៉ាងណា រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកវិស័យកសិកម្ម គឺជាវិស័យនាំមុខមួយក្នុងចំណោមវិស័យដទៃទៀត ដែលបានរួមវិភាគទានដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងបានរួមចំណែកក្នុងកំណើនផលទុនជាតិ ហើយវិស័យនេះក៏បានជួយផ្តល់ការងារ និងប្រាក់ចំណូលដល់ប្រជាពលរដ្ឋនៅជនបទ ដែលមានជីវភាពរស់នៅពឹងអាស្រ័យលើការងារកសិកម្ម។ យុទ្ធសាស្ត្រចម្បងរបស់រាជរដ្ឋាភិបាល គឺផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងលើការបង្កើនផលិតភាព និងការប្រកួតប្រជែង ព្រមទាំងផ្តល់នូវការផ្លាស់ប្តូររចនាសម្ព័ន្ធ និងការធ្វើពិពិធកម្មសេដ្ឋកិច្ចនៅក្នុងសកម្មភាពដែលមានតម្លៃបន្ថែមខ្ពស់។ លើសពីនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏មានចក្ខុវិស័យប្រាកដប្រជាក្នុងការធ្វើទំនើបកម្មវិស័យកសិកម្មឱ្យកាន់តែមានភាពប្រកួតប្រជែង បរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងមាននិរន្តរភាព ដែលនឹងធ្វើឱ្យកើនឡើងនូវប្រាក់ចំណូលគ្រួសារកសិករប្រកបដោយវិបុលភាព និងសុខុមាលភាពសម្រាប់ប្រជាជនកម្ពុជា ដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពដែលរាជរដ្ឋាភិបាលបានកំណត់នៅឆ្នាំ២០៣០។

ប្រាកដណាស់ថា ភាពជោគជ័យក្នុងការគ្រប់គ្រងវិស័យកសិកម្ម គឺបានមកពីការចូលរួមចំណែកជាចម្បងពីបណ្តាអង្គភាពជំនាញជាសេនាធិការក្រោមឱវាទក្រសួង ប្រកបដោយបទពិសោធន៍ និងក្រមសីលធម៌វិជ្ជាជីវៈខ្ពស់ ព្រមទាំងមានកិច្ចសហការល្អប្រកបដោយផ្លែផ្កាតាមអភិក្រម “ រដ្ឋ-ឯកជន-ដៃគូអភិវឌ្ឍន៍ និងសហគមន៍” ។ ទោះជាយ៉ាងណា យើងទទួលស្គាល់ថា កិច្ចខិតខំប្រឹងប្រែងដ៏សស្រាក់សស្រាំពីមន្ត្រីជំនាញ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរថ្នាក់ក្រោមជាតិក្នុងការទប់ស្កាត់បទល្មើសព្រៃឈើ ជលផល និងបទល្មើសផ្សេងៗទៀត ត្រូវបានវាយតម្លៃថា បានអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។ ក៏ប៉ុន្តែ បញ្ហាស្រួចស្រាល់ដែលបានកើតមានកន្លងមកក្នុងផ្នែកព្រៃឈើ និងជលផល ពិសេសការមិនបានគោរពច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីជលផលពីសំណាក់ជនខិលខូចមួយចំនួន បានធ្វើឱ្យមានការបាត់បង់



*ភ្ញៀវកិត្តិយសអញ្ជើញចូលរួមក្នុងពិធីចុះអនុស្សរណៈយោគយល់រវាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងអគ្គលេខាធិការដ្ឋាននៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម*



*ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីក្នុងពិធីចុះអនុស្សរណៈយោគយល់រវាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងអគ្គលេខាធិការដ្ឋាននៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្ដីពីការផ្លាស់ប្ដូរព័ត៌មានពាក់ព័ន្ធការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម*

ខូចខាតនូវប្រព័ន្ធអេកូឡូស៊ីធម្មជាតិ ការថយចុះនៃផ្ទៃដីគម្របព្រៃឈើ ព្រៃលិចទឹក នៅតំបន់រក្សាការពារ ដែលកិច្ចការនេះត្រូវតែបន្តការយកចិត្តទុកដាក់ឱ្យបានខ្ពស់បំផុតសម្រាប់ការអនុវត្តក្នុងរយៈពេលខាងមុខប្រកបដោយភាពរបរិស្ថាន។

ដោយមើលឃើញថា ការផ្ដល់ព័ត៌មានឱ្យគ្នាទៅវិញទៅមកអំពីបទល្មើសព្រៃឈើ បទល្មើសជលផល និងព័ត៌មានផ្សេងទៀតតាមការចាំបាច់ដែលត្រូវបានសង្ស័យ ឬជឿថាពាក់ព័ន្ធនឹងការសម្អាតប្រាក់ ឬហិរញ្ញប្បទានភេរវកម្មក្នុងវិស័យកសិកម្ម គឺពិតជាមានសារៈសំខាន់ណាស់។ ខ្ញុំជឿជាក់ថាការអនុវត្តអនុស្សរណៈយោគយល់នេះនឹងផ្ដល់ឱកាសឱ្យមន្ត្រីពាក់ព័ន្ធក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងទទួលបានការបណ្ដុះបណ្ដាលបន្ថែមលើកម្រិតជំនាញស៊ើបការណ៍ហិរញ្ញវត្ថុពាក់ព័ន្ធនឹងបទល្មើសផ្សេងៗដូចបានរៀបរាប់ខាងលើ ដើម្បីឱ្យការចែករំលែកព័ត៌មានទិន្នន័យទៅវិញទៅមកបានទាន់ពេលវេលាមានភាពសុក្រឹត យុត្តិធម៌ ទាំងបរិមាណ និងគុណភាព ដែលអាចទប់ស្កាត់បាននូវបទល្មើសព្រៃឈើ ជលផល និងបទល្មើសផ្សេងទៀតដែលស្ថិតក្នុងដែនសមត្ថកិច្ចនៃការទទួលខុសត្រូវរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលពាក់ព័ន្ធការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ បរិការណ៍នេះ គឺជាការរៀបចំនូវយន្តការមួយយ៉ាងល្អប្រសើរក្នុងការគ្រប់គ្រងវិបត្តិ និងហានិភ័យដែលអាចកើតឡើងក្នុងវិស័យហិរញ្ញវត្ថុ ធនាគារ កសិកម្ម និងវិស័យផ្សេងៗទៀតក្នុង





*ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីក្នុងពិធីចុះអនុស្សរណៈយោគយល់រវាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងអគ្គលេខាធិការដ្ឋាននៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្ដីពីការផ្លាស់ប្ដូរព័ត៌មានពាក់ព័ន្ធការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម*

ស្ថាប័នទទួលខុសត្រូវ។

ជាទីបញ្ចប់ ជាមួយនឹងការអបអរសាទរ ពិធីចុះអនុស្សរណៈយោគយល់រវាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា នៃធនាគារជាតិកម្ពុជា និងអគ្គលេខាធិការដ្ឋាននៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្ដីពីការផ្លាស់ប្ដូរព័ត៌មានពាក់ព័ន្ធការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម នាពេលនេះ ខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា សមាជិក សមាជិកា នៃអង្គពិធីទាំងមូល សូមទទួលនូវពុទ្ធពរទាំង ៤ប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

***សូមអរគុណ!***

# ឧបករណ៍នេសាទទឹកសាប នៃព្រះរាជាណាចក្រកម្ពុជា



ដោយ៖ រដ្ឋបាលជលផល

## I. សេចក្ដីផ្ដើម

### ១. វិស័យជលផលនៅប្រទេសកម្ពុជា

នេសាទទឹកសាបនៅប្រទេសកម្ពុជាបានពឹងផ្អែកទៅលើទន្លេមេគង្គ និងដៃរបស់វា ព្រមទាំងតំបន់លិចទឹកទាំងអស់ដែលជាទីកន្លែងមួយសំបូរទៅដោយជីវៈចម្រុះគ្រប់ប្រភេទនៅលើពិភពលោក និងជាទីតាំងប្រមូលផ្ដុំអាជីវកម្មអស់រយៈពេលរាប់សតវត្សមកហើយ។ បណ្ដាប្រទេស នៅតាមដងទន្លេមេគង្គទទួលបាននូវធនធានធម្មជាតិ ដ៏សម្បូរបែប ដូចជា ត្រី និងវារីសត្វគ្រប់ប្រភេទ ដោយសារតែប្រព័ន្ធទន្លេមេគង្គនៅមានដែនជម្រកធម្មជាតិយ៉ាងធំធេង និងមិនទាន់មានការសាងសង់ជាទំនប់ និងធ្វើសកម្មភាពឧស្សាហកម្មផ្សេងៗ ដែលជាមូលហេតុធ្វើឱ្យមានការប្រែប្រួលដល់ប្រព័ន្ធជលសាស្ត្ររបស់ទន្លេ ឬគុណភាពទឹកជាដើម។ ផលិតភាពខ្ពស់របស់ទន្លេ គឺអាស្រ័យលើភាពសាំញ៉ាំរបស់ប្រព័ន្ធទំនប់លិចទឹក ដែលជាអំណោយផលនៃធម្មជាតិទទួលបានពីមូសុងវស្សាប្រចាំឆ្នាំបង្កឱ្យមានទឹកជំនន់យ៉ាងធំមួយអស់រយៈពេលជាច្រើនខែគឺចាប់ពីខែឧសភាទៅខែវិច្ឆិកា។ ធារទឹកប្រហែលជា ៨៥ ទៅ ៩០% បានកើនឡើងនៅរដូវវស្សា ហើយនៅក្រចេះ (ប្រទេសកម្ពុជា) ធារទឹកអតិបរមារបស់ទន្លេមេគង្គ គឺកើនឡើង៥០ដង ធៀបទៅនឹងកម្រិតអប្បបរមារបស់វា។

នៅប្រទេសកម្ពុជាផ្ទៃដីប្រមាណជា ២០.០០០ ទៅ ២៥.០០០គីឡូម៉ែត្រការ៉េលិចទឹកជំនន់ជារៀងរាល់ឆ្នាំ។ វិសាលភាពនៃទឹកជំនន់អាស្រ័យលើឥទ្ធិពលមូសុងវស្សា។ តំបន់វាលទំនាបបឹងទន្លេសាប គឺជាបេះដូងរបស់ប្រទេសកម្ពុជា និងជាតំបន់ដែនជម្រកដីសើមធម្មជាតិស្ថិតនៅក្នុងប្រព័ន្ធទន្លេមេគង្គដ៏ធំបំផុតអស់រយៈពេលជាយូរលង់ណាស់មកហើយ។ ទន្ទឹមនឹងនេះ បឹងទន្លេសាបជាអាងទឹកសាបអចិន្ត្រៃយ៍ធំជាងគេបំផុតមួយនៅអាស៊ីអាគ្នេយ៍។ ផ្ទៃបឹងតភ្ជាប់គ្នាជាមួយនឹងទន្លេសាប ហើយប្រសព្វនឹងទន្លេមេគង្គត្រង់ចំណុចទីក្រុងភ្នំពេញ (រូបភាព ១)។ ដោយសារតែកម្រិតទឹកទន្លេមេគង្គនៅរដូវវស្សាខ្ពស់ជាងកម្រិតទឹកនៅទន្លេសាបដែលជាហេតុនាំឱ្យបឹងអាចពង្រីកវិសាលភាពបានធំជាងពី៣ ទៅ ៦ដង ប្រៀបនឹងរដូវប្រាំង និងមានទំហំពី២.៧០០ ដល់៩.០០០ ទៅ ១៦.០០០គីឡូម៉ែត្រការ៉េ។ នៅរដូវប្រាំងកម្ពស់ទឹកទន្លេមេគង្គបានស្រក់ចុះទាបធ្វើឱ្យទឹកហូរបញ្ច្រាស់ត្រឡប់ពីទន្លេសាបមកទន្លេមេគង្គវិញ។

ត្រីរាប់រយប្រភេទដែលរស់នៅតាមដងទន្លេអាចចាត់ថ្នាក់ជា២ក្រុមធំៗគឺ ត្រីខ្មៅ និងត្រីស។ ប្រភេទត្រីខ្មៅ ចូលចិត្តរស់នៅភាគច្រើនឬ ពេញមួយជីវិតរបស់វាតាមទំនាបលិចទឹកដែលជាកន្លែងមានទឹកថ្លាពណ៌ក្រម៉ៅ ដែលកើតឡើងដោយ




រូបភាពទី១ ផែនទីនៃភូមិភាគឥណ្ឌូចិនខាងត្បូង បង្ហាញពីទន្លេមេគង្គទំនាបលិច និងដែនដីសណ្ដ

សារតែការរលួយនៃសារធាតុខនិជពីរុក្ខជាតិ។ ផ្ទុយទៅវិញ ប្រភេទត្រីសចូលចិត្តរស់នៅតាមដងទន្លេធំៗ មានទឹកល្អក់ (ពណ៌ស) ដែលកើតឡើងដោយសារការហូរច្រោះពីតំបន់ខ្ពង់រាបខាងលើ។ នៅរដូវប្រាំង ប្រភេទត្រីសធំៗ ភាគច្រើន (រួមទាំងប្រភេទត្រីឆ្ពាំង និងត្រីកាបទន្លេ) ចូលចិត្តរស់នៅក្នុងអន្លង់ជ្រៅៗ ភាគខាងលើតាមតំបន់ទំនាបលិចទឹកសំខាន់ៗ ឧទាហរណ៍ ដូចជានៅតាមទន្លេមេគង្គ និងតាមដៃរបស់វាក្នុងខេត្តក្រចេះ និងខេត្តស្ទឹងត្រែង។ នៅដើមរដូវទឹកជំនន់ត្រីមេបានជម្រុះពង ហើយពងត្រី និងកូនញាស់រាប់លានក្បាលបានហូរធ្លាក់ចុះតាមចរន្តទឹក រួចបែកខ្ញែកទៅតាមតំបន់វាលទំនាបដែលតំបន់ទាំងនោះមានល័ក្ខខ័ណ្ឌអំណោយផលល្អប្រសើរដល់ការលូតលាស់យ៉ាងឆាប់រហ័សនៃពពួកកូនត្រីតូចៗ។ កូនត្រីម្យៅភាគច្រើនស៊ីប្លង់តុងសត្វ(zoo-plankton) ហើយនៅតាមផ្ទៃដីលិចទឹកដំបូងៗ អាចបង្កើតបានជាសរីរាង្គចិញ្ចឹមសម្រាប់ការលូតលាស់ដ៏ឆាប់រហ័សនៃពពួកប្លង់តុងរុក្ខជាតិ (phytoplankton) ដែលជាចំណីរបស់ពពួកប្លង់តុងសត្វ(zoo-plankton)។ ពពួកត្រីខ្មៅ (ដូចជា ត្រីរស់ ត្រីក្រាញ់) រស់នៅក្នុងត្លុក ត្រពាំង និងតាមបាតបឹង ឬ ក្រាំងនៅតាមតំបន់វាលទំនាបរង់ចាំរដូវវស្សាមកដល់ទើបវាចាប់ផ្តើមសកម្មភាពជីវិតជាថ្មី។

ត្រីទាំងអស់លូតលាស់យ៉ាងឆាប់រហ័សនៅតាមតំបន់វាលទំនាប ក៏ប៉ុន្តែនៅពេលដែលទឹកចាប់ផ្តើមស្រកចុះ ត្រីត្រូវបង្ខំចិត្តផ្លាស់ទីមករកកន្លែងដែលមានទឹកជ្រៅ ពពួកត្រីសធ្វើចរាចរត្រឡប់មករកទន្លេ និងបឹងទន្លេសាបវិញ ចំណែកឯពពួកត្រីខ្មៅវិញក៏ផ្លាស់ទី (lateral migration) មករស់នៅតាមត្លុកត្រពាំងដែលមានទឹកដក់នៅតាមវាលទំនាប។ បន្ទាប់មកត្រីសភាគច្រើនផ្លាស់ទីចុះតាមទន្លេសាប មកទន្លេមេគង្គ ហើយធ្វើចរាចរណ៍បន្តទៅរស់នៅលាក់ខ្លួនក្នុងអន្លង់ជ្រៅៗភាគខាងលើនារដូវប្រាំង។ តាមការផ្លាស់ទីតាមបណ្តោយទន្លេ(longitudi-nal migration) ប្រភេទត្រីដែលគេនេសាទបានតាមដងទន្លេមានប្រមាណ ៦៣% ជាប្រភេទ ត្រីស(Van Zalinge et al., 2000)។ ក្រៅពីប្រទេសត្រីសធំៗ មានប្រភេទត្រីតូចៗពេញវ័យជាច្រើនបានបន្តពូជនៅក្នុងឆ្នាំទី១ នៃជីវិតរបស់ពួកវា។ សន្ទស្សន៍នៃការចាប់គឺវាអាស្រ័យទៅលើកកម្រិតកម្ពស់ទឹកជំនន់ ឧទាហរណ៍ នៅពេលដែលមានទឹកជំនន់ធំ ទិន្នផលត្រីដែលចាប់បានក៏កើនឡើងដែរ។ ក្នុងចំណោមប្រភេទត្រីដែលវិវឌ្ឍទៅតាមកាលានុវត្ត "opportunists" ប្រភេទដែលមានបរិមាណច្រើនលើសលុបជាងគេ គឺត្រីរៀល "Henicorhynchus siamensis" (រូបភាពទី២) ដែលជាប្រភេទត្រីអាចកែច្នៃធ្វើជាប្រហុក និងចាត់ជាអាហារដ៏សំខាន់របស់ប្រជាជនកម្ពុជា។

ត្រីងាយទទួលរងគ្រោះបំផុតនៅពេលដែលគេនេសាទវាក្នុងអំឡុងពេលកំពុងធ្វើចរាចរណ៍ ជាពិសេសការប្រើប្រាស់ប្រភេទឧបករណ៍សិប្បកម្ម និងឧបករណ៍ឧស្សាហកម្មសម្រាប់ចាប់ត្រីនៅពេលដែលពួកវាធ្វើការផ្លាស់ទី គឺផ្តើមកើតមានចាប់ពីខែតុលាទៅ នៅពេលនោះទឹកចាប់ផ្តើមស្រកចុះអ្នកនេសាទអាចចាប់បានត្រីច្រើនសន្ធឹកសន្ធាប់ ព្រោះប្រភេទត្រីទាំងនោះប្រមូលផ្តុំគ្នាចុះតាមទឹកស្រក។



*រូបភាពទី២ ត្រីរៀលដែលមានបរិមាណប្រហែលជា៤០% ចាប់បានដោយឧបករណ៍ដាយប្រភេទត្រីទាំងនេះបង្កើតកូនចៅក្នុងរយៈពេល១ឆ្នាំ*

ការធ្វើនេសាទដោយឧបករណ៍ឧស្សាហកម្មនៅក្នុងបឹងទន្លេសាប និងតាមដងទន្លេសាបរួមមាន ព្រួលរត់ឈូង ស៊ីង និងលបណារ៉ាវនៅក្នុងបឹងទន្លេសាប របាំងឆ្នស់នៅតាមដែនដីសណ្តខេត្តកំពង់ឆ្នាំង និងដាយត្រីនេសាទតាមដងទន្លេសាប។ ការនេសាទដោយឧបករណ៍ឧស្សាហកម្មទាំងអស់នេះ គឺរដ្ឋាភិបាលជួលឱ្យជាសម្បទានតែប៉ុណ្ណោះ (Chevey and le Poulain 1940,Van Zalinge et al,2000)។ ប៉ុន្តែអ្នកនេសាទភាគច្រើនលើសលប់ប្រមាណជា១,២លាននាក់ ដែលរស់នៅតាមដងទន្លេសាប និងបឹងទន្លេសាបបានចូលរួមក្នុងសកម្មភាពនេសាទតាំងពីក្នុងកម្រិតកណ្តាល មធ្យម និងលក្ខណៈជាគ្រួសារ (Ahmed et al.,1998) ដោយប្រើប្រាស់ឧបករណ៍នេសាទ

តូចតាចដូចជា មង សំណាញ់ និងលបគ្រប់ប្រភេទ។

## ២. កំណាត់ប្រវត្តិ

ចាប់តាំងពីកកើតបឹងទន្លេសាបនៅប្រទេសកម្ពុជាបានកកើតឡើងប្រមាណពីរវាងឆ្នាំ៥.០០០ ទៅ ៦.០០០ឆ្នាំកន្លងមក (Carbonnel and Guiscafre 1963, Tsukawaki 1997) បឹងនេះបានផ្ដល់នូវបរិមាណត្រីដ៏ច្រើន និងគ្រប់ប្រភេទ។ ចក្រភពខ្មែរអង្គរដែលមានទឹកដីលាតសន្ធឹងយ៉ាងធំធេង បានចាប់បដិសន្ធិឡើង ដោយសារតែមានមូលដ្ឋានដ៏សំបូរស្តុកស្តម្ភនូវប្រភពត្រី និង ស្រូវអង្ករដែលទទួលផលបានមកពីតំបន់ដីលិចទឹកដ៏សំបូរជីវជាតិ។ ភោគផលត្រី និងការធ្វើនេសាទបានលាតត្រដាងឱ្យឃើញយ៉ាងច្បាស់នៅក្នុងចំណារប្រវត្តិសាស្ត្ររួមមានឧទាហរណ៍ជាក់ស្តែងដូចជា រូបចម្លាក់នៅយ៉ាងរឹងមាំក្បែរបឹងទន្លេសាប ខេត្តសៀមរាប។ ស្រូវ និងត្រី នៅតែជាម្ហូបអាហារដ៏សំខាន់សម្រាប់ប្រជាជនកម្ពុជាភាគច្រើន ហើយនៅរដូវវស្សា ប្រជាជនកម្ពុជាជាច្រើននាក់នៅតែនាំគ្នាធ្វើដំណើរមកកាន់ទន្លេសាប និងបឹងទន្លេសាប ដើម្បីប្រកបរបរជំនួសដោះដូរស្រូវ និងត្រី។ ជាការពិតណាស់នៅពេលថ្មីៗកន្លងទៅនេះកសិករនិយាយភាសាខ្មែររស់នៅភាគឦសាននៃប្រទេសថៃក៏នៅតែធ្វើដំណើរមកកាន់បឹងទន្លេសាប ប៉ុន្តែបច្ចុប្បន្ននេះ មានអ្នកជំនាញបានដឹកត្រីយកទៅលក់នៅទីនោះផ្ទាល់តែម្តង។ ភាពសម្បូរស្តុកស្តម្ភនៃធនធានត្រីនៅប្រទេសកម្ពុជា ត្រូវបានគេទទួលស្គាល់អស់រយៈពេលជាយូរលង់ណាស់មកហើយ ធនធាននេះត្រូវបានដាក់ជួលឱ្យធ្វើអាជីវកម្មតាមរយៈឡូត៍នេសាទក្រោមការគ្រប់គ្រងរបស់ច្បាប់ជលផលជាលើកដំបូង (petillot, 1911)។ Petillot បានកត់ត្រាឱ្យដឹងផងដែរថានៅឆ្នាំ១៩១០ ផលិតផលត្រីនាំចេញពីប្រទេសកម្ពុជា មានប្រមាណជា ៥០.០០០តោន មានជាអាទិ៍ ត្រីងៀត ត្រីរស់ ព្រមទាំងខ្លាញ់ត្រី និងប្រហុក។ នៅទសវត្សរ៍ឆ្នាំ១៩២០ និង១៩៣០ មានត្រីងៀតប្រមាណ ជា ២៥.០០០តោនក្នុងមួយឆ្នាំៗ ត្រូវបាននាំចេញទៅកាន់ប្រទេសឥណ្ឌូនេស៊ី បើធៀបទៅនឹងត្រីស្រស់វិញមានប្រមាណជា៧៥.០០០តោន។ Chevey និងLe Poulain ឆ្នាំ១៩៤០ បានធ្វើការប៉ាន់ប្រមាណទិន្នផលត្រីសរុបនៅប្រទេសកម្ពុជាថាមាន ១២០.០០០តោន ក្នុងមួយឆ្នាំៗ។ បច្ចុប្បន្ននេះ បរិមាណត្រីដ៏ច្រើននៅតែត្រូវបាននាំចេញទៅកាន់ប្រទេសថៃ និងប្រទេសវៀតណាមដែលមានភាគច្រើនជាត្រីស្រស់ ត្រីងៀត ត្រីឆ្អើរ ឬ ប្រហុក និងទឹកត្រី។

## ៣. សារៈសំខាន់របស់វិស័យជលផល និងស្ថានភាពនៃការធ្វើអាជីវកម្ម

ទោះបីជាផលិតភាព និងភាពសំបូរស្តុកស្តម្ភនៃធនធានត្រីនៅប្រទេសកម្ពុជា ត្រូវបានគេទទួលស្គាល់អស់រាប់សតវត្សរ៍កន្លងមកហើយក្តីតែរហូតមកដល់បច្ចុប្បន្ននេះ វិស័យជលផលនៅតែពុំទាន់ប្រមូលបាននូវព័ត៌មានច្បាស់លាស់ ឬ ស្ថិតិត្រឹមត្រូវនៅឡើយទេ។ ស្ថិតិប្រវត្តិស្តីពីផលចាប់ និងតម្លៃរបស់វានៅតែពុំទាន់មានច្បាស់លាស់នៅឡើយទេ គឺមានតែទិន្នន័យតិចតួចប៉ុណ្ណោះទៅតាមរដូវកាលដោយសារតែត្រីជាច្រើនត្រូវបានចាប់ដោយអ្នកនេសាទ ដែលប្រើប្រាស់ឧបករណ៍នេសាទតូចតាចនៅគ្រប់ទីកន្លែង។ ដូចនេះហើយទើបមានការពិបាកដើម្បីប្រមូលស្រង់ និងកំណត់នូវបរិមាណផលចាប់ឱ្យបានត្រឹមត្រូវ ត្រីជាច្រើនមិនត្រូវបានយកមកលក់ដូរឡើយ ទន្ទឹមនឹងនេះនៅមានទីផ្សារតូចៗជាច្រើនទៀត ដូចនេះហើយការពិនិត្យស្រាវជ្រាវនៅតាមទីផ្សារតូចៗ ជាច្រើនទៀត ដូចនេះហើយការពិនិត្យស្រាវជ្រាវនៅតាមទីផ្សារក៏មានការពិបាកផងដែរ។ ការសិក្សាទៅលើការប្រើប្រាស់(ឧទាហរណ៍ ត្រីសម្រាប់ទទួលទាន) អាចផ្តល់ឱ្យដឹងបាននូវទិន្នផលប៉ាន់ស្មានប្រហាក់ប្រហែលនៅពេលដែលគេអាចដឹងបានចំនួនមនុស្ស និងដឹងពីបម្រែបម្រួល កំណត់ចំពោះអាហារបរិភោគរបស់ពួកគាត់។ ផ្អែកលើការសិក្សាអាចឱ្យគេប៉ាន់ស្មានបានថា មានការប្រើប្រាស់ផលិតផលត្រីយ៉ាងហោចណាស់ប្រមាណជា៤០០.០០០តោនដែរ ដែលចាប់បានក្នុងមួយឆ្នាំៗ (Van Zalinge et al.,2000) នៅពេលថ្មីនេះ មានការប៉ាន់ប្រមាណថាមានបរិមាណប្រហែលដល់ទៅ៧០០.០០០តោន ឯណោះ (Sjorslev, 2001, Hortlenig Bush, 2003)។ សម្ពាធនៃការធ្វើនេសាទនាពេលបច្ចុប្បន្ននេះគឺមានចំនួនច្រើនហួស និងកំពុងតែមានការកើនឡើងបន្ថែមទៀត។ នេះដោយសារតែចំនួនប្រជាជនកម្ពុជាមានកំណើនកើនឡើង៣% ចាប់តាំងពីឆ្នាំ១៩៤០ ហើយប្រជាជនភាគច្រើន (៨៥%) រស់នៅតាមទីជនបទដែលក្នុងនោះមានរាប់លាននាក់ចូលរួមធ្វើនេសាទពេញម៉ោង និងខ្លះទៀតធ្វើនេសាទមិនពេញម៉ោង។ ទោះបីជាផលិតផលនេសាទសរុបអាចមានការកើនឡើងច្រើនជាងមុនក៏ដោយក៏ផលចាប់របស់អ្នកនេសាទម្នាក់ៗមានការថយចុះ។ ការនេសាទប្រភេទត្រីធំកំពុងថយចុះ ហើយបច្ចុប្បន្ននេះប្រភេទត្រីតូចដែលមានជីវិតរស់នៅខ្លី និងមានការលូតលាស់ឆាប់រហ័សនោះកំពុងមានការកើនឡើង តែចំពោះ

និទ្ទាការតម្លៃវិញ គឺទាបជាងមុន ដូច្នេះបើគិតជាតម្លៃត្រីជាមធ្យមក្នុង១គីឡូក្រាម គឺមានការធ្លាក់ចុះថោក។

តម្លៃត្រីប្រភេទលេខ១ ដែលនាំយកមកលក់នៅតាមដេប៉ូត្រី និងត្រៀមទុកសម្រាប់ផ្គត់ផ្គង់ឱ្យទីផ្សារ ឬ សម្រាប់នាំចេញក្រៅប្រទេស គឺមានតម្លៃសរុបប្រមាណជាជាង២០០លានដុល្លារ។ តម្លៃប៉ាន់ស្មាននេះមិនទាន់គិតបញ្ចូលនូវត្រីណាដែលពុំបាននាំយកមកលក់នៅតាមដេប៉ូត្រី ឬក៏ត្រីដែលត្រូវបានគេលក់យកប្រាក់ផ្ទាល់តែម្ដងនោះឡើយ ក្នុងនោះក៏ពុំបានគិតផងទេពីត្រីទុកសម្រាប់ហូបក្នុងគ្រួសារ និងដោះដូរជាមួយទំនិញទៅវិញទៅមក។ នៅក្នុងប្រទេសដែលប្រជាជនមានចំណូលជាមធ្យមប្រចាំថ្ងៃក្នុងម្នាក់ៗ ទទួលបានតិចជាង១ដុល្លារនោះ ត្រីមានសារៈសំខាន់ណាស់សម្រាប់សន្តិសុខស្បៀង ជាពិសេសសម្រាប់ប្រជាជនក្រីក្រតែម្ដង។ សិទ្ធអាចចូលរួមធ្វើអាជីវកម្មនៅក្នុងដែននេសាទផ្ទាល់ គឺមានសារៈសំខាន់ណាស់សម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជានៅតាមទីជនបទ។ ដូចនេះ ការធ្វើនេសាទទឹកសាប គឺមានតួនាទីសំខាន់ណាស់ដើម្បីជួយដល់សង្គមជាតិក្នុងការកាត់បន្ថយភាពក្រីក្រ( Degen- et al.,2000 )។

## II. គំរូឧបករណ៍នេសាទ

### ១. គោលបំណង និងកម្មវត្ថុ

សៀវភៅនេះរៀបរៀងឡើង ដើម្បីជួយដល់ការងារគ្រប់គ្រង និងស្រាវជ្រាវវិស័យជលផល។

កម្មវត្ថុពិតប្រាកដសម្រាប់អភិវឌ្ឍន៍សៀវភៅគំរូឧបករណ៍នេសាទមានដូចជា៖

១. កត់ត្រាទុកជាឯកសារនូវស្ថានភាពអភិវឌ្ឍន៍ប្រភេទឧបករណ៍នេសាទនៅកម្ពុជាដែលជាប្រទេសមួយមានវិសាលភាពជលផលធំធេង និងចម្រុះសម្បូរបែប

២. កត់ត្រាជាប្រព័ន្ធនូវចំណេះដឹង ដែលមានស្រាប់អំពីការប្រើប្រាស់ឧបករណ៍នេសាទសម្រាប់វិស័យជលផលទឹកសាបនៅប្រទេសកម្ពុជា

៣. ពង្រឹងសមត្ថភាពមន្ត្រីនាយកដ្ឋានជលផលឱ្យយល់ដឹងកាន់តែស៊ីជម្រៅអំពីការងារជលផលក៏ដូចជាសម្រាប់រៀបចំ និងអភិវឌ្ឍន៍ការងារស្រាវជ្រាវ

៤. ដើម្បីសម្របសម្រួលដល់ការយល់ដឹងឱ្យកាន់តែស៊ីជម្រៅពីទំនាក់ទំនងរវាងធនធានជលផល ដែនជម្រករបស់ត្រី និងផលប៉ះពាល់ដែលបណ្ដាលមកពីការធ្វើអាជីវកម្មរបស់មនុស្សដោយត្រូវសម្របសម្រួល ធ្វើយ៉ាងណាឱ្យការអភិរក្សធនធានជលផលកាន់តែមានប្រសិទ្ធភាព។

ចំពោះការងារគ្រប់គ្រងវិញ នៅពេលរៀបចំតាក់តែងក្រឹត្យច្បាប់ស្ដីពីការគ្រប់គ្រងវិស័យជលផលរបស់ប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៨៧ ប្រភេទឧបករណ៍នេសាទចែកចេញជា៣ក្រុមធំៗគឺប្រភេទឧបករណ៍គ្រួសារ ឧបករណ៍សិប្បកម្ម និងឧបករណ៍ឧស្សាហកម្ម ដោយផ្អែកតាមទំហំរបស់ឧបករណ៍ និងលទ្ធភាពនៃប្រាក់ចំណូលដែលទទួលបានពីការប្រើប្រាស់ប្រភេទឧបករណ៍នេសាទទាំងនោះ។ ច្បាប់ជលផលនោះអនុញ្ញាតឱ្យប្រើប្រាស់ឧបករណ៍នេសាទតែ ៥២ប្រភេទប៉ុណ្ណោះសម្រាប់នេសាទនៅក្នុងដែនទឹកសាប ក្រៅពីឧបករណ៍នេសាទដែលពុំបានរៀបរាប់នៅក្នុងច្បាស់ត្រូវចាត់ទុកជាប្រភេទឧបករណ៍ខុសច្បាប់។ ជាផលវិបាក គឺមានអ្នកនេសាទជាច្រើនធ្វើនេសាទខុសច្បាប់ដោយសារតែឧបករណ៍នេសាទពួកគាត់ដែលប្រើប្រាស់សម្រាប់ធ្វើនេសាទនោះ ពុំមានចែងនៅក្នុងច្បាប់។ ដូច្នេះសៀវភៅគំរូឧបករណ៍នេសាទនេះនឹង អាចជាជំនួយដ៏មានសារៈសំខាន់ដល់ការងារគ្រប់គ្រងវិស័យជលផលទឹកសាប ពីព្រោះវាបានកំណត់ និងពិពណ៌នាយ៉ាងត្រឹមត្រូវនូវរាល់ប្រភេទឧបករណ៍នេសាទ ដូច្នេះសៀវភៅនេះអាចយកទៅប្រើប្រាស់ដើម្បីដាក់កម្រិតសម្រាប់អភិរក្សធនធានជលផល ឧទាហរណ៍ដូចជា សម្រាប់ហាមឃាត់នូវ ប្រភេទឧបករណ៍នេសាទណាមួយ ឬក៏អនុញ្ញាតឱ្យប្រើប្រាស់នូវប្រភេទឧបករណ៍ជាក់លាក់នៅក្នុងតំបន់កំណត់ណាមួយ និងតាមពេលវេលាដ៏ត្រឹមត្រូវ។

ជាលទ្ធផលដែលមាននៅក្នុងច្បាប់ជលផលសព្វថ្ងៃគឺបានចែងតែប្រភេទឧបករណ៍នេសាទមួយចំនួនដែលមាននាពេលបច្ចុប្បន្ននេះប៉ុណ្ណោះ ដូចនេះការងារស្រាវជ្រាវដែលធ្វើតែទៅលើប្រភេទឧបករណ៍ស្របច្បាប់នឹងធ្វើឱ្យមានការប៉ាន់ស្មាន់ខុសពីទំហំ និងតម្លៃរបស់វិស័យជលផល ហើយទន្ទឹមនឹងនេះអ្នកចុះអង្កេតជាទូទៅនឹងជួបប្រទះការលំបាកក្នុងការប្រមូលយកព័ត៌មានពីផលចាប់ដោយប្រភេទឧបករណ៍នេសាទខុសច្បាប់។ សៀវភៅគំរូប្រភេទឧបករណ៍នេសាទនេះនឹងជួយដល់រាល់គ្រប់សកម្មភាព ដែលតម្រង់ទិសទៅរកការវាយតម្លៃ ឬត្រួតពិនិត្យវិស័យជលផលក៏ដូចជាបង្ហាញឱ្យដឹងច្បាស់នូវភាពជាក់លាក់ត្រឹមត្រូវនៃទំហំឧបករណ៍ និងចរិកលក្ខណៈក៏ដូចជាអាចឱ្យដឹងពីមូលដ្ឋានគំរូក្នុងការវាស់វែង និងកំណត់នូវប្រភេទ

ឧបករណ៍ដែលបានប្រើប្រាស់ក្នុងការស្រាវជ្រាវនៅតាមមូលដ្ឋានណាមួយច្បាស់លាស់។

ក្រៅពីអត្ថប្រយោជន៍នៃវិធានច្បាស់សម្រាប់គ្រប់គ្រង និងសិក្សាស្រាវជ្រាវវិស័យជលផល ឧបករណ៍នេសាទនៅបានពិពណ៌នាបង្ហាញពីវប្បធម៌ ជីវភាពរស់នៅដ៏គួរឱ្យចាប់អារម្មណ៍របស់ប្រជាជនកម្ពុជាដែលបានរស់នៅពឹងពាក់អាស្រ័យលើធនធានដ៏សម្បូរបែបរបស់ទន្លេមេគង្គអស់រយៈពេលជាច្រើនសតវត្សរ៍មកហើយ។ ដូច្នេះសង្ឃឹមថា សៀវភៅគំរូឧបករណ៍នេសាទនេះនឹងមានប្រយោជន៍ មិនគ្រាន់តែប្រើប្រាស់ធ្វើជាប្រភពមូលដ្ឋានបង្អែកសម្រាប់មន្ត្រីគ្រប់គ្រង និងមន្ត្រីរដ្ឋបាលជលផលប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងជួយដល់អ្នករៀបចំធ្វើផែនការបរិស្ថាន អ្នកជីវសាស្ត្រ អ្នកប្រវត្តិសាស្ត្រ គ្រូបង្រៀន និងមន្ត្រីផ្សព្វផ្សាយទាំងអស់ដែលមានការរួមចំណែកពាក់ព័ន្ធក្នុងសកម្មភាពស្រាវជ្រាវ និងគ្រប់គ្រងធនធានធម្មជាតិនៅក្នុងអាងទន្លេមេគង្គក៏ដូចជាតំបន់ដ៏ទៃទៀតផងដែរ។

### ២. វិធីសាស្ត្រ និងដំណើរការស្រាវជ្រាវ

សៀវភៅគំរូឧបករណ៍នេសាទនេះបានរៀបចំចងក្រងឡើងក្រោមជំនួយឧបត្ថម្ភជាថវិការបស់អង្គការផ្ដល់ជំនួយដានីដា (DANIDA) គម្រោងការណ៍គ្រប់គ្រងនេសាទទឹកសាបនៃកម្មវិធីជលផលរបស់គណៈកម្មការទន្លេមេគង្គ។ មន្ត្រីជលផលថ្នាក់ជាតិបានដើរតួនាទីជាអ្នកដឹកនាំ រីឯមន្ត្រីថ្នាក់ខេត្តបំពេញតួនាទីជាអ្នកទិន្នន័យ។ មន្ត្រីទាំងអស់បានចូលរួមវគ្គបំពាក់បំប៉នស្ដីអំពីគោលការណ៍ជាមូលដ្ឋាននៃឧបករណ៍នេសាទ ប្រជុំស័ព្ទបច្ចេកទេសសំខាន់ៗ របៀបគូររូបបច្ចេកទេស និងវិធីសាស្ត្រធ្វើបាយការណ៍។ ទម្រង់គំរូប្រមូលទិន្នន័យបានរៀបចំកែលម្អ។ បញ្ជីសំនួរបានផ្ដោតទៅលើការលើកទឹកចិត្តឱ្យមានគំនិតច្នៃប្រឌិត និងទឹកចិត្តចង់ចូលរួមពីសំណាក់អ្នកប្រមូលទិន្នន័យទាំងអស់ ដោយអនុញ្ញាតឱ្យពួកគាត់មានស្វ័យភាពទទួលខុសត្រូវកែលម្អនូវរាល់ប្រធានបទស្រាវជ្រាវ។ ព័ត៌មានដែលប្រមូលបានភាគច្រើន គឺសំដៅរៀបរាប់អំពីឧបករណ៍នេសាទ ទំហំឧបករណ៍ សម្ភារសម្រាប់តម្លើងឧបករណ៍ តម្លៃ របៀបប្រើប្រាស់ឧបករណ៍របស់អ្នកនេសាទ ដែននេសាទ និងរដូវនេសាទទិដ្ឋភាពយេនឌ័រ និងប្រភេទឧបករណ៍រួមផ្សំ។ ថតយកជារូបភាពស្រង់យកជាគំនូរបច្ចេកទេសបន្ថែម និងរបៀបប្រើប្រាស់ឧបករណ៍នេសាទ។

អ្នកប្រមូលព័ត៌មានម្នាក់ៗ ទទួលបានឧបករណ៍ស្រាវជ្រាវរួមមានកូនសម្ភាធតូចមួយដែលមានសម្ភារការិយាល័យ ដូចជា ប៊ិចគ្រប់ពណ៌ ក្រដាសមីល្លីម៉ែត្រ បន្ទាត់ ម៉ែត្រវាស់តូចធំ ដែកឈាន និងម៉ាស៊ីនថត៣៥មីល្លីម៉ែត្រ។ ការប្រមូលទិន្នន័យធ្វើឡើងនៅតាមបណ្ដាខេត្តដែលមានដែននេសាទសំខាន់ៗ ភាគច្រើនដូចជាខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង ខេត្តកណ្ដាល រាជធានីភ្នំពេញ ខេត្តតាកែវ ខេត្តព្រៃវែង ខេត្តកំពង់ចាម ខេត្តក្រចេះ និងខេត្តស្ទឹងត្រែង។

សន្លឹកទិន្នន័យទាំងអស់ បានប្រមូលផ្ដុំគ្នានៅឯការិយាល័យគម្រោងដើម្បីត្រួតពិនិត្យ។ ភារកិច្ចរបស់អ្នកស្រាវជ្រាវ




*រូបភាពទី៣ ឧបករណ៍នេសាទដែលមានមុខនាទីដល់ការសម្រេចចិត្តរបស់អ្នកជលផល*

គឺត្រូវកត់ត្រាយកជាឯកសារឱ្យបានសុក្រឹត្យបំផុតនូវឧបករណ៍នេសាទណាមួយដែលបានជួបប្រទះដោយត្រូវធ្វើការវាស់វែងឱ្យបានត្រឹមត្រូវ។ ចាប់តាំងពីពេលឧបករណ៍នេសាទរៀបចំសាងសង់ឡើង ឬប្រមូលផ្ដុំគ្នាដោយសិប្បករ ឧបករណ៍នីមួយៗគឺត្រូវបានកំណត់ដោយឡែកៗពីគ្នា ដូចនេះការវាស់វែងបង្ហាញហើយការវាស់វែងនោះអាចមានការប្រែប្រួលខុសៗគ្នា បន្តិចបន្តួចរវាងអ្នកនេសាទម្នាក់ទៅអ្នកនេសាទម្នាក់ទៀត ពីអ្នករៀបចំសាងសង់ឧបករណ៍ម្នាក់ ទៅអ្នករៀបចំម្នាក់ទៀត ខុសគ្នាពីមួយឆ្នាំទៅមួយឆ្នាំ និងពីទីកន្លែងមួយទៅទីកន្លែងមួយទៀត។

ការរៀបចំសៀវភៅគំរូឧបករណ៍នេសាទនេះ គឺស្ថិតក្នុងដំណើរការរៀនសូត្រទាំងអ្នកប្រមូលផ្ដុំចងក្រងក៏ដូចជាអ្នករួមសហការនៅតាមមូលដ្ឋានផងដែរ។ សៀវភៅគំរូឧបករណ៍នេសាទនេះមិនមានមន្ទិលថាមានកំហុស និងមានការរំលងកន្លែងណាឡើយ ហើយសង្ឃឹមថាការបោះផ្សាយលើកក្រោយៗទៀតនឹងមានឧបករណ៍រឹតតែច្រើនជាងនេះថែមទៀតហើយប្រហែលជាអាចចាត់ថ្នាក់បានរឹតតែប្រសើរ ដោយរៀនសូត្រពីបទពិសោធន៍ដែលទទួលបានពីការចងក្រងឧបករណ៍នេសាទដូចបានបង្ហាញក្នុងសៀវភៅនេះ និងរួមជាមួយលទ្ធផលស្រាវជ្រាវបន្ថែមទៀត។

### ៣. គោលគំនិត

អ្នកនេសាទប្រើប្រាស់ឧបករណ៍ខុសៗគ្នា និងច្រើនរបៀបអាស្រ័យទៅលើកត្តាមួយចំនួនរួមមាន ប្រភេទត្រីគោលដៅ ដែលជម្រកពេលវេលា និងលក្ខខណ្ឌជលសាស្ត្រ។ ឧទាហរណ៍ វិធីសាស្ត្រយ៉ាងសាមញ្ញបំផុតមួយសម្រាប់នេសាទត្រីគឺការចាប់ដោយដៃទទេ និងរបៀបនេសាទដ៏សាំញ៉ាំនោះ គឺការធ្វើនេសាទជាលក្ខណៈឧស្សាហកម្មដោយប្រើប្រាស់ឧបករណ៍ជាច្រើនប្រភេទរួមផ្សំជាមួយវិធីផ្សេងៗ ដើម្បីធ្វើឱ្យស៊ីសង្វាក់គ្នាក្នុងពេលតែមួយ។

ឧបករណ៍នេសាទគឺតែងមានទំនាក់ទំនងគ្នារវាងអ្នកនេសាទជាមួយនឹងត្រី។ ឧបករណ៍ដែលគេជ្រើសរើស និងវិធីដែលគេប្រើប្រាស់បង្ហាញនូវទិដ្ឋភាពជាច្រើនរបៀបនៃចរឹករបស់ប្រភេទត្រីដែលត្រូវនេសាទ ដែនជម្រករស់នៅរបស់ពួកវាបម្រែបម្រួលភូមិសាស្ត្រ និងរដូវកាល ពីព្រោះប្រភេទឧបករណ៍ដែលជ្រើសរើសសម្រាប់ប្រើប្រាស់នោះ គឺទៅតាមការយល់ដឹងរបស់អ្នកនេសាទដែលចេះតៗគ្នារាប់សិបឆ្នាំមកហើយ។ ចំណែកឧបករណ៍នេសាទវិញ ក៏ជាឧទាហរណ៍បញ្ជាក់ឱ្យឃើញផងដែរពីបច្ចេកវិទ្យានៅតាមមូលដ្ឋាន និងបង្ហាញពីរបៀបសម្រេចចិត្តរបស់អ្នកនេសាទចំពោះលទ្ធភាពនៃការរៀបចំ ឬការគ្រប់គ្រងដើម្បីបំពេញបំណងនៃសេចក្ដីត្រូវការរបស់ពួកគាត់ និងធ្វើយ៉ាងណាឱ្យការធ្វើអាជីវកម្មធនធានជលផលមាននិរន្តភាពទៅថ្ងៃអនាគត(រូបភាពទី៣)។

ប្រពៃណី និងពិធីបុណ្យទាំងឡាយដែលទាក់ទងនឹងត្រីគឺជាចំណែកមួយនៃការប្រមូលគ្នាដើម្បីរៀបចំការងារគ្រប់គ្រងនៅតាមមូលដ្ឋាន។ ការប្រើប្រាស់ឧបករណ៍នេសាទប្រភេទណាមួយគឺជាជម្រើសរបស់អ្នកនេសាទដែលបញ្ជាក់ឱ្យឃើញផងដែរនូវជំនឿ និងបម្រាមពិសិដ្ឋ។ តាមធម៌វិន័យព្រះពុទ្ធ ការនេសាទមិនអនុញ្ញាតឱ្យធ្វើនៅជិតទីវត្តអារាមឡើយ។ ទន្ទឹមនឹងនេះផងដែរ កន្លែងអារុក្ខអារក្សក៏ច្រើនហាមឃាត់ការធ្វើនេសាទផងដែរ។ ជំនឿក៏នៅតែមានជាប់តមករហូតចំពោះអ្នកតាត្រង់នេះគឺមានប្រយោជន៍ខ្លាំងណាស់ដើម្បីធ្វើការជ្រើសរើសកំណត់តំបន់សម្រាប់អភិរក្សធនធាន។ តែយ៉ាងណាមិញ ទិដ្ឋភាពដ៏មានសារៈសំខាន់ចំពោះការគ្រប់គ្រងវិស័យជលផល គឺពុំមានរៀបរាប់នៅក្នុងសៀវភៅនេះឡើយ។

### ៤. ចំណាត់ថ្នាក់ឧបករណ៍នេសាទ

ការចាត់ថ្នាក់ឧបករណ៍នេសាទភាគច្រើន យកតាមសៀវភៅបោះពុម្ពដោយលោក វង់( Von Brandt 1959 1972 និង1984 )។ លក្ខណៈវិនិច្ឆ័យចម្បងសម្រាប់ចាត់ថ្នាក់គឺផ្អែកលើគោលការណ៍នៃការនេសាទរបស់វា គឺមិនមែនផ្អែកលើសារៈសំខាន់របស់ឧបករណ៍នេសាទ ឬក៏ល្បាយរបស់វានៅក្នុងប្រទេសឡើយ។ ចំពោះការបែងចែកជាក្រុមរងវិញគឺត្រូវបានប្រើប្រាស់លក្ខណៈវិនិច្ឆ័យខុសៗគ្នា ដោយផ្អែកតាមទីកន្លែងដែលប្រភេទឧបករណ៍មាននៅនឹងមូលដ្ឋាន ដូចជា លប ទ្រូ ឬសៃយឺន ចំពោះករណីសៃយឺននេះវិញ គឺតែងមានភាពខុសៗគ្នាទៅគ្នាទៅតាមការរៀបតរាប់ និងទ្រង់ទ្រាយរបស់វា ហើយជាពិសេសនោះគឺទម្រង់របស់ប្រឹស។

ឧបករណ៍នេសាទទាំង១៦ក្រុមធំៗមានដូចតទៅ៖

១. នេសាទដោយដៃទទេ
២. ឧបករណ៍ដង ដួស និងជញ្ជាត់
៣. ឧបករណ៍ធ្វើឱ្យមានរបួស
៤. សន្ទូច
៥. អន្ទាក់
៦. មង

៧. អួន
៨. ឧបករណ៍ការអូស
៩. ឧបករណ៍ចូករុញ
១០. ឧបករណ៍លើក
១១. ឧបករណ៍ក្រុងគ្រប
១២. ឧបករណ៍ថ្នក់ចង់
១៣.វិធីសាស្រ្តធ្វើឱ្យសន្លប់
១៤. ការនេសាទដោយបូមបាច
១៥. ឧបករណ៍ធ្វើឱ្យត្រីកុំ
១៦. ឧបករណ៍ធ្វើអោយត្រីផ្អើល

ក្រុមសំខាន់ៗនៃឧបករណ៍នេសាទខាងលើនេះចែកចេញជា៤៤ប្រភេទរង ហើយបែងចែកបន្តទៀតជា ៩៤ក្រុមរងតូចៗ។ សរុបជារួមមានឧបករណ៍ និងសម្ភារនេសាទរួមផ្សំច្រើនជាង១៥០ប្រភេទ ដែលបានលើកយកមកបង្ហាញនៅក្នុងសៀវភៅនេះ។ បន្ថែមលើនេះនៅមានវេវចនៈស័ព្ទ ៥០ក្រុមទៀតក៏បានពិពណ៌នានៅក្នុងសៀវភៅគំរូឧបករណ៍នេសាទនេះដែរ។ ការរៀបចំចាត់ថ្នាក់ឧបករណ៍នេសាទខ្លះគឺធ្វើឡើងដោយមានការពិភាក្សាគ្នាយ៉ាងហ្មត់ចត់។ អ្នករៀបចំប្រមូលផ្តុំចងក្រងគ្រប់ៗគ្នាសុទ្ធតែមានទឹកចិត្តចូលរួមក្នុងការពិភាក្សា ដូចនេះសង្ឃឹមថា ភាពត្រឹមត្រូវប្រាកដប្រជា ចំពោះការកែ-សម្រួលប្រភេទគំរូឧបករណ៍នេសាទនៅថ្ងៃអនាគតនឹងរឹតតែធ្វើឱ្យទទួលបាននូវចំណាត់ថ្នាក់ដ៏ទូលំទូលាយ និងកាន់តែប្រសើរឡើង។

## III. បទបង្ហាញពីឧបករណ៍នេសាទ

ការណែនាំឱ្យស្គាល់ ពីប្រភេទឧបករណ៍នេសាទសំខាន់ៗតាមគម្រោងមានដូចតទៅ៖

### ១. ឈ្មោះ

ឧបករណ៍នេសាទបានដាក់ឈ្មោះជាភាសាខ្មែរ និងភាសាអង់គ្លេស។ មានឈ្មោះឧបករណ៍នេសាទប្រហែល២០០ ដែលបានកត់ត្រាស្រង់យកចេញមកពី១២ខេត្ត-ក្រុង។ ដូចដែលបានគិតទុក មានពេលខ្លះឧបករណ៍នេសាទដូចគ្នា គ្រាន់តែនៅទីកន្លែងខុសគ្នាគឺបានកត់ត្រាឈ្មោះខុសគ្នា ឬឧបករណ៍ខុសគ្នាតែកត់ត្រាមានឈ្មោះដូចគ្នា ដោយសារតែវាមាននៅតាមខេត្តផ្សេងពីគ្នា។ នៅកន្លែងខ្លះ ឧបករណ៍ដូចគ្នាក៏អាចហៅឈ្មោះខុសគ្នាដែរ ដោយសារតែអ្នកស្រង់ផ្អែកទៅលើតាមប្រភេទត្រីដែលចាប់បានតាមឧបករណ៍ ឬក៏ទ្រង់ទ្រាយមាត់ប្រើសរបស់វា ឬតាមទីកន្លែង ឬរបៀបនៃការធ្វើនេសាទ។

ឈ្មោះឧបករណ៍នេសាទជាភាសាខ្មែរ បានបកប្រែទៅជាភាសាអង់គ្លេសដើម្បីប្រើប្រាស់នៅក្នុងអនុសញ្ញាអន្តរជាតិសម្រាប់ការកំណត់ឈ្មោះឧបករណ៍នេសាទ និងទៅតាមច្បាប់ជលផលរបស់ប្រទេសកម្ពុជាសូមមើល Von Brandt 1959, 1972 និង1984; Nedelec និងPrado 1990; Department of Fisheries,1990 និងClaridge et al.,1997 )។

### ២. ការពិពណ៌នាអំពីឧបករណ៍នេសាទ និងដំណើរការ

ឧបករណ៍នេសាទនីមួយៗ ដែលប្រមូលបានពីគ្រប់បណ្តាខេត្ត-ក្រុង បានពិពណ៌នាសង្ខេបអំពីបច្ចេកទេសរបស់វាដោយគិតពិចារណាទាំងទៅលើភាពស្រដៀងគ្នា ក៏ដូចជាការខុសគ្នានៅតាមតំបន់ ហើយជួនកាលក៏បានបង្ហាញពីប្រភពផ្ទាល់របស់អ្នកធ្វើឧបករណ៍នោះផងដែរ។ ការកត់ត្រារង្វាស់ខ្នាតរបស់ឧបករណ៍នេសាទនីមួយៗនោះគឺបានដកស្រង់យកចេញពីការធ្វើអង្កេតនៅតាមមូលដ្ឋាន។

### ៣. គំនូរ

គំនូរបច្ចេកទេសនីមួយៗជាឧបករណ៍របស់ឧបករណ៍ជាក់លាក់ណាមួយ ដែលបានជួបប្រទះនៅតាមមូលដ្ឋាន។ ជាទូទៅ គំនូរពិតៗ និងស្រដៀងគ្នាបំផុតនោះគឺដកស្រង់ចេញមកពីអ្នកប្រមូលទិន្នន័យដែលបានជ្រើសរើសធ្វើជាឧបករណ៍ រួចហើយរៀបចំគូរឡើងវិញសម្រាប់បោះពុម្ព។ គំនូររបស់ឧប-ករណ៍នេសាទធំៗ និងការធ្វើអាជីវកម្មនេសាទដោយប្រើឧប-ករណ៍ឧស្សាហកម្មដែលមានលក្ខណៈសាំញ៉ាំ គឺបានបង្ហាញនូវបច្ចេកទេសតិចតួចប៉ុណ្ណោះ ហើយជួនកាលក៏បានដកស្រង់យកចេញពីឯកសាររបស់ ឆេវី (Chevy) និងឡេប៉ូឡាំង (Le-Pouliain)១៩៤០ និងហ្វីលី(Fily) និងដេអូបេនតុន (D`Au-benton)១៩៦៥។ គំនូរនៃការធ្វើនេសាទគឺគូរយកតាមគម្រោងដែលស្រង់បានមកពីមូលដ្ឋានដោយអ្នកប្រមូលទិន្នន័យ។

### ៤. រូបថត

រូបភាពភាគច្រើនថតដោយអ្នកប្រមូលទិន្នន័យដែលបានកត់ត្រាថាជាអ្នកសហការ និងរៀបចំចងក្រងឯកសារ។ បន្ថែមលើនេះ រូបថតមួយចំនួនទៀតទទួលបានពីស្នាដៃរូបភាពរបស់គណៈកម្មការទន្លេមេគង្គ និងជំនាញឌីជីថលមួយចំនួនទៀតដកស្រង់ចេញពីឯកសារវីដេអូ “មានទឹក មានត្រី” ដែលផលិតដោយគណៈកម្មការទន្លេមេគង្គដោយរួមសហការជាមួយនាយកដ្ឋានជលផលនៃប្រទេសកម្ពុជា។ ប៉ុន្តែក៏មានឧបករណ៍

នេសាទខុសច្បាប់មួយចំនួនមិនអាចថតយករូបភាពបានឡើយ។

### ៥. តម្លៃ

តម្លៃរបស់ឧបករណ៍នេសាទបានគិតគូរទៅតាមរូបិយប័ណ្ណប្រាក់រៀលរបស់កម្ពុជា។ ការប៉ាន់តម្លៃ គឺយោងទៅលើថ្លៃក្នុងចន្លោះឆ្នាំ១៩៩៨ និង២០០០។ អាត្រាប្ដូរប្រាក់ជាមធ្យមនៅពេលនោះ គឺប្រហែលជា ៣.៨០០រៀល ក្នុង១ដុល្លារ។ ឧបករណ៍នេសាទដែលតែងតែយកមកប្រើប្រាស់គឺពុំបានទិញយកមកពីទីផ្សារទេ គឺតែងតែច្នៃប្រឌិតបង្កើតឡើងដោយអ្នកនេសាទផ្ទាល់តែម្ដង។ ក្នុងករណីដូចនេះ ពេលវេលាដែលបានប្រើប្រាស់សម្រាប់ប្រមូលយកព័ត៌មានពីមូលដ្ឋាន និងការកែច្នៃវាក៏ដូចជាការរៀបចំសាងសង់ឧបករណ៍ត្រូវបានប៉ាន់ប្រមាណតម្លៃ និងគណនាទៅតាមតម្លៃពលកម្មជាអតិបរមានៅនឹងទីកន្លែងផលិត( ប្រហែលជា២៥០០ ទៅ៤០០០រៀល ក្នុងមួយថ្ងៃ )។

### ៥. ទិដ្ឋភាពយេនឌ័រ

ការប្រមូលផ្ដុំព័ត៌មានឧបករណ៍នេសាទផ្ដល់នូវកម្មវិធីដ៏ល្អដល់ការងារស្រាវជ្រាវអំពីការចូលរួមពិតប្រាកដរបស់បុរស និងស្ត្រីនៅក្នុងវិស័យជលផល។ វាក៏បង្ហាញឱ្យដឹងផងដែរពីប្រភេទឧបករណ៍នេសាទខុសៗគ្នាដែលបានប្រើប្រាស់ដោយស្ត្រី និងឬក្រុមក្មេងជំទង់។

### ៦. ដ្យាក្រាមនៃការប្រើប្រាស់រដូវកាលនៅតាមតំបន់នេសាទសំខាន់ៗ

“ ការប្រើប្រាស់ពេលវេលា និងទីកន្លែង ” ដ្យាក្រាមបង្ហាញឱ្យឃើញពីការប្រើប្រាស់តាមរដូវកាល និងភូមិសាស្ត្ររបស់ឧបករណ៍នេសាទនីមួយៗ។ ខ្សែកោងបង្ហាញពីវដ្ដនៃទឹកជំនន់មធ្យមប្រចាំឆ្នាំដែលមានកម្រិតអតិបរមានៅក្នុងខែមេសា និងខែឧសភា និងកម្រិតអប្បបរមានៅក្នុងខែកញ្ញា និងខែតុលា។ តំបន់ទាំងបួននៅក្នុងដ្យាក្រាមគឺ៖

១. “បឹងទន្លេសាប ដៃរបស់វា និងតំបន់លិចទឹកនៅជុំវិញ” តំបន់នេសាទសំខាន់ៗធំជាងគេរបស់ប្រទេសរួមមាននៅតាមខេត្តបាត់តំបង ខេត្តពោធិ៍សាត់ ខេត្តសៀមរាប និងខេត្តកំពង់ធំ

២. “ទន្លេសាប និងវាលទំនាបលិចទឹកជុំវិញទន្លេសាប” ជាផ្លូវចរាចរត្រីសំខាន់ និងធំជាងគេបំផុតសម្រាប់ប្រភេទត្រីស គឺមានគ្របដណ្ដប់លើខេត្តកំពង់ឆ្នាំង ភាគខ្លះនៃខេត្តកណ្ដាល និងរាជធានីភ្នំពេញតាមដងទន្លេសាប

៣. “តំបន់វាលទំនាបមេគង្គ បាសាក់” ខេត្តតាកែវ ខេត្តកណ្ដាល ខេត្តព្រៃវែង និងខេត្តកំពង់ចាម ជាទីកន្លែងដែលទឹកជំនន់ស្រកយឺតជាងតំបន់វាលទំនាបប៉ែកខាងជើងរាជធានីភ្នំពេញ( ឧ.អាងទន្លេសាប )

៤. “មេគង្គលើ និងដៃរបស់វា ស្ថានភាពទន្លេតំបន់ប៉ែកខាងលើភាគច្រើនជាកន្លែងពងកូនដ៏សំខាន់សម្រាប់ពពួកត្រីសជាច្រើនប្រភេទ និងជាកន្លែងដែលមានតំបន់លិចទឹកតិចនៅតាមខេត្តក្រចេះ និងខេត្តស្ទឹង-ត្រែង

### ៦. ប្រភេទគោលដៅ

ឧបករណ៍នេសាទភាគច្រើនប្រើប្រាស់សម្រាប់ចាប់ត្រីទៅតាមប្រភេទច្បាស់លាស់ដែលវាបានឆ្លុះបញ្ចាំងឱ្យឃើញទៅតាមឈ្មោះរបស់ឧបករណ៍នោះ។ ប៉ុន្តែឧបករណ៍នេសាទភាគច្រើនផ្ដោតទៅលើជម្រើសនៃការចាប់ទូលំទូលាយដូចជា៖ ប្រភេទត្រីរស់នៅស្រទាប់លើ( ផ្លាស់ទី ) ឬ ប្រភេទត្រីរស់នៅស្រទាប់ក្រោម។ ឧបករណ៍នេសាទមួយចំនួនតូចដូចជាឧប-ករណ៍របាំង ឬ ប្រភេទអួសទាញ គឺជាប្រភេទឧបករណ៍ចាប់គ្មានកំណត់ប្រភេទឡើយ។ ជាទូទៅ ភាគច្រើនរួមមានតែជាង១០ប្រភេទដែលត្រូវបានកត់ត្រាទុក ក្រៅពីនេះអាចមានប្រភេទត្រីច្រើនទៀតដែលចាប់បានដោយឧបករណ៍ទាំងនោះ។

ឈ្មោះត្រីជាភាសាខ្មែរដែលបានដាក់នៅក្នុងសៀវភៅរ៉េនបូត“Rainboth”( ១៩៩៦ )បានប្រើជាគំរូសម្រាប់ការហៅ។

### ៧. ទិដ្ឋភាពផ្លូវច្បាប់

ការតាក់តែងឧបករណ៍នេសាទដែលមានកំណត់នៅក្នុងច្បាប់ជលផលក៏បានកត់សម្គាល់នៅក្នុងផ្នែកនេះដែរ។ តែទន្ទឹមនឹងនេះមាន ឧបករណ៍នេសាទទឹកសាបភាគច្រើននៅកម្ពុជាពុំបានចែងក្នុងច្បាប់ជលផលឡើយ។ នៅពេលបោះពុម្ពនេះ ច្បាប់ជលផលក៏ត្រូវបានរៀបចំកែសម្រួលផងដែរ។

# ផែនទីនៃប្រទេសកម្ពុជា

## ទន្លេ និងខេត្ត ក្រុងសំខាន់ៗនៅប្រទេសកម្ពុជា




សញ្ញាសំគាល់ :

- ● ទីរួមខេត្ត
- ● រាជធានី
- ព្រំដែនប្រទេស
- ទន្លេ
- ផ្ទៃទន្លេ បឹង ស្ទឹង
- តំបន់លិចទឹក

២៥ 0 ២៥ ៥០ ៧៥ ១០០ គីឡូម៉ែត្រ

**Disclaimer:**

While every care is taken to ensure the accuracy of the data used on this map, the Mekong River Commission and the Governments of the Kingdom of Cambodia, the Lao People's Democratic Republic, the Kingdom of Thailand and the Socialist Republic of Viet Nam make no representations or warranties about this accuracy, reliability, completeness or suitability for any particular purpose and disclaims all responsibility and all liability (including without limitation, liability in negligence) for all expenses, losses, damages (including direct or consequential damage) and costs which may be incurred as a result of the data being inaccurate or incomplete in any way and for any reason.

© Mekong River Commission 2003
Not for commercial distribution or re-sale. All reproductions of this map, however, altered, reformatted or redisplayed, shall be bear the following notice: © Mekong River Commission 2003.

# ឡូតិ៍នេសាទ នៅប្រទេសកម្ពុជា




**សញ្ញាសំគាល់ :**

- ផ្ទៃដែនឡូតិ៍នេសាទ
- ដែនឡូតិ៍ដែលប្រគល់ជូនរាស្ត្រ
- ដែននេសាទបំរុងទុក
- ព្រំប្រទល់ប្រទេស
- ព្រំប្រទល់ខេត្ត
- ទន្លេសំខាន់ៗ
- តំបន់ព្រៃលិចទឹក
- រាជធានី
- ទីរួមខេត្ត

១០ ០ ១០ ២០ គីឡូម៉ែត្រ

**Sources :** [1] Department of Fisheries provided the fishing lot dataset (updated version of 2001).
[2] Inundated area was derived from RADARSAT images acqired in September 2000.

**Disclaimer:**

While every care is taken to ensure the accuracy of the data used on this map, the Mekong River Commission and the Governments of the Kingdom of Cambodia, the Lao People's Democratic Republic, the Kingdom of Thailand and the Socialist Republic of Viet Nam make no representations or warranties about this accuracy, reliability, completeness or suitability for any particular purpose and disclaims all responsibility and all liability (including without limitation, liability in negligence) for all expenses, losses, damages (including direct or consequential damage) and costs which may be incurred as a result of the data being inaccurate or incomplete in any way and for any reason.

© Mekong River Commission 2003
Not for commercial distribution or re-sale. All reproductions of this map, however, altered, reformatted or redisplayed, shall be bear the following notice: © Mekong River Commission 2003.

សូមរង់ចាំអានបន្តនៅទស្សនាវដ្ដីកសិកម្មលេខ ៨០



# ការកែច្នៃដើមឬស្សីនៅខេត្តមណ្ឌលគិរី

ដោយ៖ នាយកដ្ឋានឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ





ការកាត់តម្រឹមដើមឬស្សីជាកង់ៗទៅតាមខ្នាតនីមួយៗ

បច្ចុប្បន្ននៅខេត្តមណ្ឌលគិរីមានក្រុមហ៊ុនកែច្នៃឬស្សីមួយឈ្មោះថាក្រុមហ៊ុន បាមប៊ូសា គ្លូបិល វេនឈ័រ (BAMBUSA GLOBAL VENTURES Co., Ltd) មានលោក Richard DANSEY ជនជាតិ New Zealand ជាប្រធានក្រុមប្រឹក្សាភិបាល ដែលជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត បានដាក់ទុនវិនិយោគ និងចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនៅឆ្នាំ២០១២។

ក្រុមហ៊ុនបានទទួលការអនុញ្ញាតឱ្យបង្កើតរោងសិប្បកម្មកែច្នៃដើមឬស្សីចំនួន១កន្លែង ស្ថិតនៅក្នុងភូមិសាស្រ្តភូមិអន្ទ្រេះ ឃុំអរបួនលើ ស្រុកកោះញែក ខេត្តមណ្ឌលគិរី និងបានប្រមូលទិញដើមឬស្សីពីប្រជាពលរដ្ឋរស់នៅក្នុងភូមិសាស្រ្តនេះ ដោយបានកែច្នៃជាផលិតផលរួមមាន៖ សសរ ជញ្ជាំងផ្ទះ គ្រែ បំពង់តដ្ឋខ្យល់ ប្រអប់សាប៊ូ ស្រោមអំពូលភ្លើង ប្រដាប់បំពងសម្លេង (Speaker) ប្រដាប់ទ្រ Menu ឬរូបថត (Easels) ទ្រនាប់ឆ្នាំង (Sushi Hotplate Mat) ប្រដាប់ដាក់ផ្លែឈើ (Peach & Aple Box) ជណ្តើរ (Ladder Screen) ទ្រនាប់ងូតទឹក (Bath Mat, Slat) ជាដើម។ ទន្ទឹមនឹងនេះ ក្រុមហ៊ុនបានទទួលគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលឱ្យធ្វើការនាំចេញផលិតផលឬស្សីកែច្នៃចំនួន ១០០.០០០គ្រឿងទៅបរទេសនៅក្នុងឆ្នាំ២០១៨ និងបានធ្វើការនាំចេញផលិតផលឬស្សីកែច្នៃខាងលើនេះ ចំនួន០៥លើក សរុបចំនួន ៤ ៥៩០ គ្រឿង ទៅកាន់ប្រទេសអ៊ីស្រាអែល។

ការកែច្នៃដើមឬស្សីត្រូវបានធ្វើឡើងតាមដំណាក់កាលដូចខាងក្រោម៖

### ក. ដំណាក់កាលទី១ (ការសម្អាត)

- ការកាត់តម្រឹម(កាត់ជាកង់ៗ) ទៅតាមខ្នាតនៃតម្រូវការ ដោយប្រើប្រាស់ឧបករណ៍រណារដៃ រណារថាស ម៉ាស៊ីនកាត់តម្រឹម ឬម៉ូទ័រកាត់

- ការពត់តម្រង់ដោយប្រើប្រាស់ឧបករណ៍ ចំពោះដើមឬស្សីដែលមានលក្ខណៈវៀចកោងត្រូវធ្វើការពត់តម្រង់ ដោយកម្តៅ ដើមឬស្សីត្រូវការរោលភ្លើងដែលប្រើប្រាស់ថាមពលពីការដុតកម្ទេចកាកសំណល់ឬស្សី អុស ឬឧស្ម័ន នៅសីតុណ្ហភាពប្រមាណពី ៣០C°-៥០C° និងប្រើរយៈពេលប្រមាណពី ៣០ នាទី ទៅ៥ម៉ោង (អាស្រ័យទៅតាមប្រភេទទំហំ កម្រាស់សាច់ និងកម្រិតសំណើមនៃដើមឬស្សី) និងចងពត់ទាញដោយខ្សែ ឬ ប្រវាក់ដើម្បីទាញពត់ឱ្យដើមឬស្សីស្របទៅតាមទម្រង់នៃតម្រូវការ



ការពត់តម្រង់ដើមឫស្សីដែលវៀចកោងដោយប្រើកម្ដៅ

**ការរំលីងដុល (មុនពេលពុះបំបែក)៖** ការរំលីងធ្វើឡើងដោយប្រើប្រាស់ឧបករណ៍ដូចជាកាំបិត ម៉ាស៊ីនរំលីង ឬម៉ូទ័រខាត់រំលីង។ល។



ការរំលីងដុលមុនពេលពុះបំបែកដើមឫស្សី

**ខ. ដំណាក់កាលទី២ (ការពុះច្រៀក និងខាត់រំលីង)**

ការពុះច្រៀក ឬពុះបំបែកគឺត្រូវប្រើប្រាស់ឧបករណ៍ កាំបិត ពូថៅ ម៉ាស៊ីនពុះច្រៀក(បំបែក) ឬម៉ូទ័រពុះបំបែក



ការពុះច្រៀកដើមឫស្សីដោយម៉ូទ័រពុះបំបែក

ការកោស ឬខាត់រំលីងក្រោយពេលពុះបំបែក ឬជាបន្ទះ គឺធ្វើឡើងដោយប្រើប្រាស់ឧបករណ៍ដូចជា កាំបិត ក្រដាសខាត់ ម៉ាស៊ីនខាត់រំលីង ឬម៉ូទ័រខាត់រំលីង។ល។ ផលិតផលត្រូវខាត់រំលីងរហូតដល់សាច់ឫស្សីមានសភាពម៉ដ្ឋល្អ។




ការខាត់រំលីងដើមឫស្សីដោយម៉ាស៊ីនខាត់រំលីង

**គ. ដំណាក់កាលទី៣ (ការពង្រឹងគុណភាព)**

ដើម្បីរក្សា ឬបង្កើនគុណភាពនៃផលិតផល ចាំបាច់ត្រូវធ្វើការថែរក្សាការពារផលប៉ះពាល់ពីមជ្ឈដ្ឋាននានាដោយអនុវត្តតាមវិធីសាស្ត្រជាលក្ខណៈប្រពៃណី (បែបធម្មជាតិ) និងបច្ចេក-វិទ្យា៖

❖ **លក្ខណៈប្រពៃណី (បែបធម្មជាតិ)**

**ការត្រាំទឹក៖** ដើមឫស្សីដែលបានប្រមូលផ្ដុំរួចហើយត្រូវយកទៅត្រាំក្នុងទឹក(ទឹកអូរ ស្ទឹង បឹង ត្រពាំង ស្រែ ថ្លុក...) រយៈពេលពី ១៥ថ្ងៃ-៣០ថ្ងៃ (ប្រសិនបើត្រាំទឹកទុកបានយូរនោះកាន់តែប្រសើរ) បន្ទាប់មកត្រូវធ្វើការលាងសម្អាតឱ្យស្អាតរួចដាក់ហាលថ្ងៃ (ក្រោមកម្ដៅថ្ងៃ ឬទីវាលដែលមានពន្លឺ កម្ដៅ និងខ្យល់គ្រប់គ្រាន់) និងត្រូវប្រើរយៈពេលសមស្របរហូតដល់កម្រិតសំណើមត្រឹមប្រមាណពី ១៥%-២៥% ហើយត្រូវរក្សាទុករហូតអស់ក្លិនមិនល្អ។

**ការរោល ឬឆ្អើរផ្សែងភ្លើង៖** ចំពោះដើមឫស្សីដែលមានទម្រង់វៀច កោងត្រូវយកទៅរោល ឬឆ្អើរផ្សែងភ្លើង ដោយប្រើរយៈពេលសមស្របរហូតដល់កម្រិតសំណើមប្រមាណពី១៥%-២៥%។ ភ្នក់ភ្លើងប្រើសម្រាប់ការរោល ឬឆ្អើរដើមឫស្សីគប្បីប្រើប្រាស់នូវសំរាម ឬកាកសំណល់ដែលអាចផ្ដល់នូវផ្សែងច្រើន។ ផ្សែងភ្លើងអាចជួយកាត់បន្ថយការពុកផុយ និងការយាយីពីសត្វល្អិតចង្រៃ។



*ការរោលផ្ទើរផ្សែងភ្លើងដល់ដើមឫស្សី*

**អត្ថប្រយោជន៍ ៖** ការអនុវត្តនូវវិធីសាស្ត្រខាងលើនឹងអាចជួយថែរក្សាគុណភាពដើមឫស្សី ដោយការកាត់បន្ថយពេលវេលានៃការពុកផុយ បែកប្រេះ ព្រមទាំងអាចទប់ទល់នូវការគំរាមកំហែងពីប្រភេទសត្វល្អិតចង្រៃជាដើម។

**ផលវិបាក៖** ការអនុវត្តនូវវិធីសាស្ត្រខាងលើនៅក្នុងដំណាក់កាលនៃការកែច្នៃអាចទទួលនូវក្លិនមិនល្អពីការត្រាំទឹក ឬ ក្លិនផ្សែងភ្លើង។ល។

### ❖ ការភ្នោក ( ប្រើប្រាស់សារធាតុគីមី )

**ការរៀបចំមុនពេលភ្នោក៖** មុននឹងធ្វើការភ្នោក ដើមឫស្សីត្រូវពុះបំបែកជាពីរ ឬជាច្រើនចំរៀកទៅតាមតម្រូវការ។ ចំពោះដើមឫស្សីដែលមានបំណងរក្សាទម្រង់មូលដដែល ចាំបាច់ត្រូវធ្វើការទម្លុះថ្នាំងនីមួយៗ ដើម្បីឱ្យល្បាយសារធាតុ បានឆ្លងកាត់ និងជ្រាបចូលក្នុងសាច់ឫស្សី បន្ទាប់មកត្រូវតម្រៀបដើមឫស្សីទាំងនោះតាមលំដាប់លំដោយ និងចងរឹតឱ្យតឹង រួចដាក់បញ្ចូលទៅក្នុងធុងចំហុយដែលមានល្បាយសារធាតុគីមី Copper Chrome Asenated(CCA) $As_2CrCuO_9$។





ដើមឫស្សីដែលរៀបចំមុនពេលភ្នោក

**របៀបលាយសារធាតុគីមី៖** ក្នុងសារធាតុគីមី CCA ($As_2$ -$CrCuO_2$ ) ចំនួន 120kgs ត្រូវលាយជាមួយទឹក $H_2O$ ចំនួន ១០.០០០លីត្រ។

**រយៈពេលនៃការភ្នោក៖** ការភ្នោកសារធាតុគីមីដោយការ ធ្វើប្រព្រឹត្តិកម្មត្រូវប្រើប្រាស់រយៈពេលពី ២ម៉ោង-៤ម៉ោង។ រយៈពេលនៃការភ្នោកគឺអាស្រ័យទៅតាមទំហំ និងកម្រាស់នៃសាច់ឫស្សី។

**អត្ថប្រយោជន៍៖** ការភ្នោកផលិតផលដើមឫស្សីដោយប្រើ ប្រាស់សារធាតុគីមីនឹងអាចជួយដល់ការការពារ និងការកាត់បន្ថយផលប៉ះពាល់នៃបរិយាកាសខាងក្រៅ ពោលគឺកាត់បន្ថយការបែកប្រេះ ពុកផុយ រក្សាពណ៌ដើមបានយូរ និងការកាត់បន្ថយការបំផ្លិចបំផ្លាញនៃសត្វល្អិតចង្រៃ ព្រមទាំងជួយរក្សាគុណភាពនៃផលិតផលដើមឫស្សី។

**ការហាមឃាត់៖** ក្រៅពីទទួលបានអត្ថប្រយោជន៍ខាងលើ សារធាតុគីមីនេះត្រូវបានហាមឃាត់ចំពោះការប្រើប្រាស់លើឧបករណ៍សម្ភារសម្រាប់ដាក់ចំណីអាហារដូចជា បំពង់ទឹកចង្កឹះ ចាន វែក ស្លាបព្រា កញ្ជើ ល្អី។ល។

### ឃ. ដំណាក់កាលទី៤( ការសម្ងួត )

ការសម្ងួតធ្វើឡើងជាលក្ខណៈធម្មជាតិដោយហាលថ្ងៃ ឬរក្សាទុកក្នុងរោងដែលមានកម្ដៅ ពន្លឺ និងខ្យល់គ្រប់គ្រាន់។ ការសម្ងួតនេះប្រព្រឹត្តទៅរហូតដល់សំណើមមានកម្រិតប្រមាណពី១០%-២៥%។





ការសម្ងួតដើមឫស្សីដោយទុកក្នុងរោង ឬហាលថ្ងៃ

ង. ដំណាក់កាលទី៥ (ការផលិតផលិតផល)

ដើមឫស្សីជាវត្ថុធាតុដើមប្រើប្រាស់ សម្រាប់សំណង់ ផលិតជា ឧបករណ៍កសិកម្ម ឧបករណ៍នេសាទ ឧបករណ៍ផ្ទះបាយ ឧបករណ៍ប្រើប្រាស់ប្រចាំថ្ងៃ គ្រឿងសង្ហារិម និងគ្រឿងតុបតែងលម្អ។ល។

ក្រោយពីការសម្អាត ការពត់តម្រង់ ការពុះច្រៀក ការខាត់រំលីង ការប្រើប្រាស់លក្ខណៈប្រពៃណី ការភ្នោក សារធាតុគីមី CCA និងការសម្ងួតរួចមក ដើមឫស្សីត្រូវបានយកទៅធ្វើការកែច្នៃជាផលិតផលដូចខាងក្រោម៖

សសរដើមឫស្សី៖ គល់ឫស្សីចាស់(មានខ្លឹម) ត្រូវបានកាត់តម្រឹមប្រវែងពី ៣.៥ម-៤.៥ម រួចចោះឆ្វៀលចុងម្ខាងនៃកំណាត់ដើមឫស្សីនោះប្រវែង ៤ស.ម និងចោះជាដំណាប់សម្រាប់ទ្រពន្លួញនៃកំណាត់ដើមឫស្សី ឬឈើ...។

បំពង់ឥដ្ឋខ្យល់៖ ដើមឫស្សីត្រូវបានកាត់ជាកង់ៗ ប្រវែង ១០ស.ម-២០ស.ម សម្រាប់ប្រើជំនួសឥដ្ឋខ្យល់ ឬឥដ្ឋប្រហោង។ សារធាតុសរសៃនៃដើមឫស្សីមានលក្ខណៈ រឹងមាំក្នុងការប្រើប្រាស់ជាមួយស៊ីម៉ង់ត៍។



ដើមឫស្សីដែលកាត់ជាកង់ៗប្រើជំនួសឥដ្ឋខ្យល់

ការផលិតប្រអប់សាប៊ូ៖ ដើមឫស្សីដែលមានទំហំអង្កត់ផ្ចិតពី០.៧ស.ម-១០ស.ម ត្រូវបានកាត់ជាកង់ៗប្រវែង១២-ស.ម-១៥ស.ម រួចពុះជាពីរផ្នែកដោយផ្នែកទី១ មានទំហំស្មើនឹង ១/៣ នៃបរិមាត្រកំណាត់ដើមឫស្សី ហើយផ្នែកដែលនៅសល់ត្រូវបានយកទៅចោះឆ្វៀលផ្ទៃបាតទំហំស្មើនឹង ៣/៤ សម្រាប់ដាក់ដែក ឬឧបករណ៍សម្រាប់ទ្រដុំសាប៊ូ ហើយត្រូវរក្សាទុកនូវសាច់ឫស្សីផ្នែកផ្ទៃបាតស្មើនឹង ៣/៤ប៉ុណ្ណោះ បន្ទាប់មកធ្វើការសម្អាតខាត់រំលីង លាបថ្នាំរលោង ឬរក្សាភាពដើមទៅតាមតម្រូវការ។ ចំពោះមាឌ ឬទំហំនៃផលិតផលប្រអប់សាប៊ូអាចជ្រើសរើស និងកែច្នៃទៅតាមសេចក្តីត្រូវការ។



កំណាត់ដើមឫស្សីធ្វើជាប្រអប់សាប៊ូ

ការផលិតស្រោមអំពូលម៉ែត្រ៖ ដើមឫស្សីដែលមានទំហំអង្កត់ផ្ចិតពី ៨ស.ម-១១ស.ម ត្រូវបានកាត់ជាកង់ៗប្រវែង ៧០ស.ម-១៤០ស.ម អាស្រ័យទៅតាមខ្នាតរបស់អំពូលភ្លើង រួចចោះប្រហោងចំនួន ៣ ឬ៤នៅផ្នែកខាងក្រោមដែលប្រហោងនីមួយៗមានទំហំ ៤ស.ម - ៦ស.ម រីឯប្រហោងចំណុចកណ្តាលមានប្រវែងសមស្របទៅនឹងអំពូលដែលត្រូវបំពាក់។ ប្រហោងទាំងនេះរក្សាទុកដើម្បីឱ្យពន្លឺជះចេញមកក្រៅ និងសម្រាប់តខ្សែចរន្តអគ្គិសនី។



កំណាត់ដើមឫស្សីធ្វើជាប្រអប់អំពូលភ្លើងអគ្គិសនី

**ការផលិតជញ្ជាំង៖** ដើមឫស្សីត្រូវបានកាត់ជាកំណាត់ៗ រួចពុះច្រៀកជាពីរបន្ទះ ឬច្រើនទៅតាមខ្នាតនៃតម្រូវការប្រើប្រាស់ បន្ទាប់មកត្រូវធ្វើការឈូសកោស ឬខាត់រំលីងដោយឧបករណ៍ប្រើប្រាស់ដោយដៃ ឬដោយម៉ាស៊ីន ហើយត្រូវធ្វើការតភ្ជាប់ ឬផ្គុំដំឡើងជាជញ្ជាំងផ្ទះ ជញ្ជាំងបន្ទប់ ជញ្ជាំង របងជាដើម ដោយសម្ភារដូចជា ដែកគោលឫស្សី ដែកគោលឈើ ដែកគោលដែក ឬដោយចំណងផ្សេងៗ។



ដើមឫស្សីដែលពុះច្រៀកសម្រាប់ធ្វើជារបង ឬជញ្ជាំង



ដើមឫស្សីដែលបានធ្វើជារបងផ្ទះ

- ការផលិតជាគ្រឿងសំណង់៖ ដើមឫស្សីត្រូវបានយកទៅប្រើប្រាស់សម្រាប់ការសាងសង់សំណង់នានា ដូចជា លំនៅដ្ឋានជាដើម។ ដើមឫស្សីត្រូវបានកាត់ជាកំណាត់ៗ រួចពុះច្រៀកជាបន្ទះទៅតាមមុខងារនៃគ្រឿងសំណង់រួមមាន៖ ខ្នាតជាសសរ ផ្ទោង ផ្លាន ឃ្នាបដៃរណែង មេជញ្ជាំង ជញ្ជាំង និងដំបូល។ល។ បន្ទាប់ពីការកាត់តម្រឹម ឈូសសម្អាត កោស ឬខាត់រំលីងរួចមក ដើមឫស្សីត្រូវបានផ្គុំដំឡើងជារូបរាងសំណង់ សម្រាប់បម្រើសេចក្តីត្រូវការ។





សំណង់ផ្សេងៗដែលប្រើដោយដើមឫស្សី

**ការផលិតជាសម្ភារ និងឧបករណ៍ប្រើប្រាស់ផ្សេងៗ ៖**

- ដើមឫស្សីព្រៃចត្រូវបានយកកែច្នៃជារនាំង ឬវាំងននដែលជាទីទាក់ទាញសម្រាប់ការប្រើប្រាស់ក្នុងផ្ទះ សណ្ឋាគារ ភោជនីយដ្ឋាន និងសម្រាប់ដាក់តាំងលម្អនៅកន្លែងសំខាន់ៗនានា។ ផលិតផលកែច្នៃពីដើមឫស្សីព្រៃចពុំសូវឃើញមាននៅលើទីផ្សារឡើយ។ ដើមឫស្សីព្រៃចត្រូវបានកែច្នៃដោយធ្វើការកាត់តម្រឹម លួសរំលីងដើម និងថ្នាំងដោយប្រុងប្រយ័ត្ន ចៀសវាងការបែក ឬបាក់ចំណុចពក និងមែកនៃថ្នាំងនីមួយៗដែលប្រើប្រាស់កូនកាំបិត ពន្លាក ឬឧបករណ៍ ឆ្កឹះរំលីងប្រកបដោយ

ទេពកោសល្យ។ ទីបញ្ចប់នៃផលិតកម្ម គឺផលិតផលត្រូវបានធ្វើការលាបថ្នាំរលោង (Varnish)។



ផលិតផលធ្វើពីដើមឫស្សីព្រេច

☑ ដើមឫស្សី(ព្រៃ) ត្រូវបានកែច្នៃជាប្រដាប់បំពងសម្លេង (Speaker)។ ការកែច្នៃផលិតផលនេះគឺត្រូវយកដើមឫស្សីដែលមានទំហំអង្កត់ផ្ចិតចាប់ពី ៨ស.ម ឡើងធ្វើការកាត់ជាកំណាត់មានប្រវែងពី ៣០ស.ម រួចហើយត្រូវធ្វើការកាត់បញ្ឆិតផ្នែកលើខាងមុខមកចុងនៃកំណាត់ឫស្សីស្ថិតក្នុងមុំ ៦០° (មុំ៦០ អង្សា)។ ចំណែកឯនៅផ្នែកមុខនៃថ្នាំងឫស្សីចម្ងាយប្រមាណ ២ស.ម ត្រូវចោះប្រហោងទំហំ ២ស.ម កាត់ទទឹងពេញទំហំផ្នែកខាងលើនៃកំណាត់ឫស្សីនោះ។ នៅផ្នែកចំហៀងត្រូវចោះប្រហោងសងខាង ដែលប្រហោងនីមួយៗមានទំហំ១ស.ម និងមានប្រវែង១២ស.ម។ ចំពោះដើមឫស្សីដែលត្រូវជ្រើសរើសយកធ្វើការកែច្នៃ គឺជាឫស្សី ដែលមានសាច់លះ និងថ្នាំងល្អ (សាច់ល្អ ថ្នាំងល្អ)។ ប្រដាប់បំពងសម្លេង (Speaker) អាចបំពងសម្លេងបានល្អនៅក្នុងបន្ទប់ដែលមានទំហំ ៣ម x ៤ម។

ដើមឫស្សី (ឫស្សីព្រេច) ក៏អាចកែច្នៃជាចង្កឹះ សម្បកដៃខ្មៅ សម្បកប៊ិច បំពង់ដាក់សម្ភារសិក្សា ឬការិយាល័យ និងចង្កឹះផងដែរ... (ឫស្សីព្រៃ)។





កំណាត់ដើមឫស្សីព្រៃធ្វើជាប្រដាប់បំពងសម្លេង (Speaker)





# ចំណេះដឹងស្តីអំពី សុខភាពសត្វ

រៀបចំដោយ៖
អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ

បន្តពីទស្សនាវដ្តីកសិកម្មប្រចាំត្រីមាសទី២ ឆ្នាំ២០២១ លេខ៧៨

- ហើមត្របកភ្នែកជាការសម្គាល់របស់ជំងឺហើម។

**ការពិនិត្យលើស្បែក**

- ដើម្បីកំណត់បានការចេញឈាមក្រោមស្បែក (អាចជាជំងឺប៉េស្តជ្រូក)
- មានពណ៌ក្រហម និងលេចចេញចំណុចប្ញូនជ្រុង អាចជាជំងឺកញ្ជ្រិល
- ស្នាមអុច និងក្រម៉ រ អាចអង្គែ......។




**ការពិនិត្យលើច្រមុះ**

ដើម្បីមើលការហៀរសំបោរ ឈាម ឬ ខ្ទុះ ចំពោះជំងឺផ្លូវដង្ហើមធ្ងន់ធ្ងរ និងពងដោរ ចំពោះជំងឺអុតក្តាម(FMD)។




ឈាម(ជំងឺអាក់ទីណូបាក់ស៊ីលុស)

**ការពិនិត្យលើយោនី និងកម្រាលទ្រុង ដើម្បីកំណត់៖**

- ការហូរសារធាតុរាវ ចេញពីយោនី នៅជាសញ្ញារលាកផ្លោកនោម ឬ រលាកស្បូន
- ការហើមយោនីជាសញ្ញានៃការរកឈ្មោល។




**ការពិនិត្យលើកន្សោមដោះ**

មានភាពងាយស្រួល ពេលមេជ្រូកស្ថិតនៅក្នុងទ្រុងកើតកូន។ ការពិនិត្យនេះដើម្បីរកជំងឺរលាកស្បូន លាសដោះ និងអត់ទឹកដោះ(MMA)ឬជំងឺលាសដោះ ឬស្នាមរបួសលើកក្បាលដោះ។




គ្មានទឹកដោះបន្ទាប់ពីកើតកូន បញ្ហារលាកស្បូន លាសដោះ និងអត់ទឹកដោះ

**ការពិនិត្យលិង្គ និងពងស្វាស ជ្រូកបា៖**

- រកមើលមុខរបួស ឬ ការឆ្លងមេរោគផ្សេងៗ
- ពិនិត្យមើលពងស្វាសទន់ មិនស្អិតជាប់ និងមានទំហំប៉ុនៗគ្នា។



ពងស្វាសលូតលាស់មិនបានល្អ

☞ ការពិនិត្យលើរន្ធលាមក អាចឱ្យយើង៖

- កំណត់ថា ជ្រូកមួយណារាគ
- ឃើញលៀនក្រសាលគូថចេញមកក្រៅ។



**ការពិនិត្យលើជើង៖** ពេលមេជ្រូកដេកអាចឱ្យយើងសង្កេតទៅលើក្រចក៖

- ដើម្បីមើលស្លាកស្នាមដំបៅ ជើងធូន់ធូរ
- ដើម្បីមើលស្លាកស្នាមនៃជំងឺអុតក្ដាម។



**៣. ការចាប់ជ្រូក**

**កូនជ្រូក៖** នៅក្នុងទ្រុងត្រូវចាប់កាន់ជើងក្រោយដើម្បីដាក់កន្លែងផ្សេងសម្រាប់ចាក់ថ្នាំ គៀវកាត់ធ្មេញ.....។



ការចាប់កូនជ្រូកក្នុងទ្រុង



ការបញ្ចក់ថ្នាំ

☞ **ជ្រូកសាច់៖** ជាទូទៅការចាប់ជ្រូកដោយមិនបានចាប់កាន់ឱ្យបានត្រឹមត្រូវ បណ្ដាលឱ្យការចាក់ថ្នាំខុសទីតាំង និងមិនតាមលក្ខណៈបច្ចេកទេស។ ដើម្បីឱ្យជ្រូកនៅស្ងៀម ដូចនេះត្រូវប្រើប្រដាប់ទាក់ចាប់ជ្រូក។ ប្រដាប់ទាក់ចាប់ជ្រូក អាចជាខ្សែមួយដែលមិនរអិល។ ពេលចាប់ថ្គាមលើជ្រូកថយក្រោយខ្លាំង ហើយបើខ្សែជាប់ស្វិត វាមិនអាចរើទៀតទេ។





ចាប់ជ្រូកទម្ងន់៤០គ.ក្រ ដោយចាប់ត្រចៀក និងកន្ទុយ

**មេជ្រូក៖** ប្រដាប់ទាក់ចាប់ជ្រូក អាចប្រើសម្រាប់ទាក់ចាប់មេជ្រូកផងដែរ ប៉ុន្តែបើមេជ្រូកនៅក្នុងទ្រុងដាច់តែឯង ការអនុវត្តអាចមិនចាំបាច់ចាប់វាទេ។



## គ. គោ

### ១. ការពិនិត្យទូទៅ

ស្ថានភាពដងខ្លួន (រាងកាយ)ស្ថានភាពស្គម អាចជាសញ្ញាកង្វះចំណីជំងឺរ៉ាំរ៉ៃ ឬចម្លងបរាសិត។ សត្វស្គមមិនងាយជាឆាប់រហ័សនោះទេ។ផ្ទុយមកវិញពេលសត្វមានស្ថានភាពរាងកាយល្អ តែវាឈឺត្រូវសង្ស័យទៅលើជំងឺស្រួចស្រាវ។





ទិដ្ឋភាពស្បែក៖

វាជាសញ្ញាសំខាន់ចំពោះគោ ក្របី៖ រោមស្រអាប់ ខូចពណ៌ក្រមរ...កើតឡើងដោយសារកង្វះជាតិវីតាមីន និងសារធាតុរ៉ែ គោ ក្របី ទាំងនេះខ្សោយក្នុង ការទប់ទល់នឹងការឆ្លងជំងឺ។

ប្រតិកម្មចាញ់ពន្លឺថ្ងៃកើតមាន ជាទូទៅក្នុងប្រទេសកម្ពុជា និងងាយស្រួលក្នុងការកំណត់បញ្ហានេះ។




របួសដោយប្រតិកម្មចាញ់ពន្លឺថ្ងៃ



ការធ្វើចលនា(ការដើរ)

ដំបូងត្រូវសង្កេតលើគោក្របី ដែលក្រោកឈរដើម្បីកំណត់ពីភាពខ្សោយរបស់វា។ ឧទាហរណ៍ វាកើតមានដោយសារកង្វះសារធាតុបន្ទាប់ពីកើតកូន ឬឈរមិននឹងបណ្តាលមកពីជំងឺសរសៃប្រសាទ ដូចជាជំងឺពុលដោយការស៊ីចំណីមិនស្អាត(Botulism)។ពេលគោក្របីដើរងាយស្រួលដើម្បីពិនិត្យមើលការខូកជើង៖

សត្វក្រោក ប៉ុន្តែប្រឹងចៃរជើងមួយទៅមួយទៀត មេគោបន្ទន់ខ្លួនចុះនៅប៉ុន្មាននាទីក្រោយមកសត្វមិនអាចទ្រខ្លួនលើកជើងតែម្ខាង។













ការដកដង្ហើម៖

ការដកដង្ហើមជាធម្មតា ចលនាតាមទ្រូង និងពោះដោយធ្វើចលនារួមគ្នា នឹងមានចង្វាក់១០ទៅ២០ដងក្នុងមួយនាទីសម្រាប់សត្វពេញវ័យ។

ពេលសីតុណ្ហភាពក្តៅ ឬពេលមានជំងឺផ្លូវដង្ហើម នោះចង្វាក់ដកដង្ហើមកើន ឡើងយ៉ាងច្បាស់ មាត់សត្វអាចបើក។

ការក្អកងាយស្រួលក្នុងការពិនិត្យឃើញ ពេលសត្វធ្វើចលនា។




លាមក

ការពិនិត្យលាមកអាចផ្តល់ព័ត៌មានដូចជា៖

ពណ៌ពីខ្មៅដូរទៅជាខៀវ អាស្រ័យលើចំណី និងមុខងាររបស់ថ្លើម

- មានឈាម ឬសំបោរដូចជាជំងឺដង្កូវថ្លើម
- រាកបណ្តាលពីស៊ីស្មៅខ្ចីច្រើនពេក ឬមានព្រូន
- ក្ងៀនពេលគោ ក្របីស៊ីមិនគ្រប់គ្រាន់ ពីព្រោះសីតុណ្ហភាពក្តៅ។













២. ការពិនិត្យផ្ទាល់

ពិនិត្យសីតុណ្ហភាព៖

- សត្វពេញវ័យពី ៣៨ ទៅ ៣៩អង្សាសេ
- កូនគោពី ៣៩ ទៅ ៤០អង្សាសេ
- ជាទូទៅសីតុណ្ហភាពខ្ពស់ជាសញ្ញានៃការឆ្លងជំងឺ។



ពិនិត្យលើភ្នែក អាចកំណត់ពី៖

- ការឆ្លងមេរោគលើភ្នាស ស្តើងខាងក្នុងភ្នែកធ្វើឱ្យហូរទឹកភ្នែក
- របួសលើភ្នែកជារឿយៗសត្វបិទភ្នែក
- កំណត់ពណ៌ភ្នាសស្តើងភ្នែក៖ បើភ្នាស់ស្តើងខាងក្នុងភ្នែកស្លេកស្លាំង ជាសញ្ញាកង្វះឈាមក្រហម ច្រើនកើតចំពោះសត្វដែលមានជំងឺដង្កូវថ្លើម។







ពិនិត្យលើមាត់៖

ក្រអូម និងមាត់ត្រូវពិនិត្យជាពិសេសពេលសត្វមានចេញទឹកមាត់ខុសប្រក្រតី វាអាចបណ្តាលមកពីរបួសមុតឈើ ឬដែក ឬស្លាកស្នាមនៅលើអញ្ចាញ និងអណ្តាតដោយសារជំងឺអុតក្តាម។







ពិនិត្យលើស្បែកមានសារៈសំខាន់ដើម្បី៖

- មើលបរាសិតខាងក្រៅដូចជាដង្កែ
- សង្កេតពីក្រម៉រ ដែលអាចបង្ក
- ដោយអង្កែ ឬការដាច់រលាត់
- ការវាយតម្លៃពីដំបៅ។



ការពិនិត្យលើស្បែក




ពិនិត្យជើង៖

ចាំបាច់ត្រូវពិនិត្យបាតជើង ក្រចក និងសន្លាក់ដើម្បីដឹងពីមូលហេតុ ដែលបណ្តាលឱ្យមានបញ្ហាខ្វក់ជើង។


ការពិនិត្យជង្គង់



## ការពិនិត្យលើកន្សោមដោះ និងទឹកដោះ៖

ពេលកូនគោមិនបៅដោះ ឬរាគ ឬលូតលាស់មិនល្អ ចាំបាច់ត្រូវពិនិត្យមើលកន្សោមដោះ

- ដំបូងត្រូវពិនិត្យ បើក្បាលដោះមិនធំពេក ឬមានរាងខុសធម្មតា
- បន្ទាប់មកបសុពេទ្យត្រូវពិនិត្យថា តើកន្សោមដោះរឹង និងមានទឹកដោះចេញធម្មតាឬទេ ដើម្បីវិនិច្ឆ័យលើជំងឺលាសដោះ។


កូនគោមិនអាចបៅក្បាលដោះនេះបាន

## ពិនិត្យលើលិង្គ និងពងស្វាស៖

- លិង្គត្រូវតែមានប្រវែងល្មម គួរលៀនមកស្មើរតែដល់ចន្លោះជើងមុខទាំងពីរ នៅពេលវាមានចំណង់ និងលៀនចេញ។ គោឈ្មោលដែលមានលិង្គខ្លីមិនអាចបង្កាត់ពូជបានទេ។
- ពងស្វាសគួរ តែកម្រើកបានដោយសេរីខាងក្នុងស្បែកស្រោបពង និងមានទំហំប៉ុនគ្នា។



## ពិនិត្យលើរន្ធគូថ

- បច្ចេកទេសនេះមានសារៈសំខាន់ដើម្បីបញ្ជាក់ថា៖ គោផើមរហូតដល់៤ខែ ពីព្រោះស្បូនធ្ងន់ និងធ្លាក់ចុះក្នុងពោះ
- តាមការសិក្សាការពិនិត្យនេះ អាចឱ្យយើងដឹងពីដុំពក( គីស្ត )នៅលើដៃស្បូន។



## ៣. ការចាប់

## ការចាប់កូនគោ

មនុស្សម្នាក់អាចចាប់កូនគោទើបកើតបាន ប៉ុន្តែពេលចាប់កូនគោអាយុពី៦ខែ ត្រូវការមនុស្សពីរនាក់ដើម្បីជួយ។



## ការចាប់គោពេញវ័យ

ជាធម្មតាការចងគោជាប់នឹងដើមឈើ ដើម្បីចាក់ថ្នាំ

មិនមានសុវត្ថិភាព និងមិនងាយស្រួលក្នុងការអនុវត្តលើសត្វទេ។ បច្ចេកទេសនេះអាចប្រើបាន ចំពោះការចាក់ថ្នាំតែមួយម្ជុល ឬការអនុវត្តលឿន។

- ការចាប់ច្រមុះឱ្យសត្វរើបាន ប៉ុន្តែបច្ចេកទេសនេះអាចប្រើបាន ចំពោះតែសត្វដែលស្លូត និងសត្វមិនធំពេកទេ។
- មានវិធីងាយៗ ជាច្រើនត្រូវបានប្រើដើម្បីចាប់សត្វ។ បច្ចេកទេសល្អបំផុត ក្នុងការចាប់គោត្រូវធ្វើសាឡុងដើម្បីងាយស្រួលក្នុងការអនុវត្ត និងមានសុវត្ថិភាពទាំងសត្វ និងមនុស្ស។



**ការផ្ដួលគោ**

ប្រើខ្សែប្រវែងប្រហែល១០ម៉ែត្រដើម្បីផ្ដួលគោពេញវ័យឱ្យដួលដោយសុវត្ថិភាព និងគ្មានស្ត្រេស។



## នីតិវិធីនៃការអនុវត្ត ការជួយសង្គ្រោះ និងការក្រៀវ

### ក. មាន់

### ១. ការប្រើប្រាស់បសុឱសថ

#### ១.១ ការបន្តក់ភ្នែក៖

ច្រើនធ្វើពេលបន្តក់វ៉ាក់សាំង។ ជាការប្រសើរត្រូវប្រើទឹកលាយ ដែលមានពណ៌ ដើម្បីមើលឃើញច្បាស់នូវតំណក់វ៉ាក់សាំង បានចូលក្នុងភ្នែកកូនមាន់។




*ការធ្វើវ៉ាក់សាំងញកាសចំពោះកូនមាន់ អាយុ១ថ្ងៃ*

#### ១.២ ការចាក់ថ្នាំ៖

- ប្រើសម្រាប់ចាក់វ៉ាក់សាំង ឬថ្នាំផ្សេងៗ ដូចជាថ្នាំអង់ទីប៊ីយ៉ូទិក។
- ថ្នាំភាគច្រើនចាក់លើសាច់ដុំទ្រូង
- ថ្នាំមួយចំនួនអាចពុលពេលចាក់លើជើង ព្រោះថ្នាំនឹងចូលទៅផ្ទាល់ក្នុងក្រលៀន។

*ការចាក់ថ្នាំអុកស៊ីតេត*



#### ១.៣ ការជួសស្លាប៖

ចាក់ទម្លុះផ្នែកស្តើងនៃសន្ទះស្លាប ដើម្បីចាក់វ៉ាក់សាំងការពារជំងឺអុតបក្សី។



### ១.៤ ការដាក់ក្នុងទឹក៖

វ៉ាក់សាំង ថ្នាំអង់ទីប៊ីយ៉ូទិក និងវីតាមីន អាចដាក់ក្នុងទឹក។ ដើម្បីប្រាកដថា សត្វទាំងអស់នឹងផឹកថ្នាំបានគ្រប់គ្នា ត្រូវដកស្នូកទឹកចេញ ១ទៅ ២ម៉ោងមុន។ បន្ទាប់មកលាយថ្នាំជាមួយទឹករួចទើបយើងចាប់ផ្ដើមឱ្យវាផឹក ហើយស្របពេលសត្វស្រេកទឹក នោះវានឹងផឹកបានគ្រប់គ្នា។



*ថ្នាំ ឬវ៉ាក់សាំងលាយក្នុងទឹកសម្រាប់ឱ្យមាន់ទាំងអស់ផឹក*

### ១.៥ ការដាក់ក្នុងចំណី៖

ថ្នាំខ្លះមិនរលាយ ឬពេលខ្លះកសិករប្រើថ្នាំសម្រាប់មនុស្សជំនួស ដូច្នេះងាយស្រួលលាយក្នុងចំណី។ ប៉ុន្តែត្រូវដឹងថាមាន់ឈឺនៅបន្តផឹកទឹក តែឈប់ស៊ីចំណី។

### ២. ការវះកាត់

រាល់ការវះកាត់សត្វដែលឈឺ និងងាប់ អាចធ្វើទៅបានស្ថិតក្រោមការគ្រប់គ្រងរបស់មន្ត្រីបសុពេទ្យ។

ការវះកាត់ពិនិត្យសាកសព ជាការត្រួតពិនិត្យលើសាកសពសត្វ ក្នុងគោលបំណងពិនិត្យមើលស្លាកស្នាមដំបៅរបស់សរីរាង្គដើម្បីជួយក្នុងការធ្វើរោគវិនិច្ឆ័យជំងឺ។ឧ.ចាំបាច់ដើម្បីវះកាត់សាកសពបក្សីគឺកាំបិតមុតស្រួច។បន្ទាប់ពីការវះកាត់រួចសាកសពត្រូវដុត ឬកប់។ ចូរកុំបោះវាចោលពាសវាលពាសកាល ព្រោះវាអាចសាយភាយមេរោគ។

**ការប្រុងប្រយ័ត្ន៖** ជំងឺមាន់មួយចំនួនអាចចម្លងមកមនុស្ស យើងត្រូវតែពាក់ស្រោមដៃផ្លាស្ទិចពេលដំណើរការវះកាតសាកសព និងលាងដៃដោយប្រុងប្រយ័ត្នជាមួយសាប៊ូបន្ទាប់ពីធ្វើការវះកាត់រួច។

ក្នុងករណីសង្ស័យជំងឺផ្ដាសាយបក្សី (អត្រាបក្សីងាប់ខ្ពស់ហើយលឿន) យើងមិនត្រូវធ្វើការវះកាត់សាកសពទេ និងត្រូវផ្ញើរសាកសពមកកាន់វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល។

### ២.១ ការពិនិត្យលើក្បាល៖

ភ្នែក៖ ការហើម ឡើងក្រហមខុសធម្មតា គឺជាសញ្ញាជំងឺផ្លូវដង្ហើម។ ការស្អិតត្របកភ្នែកបានឃើញចំពោះជំងឺគូរីសា (Coryza) និងការហូរទឹកភ្នែកចំពោះជំងឺផ្ដាសាយបក្សី និងជំងឺរលាកទងសួត។ ជំងឺម៉ារិក (Marek) បង្កជាដុំសាច់លើប្រស្រីភ្នែក និងធ្វើឱ្យខ្វាក់ភ្នែក។



*ការហូរទឹកភ្នែកចំពោះមាន់កើតជំងឺផ្ដាសាយបក្សី*

ខាងក្នុងមាត់៖ ខ្ទុះ ឬស្លេះជាសញ្ញាជំងឺផ្លូវដង្ហើមមានដូចជា ជំងឺគូរីសា មីកូផ្លាស្មា អាសន្នរោគ ឬជំងឺរលាកទងសួត។ ការរលាកភ្នាស និងដំបៅ ជាសញ្ញាជំងឺអុតបក្សី។





### ២.២ ការពិនិត្យបំពងក៖

បំពង់ខ្យល់៖ ការកាត់ដើមក និងបំពង់ខ្យល់ ដើម្បីសង្កេតឱ្យបានច្បាស់នូវសញ្ញានៃជំងឺរលាកទងសួត។ ស្លេះលាយឈាមមានលើជំងឺផ្ដាសាយបក្សី រលាកដើមក និងរលាកបំពង់ខ្យល់ និងជំងឺ ញូវកាស(ដង្កោរែក)។ ជាទូទៅឃើញមានព្រួនពណ៌ក្រហម កើតលើមាន់ដែលចិញ្ចឹមលែង។

សូមរងចាំអានបន្តនៅទស្សនាវដ្ដីកសិកម្ម លេខ ៨០

# ការធ្វើឱ្យប្រសើរឡើងនូវបច្ចេកវិទ្យាចិញ្ចឹមដង្កូវនាង និងការផលិតសូត្រចេញពីដង្កូវនាងកូនកាត់ពូជ CK1-7-4

## (Optimization of Cultivation Technology and Production of Silk from Hybridized Silkworm CK1-7-4)"

ដោយលោក ឃិន ច័ន្ទសុធី អនុប្រធាននាយកដ្ឋានដំណាំឧស្សាហកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម





វឌ្ឍនភាពនៃការអនុវត្តគម្រោងស្ដីពី "ការធ្វើឱ្យប្រសើរឡើងនូវបច្ចេកវិទ្យាចិញ្ចឹមដង្កូវនាង និងការផលិតសូត្រចេញពីដង្កូវនាងកូនកាត់ពូជ CK1-7-4 ( Optimization of Cultivation Technology and Production of Silk from Hybridized Silkworm CK1-7-4 )"។

តម្បាញសូត្រ មិនត្រឹមតែដើរតួជាផ្នែកមួយនៃប្រវត្តិសាស្ត្រ ប៉ុន្តែថែមទាំងជាផ្នែកមួយនៃវប្បធម៌រស់នៅក្នុងជីវភាពរបស់ជនជាតិខ្មែរតាំងពីយូលង់។ ជាប្រពៃណីដ៏យូលង់មកហើយ នារីខ្មែរតែងតែស្លៀកពាក់សំពត់ហូល ផាមួងដែលផលិតពីសសៃសូត្រ សម្រាប់ចូលរួមក្នុងពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរ បុណ្យភ្ជុំបិណ្ឌ ពិធីមង្គលការ បុណ្យជាតិ និងបុណ្យបែបសាសនាផ្សេងៗទៀត។ល។ ការប្រកាន់ខ្ជាប់នូវប្រពៃណីដ៏ផូរផង់នេះ ធ្វើឲ្យវប្បធម៌ជាតិខ្មែរនៅតែពណ្ណរាយជាដរាបពីមួយជំនាន់ទៅមួយជំនាន់។ ឯកសារដែលដកស្រង់ចេញពីខេត្តតាកែវ បានឲ្យដឹងថាខ្មែរបានផលិតសូត្រចាប់តាំងពីសម័យហ្វូណន ហើយបច្ចុប្បន្ន តម្បាញសូត្រ និងផលិតផលសូត្រមានសារៈសំខាន់សម្រាប់ខេត្តចំនួនប្រាំ ដែលមានការច្នៃម៉ូតដ៏ល្បី និងគុណភាពខ្ពស់គឺមកពីខេត្តតាកែវ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពត។

ជាអកុសល ផលិតកម្មសូត្រខ្មែរ ត្រូវបានបោះបង់ចោលស្ទើរតែទាំងស្រុងក្នុងសម័សសង្គ្រាម ប៉ុន្តែនៅទសវត្សរ៍ឆ្នាំ១៩៩០ រហូតមកទល់បច្ចុប្បន្ន ផលិតកម្មនេះបានចាប់ផ្ដើមដំណើរឡើងវិញ តែហាក់ដូចជាមិនទាន់បានឆ្លើយតបតាមតម្រូវការប្រើប្រាស់ក្នុងស្រុកនៅឡើយ។ ជាក់ស្ដែង គេឃើញមានដំណាំមនមានការដាំដុះតិចតួចនៅតាមបណ្ដាខេត្តមួយចំនួនដូចជា ៖ ខេត្តតាកែវ សៀមរាប បន្ទាយមានជ័យ កំពង់ស្ពឺ កំពង់ឆ្នាំង បាត់ដំបង កណ្ដាល កំពត និងមណ្ឌលគិរី។ល។ ផលិតផលស្លឹកមន ត្រូវបានប្រើប្រាស់ជាអាទិភាពទីមួយជាចំណីរបស់ដង្កូវនាង ដែលដង្កូវនាងស៊ីស្លឹកមន បង្កើតបានជាសំបុក សំបុកនេះផលិតចេញសសៃសូត្រ និងទី២ស្លឹកមនយកមកកែច្នៃធ្វើជាតែ សម្រាប់កាត់បន្ថយជាតិស្កក្នុងឈាម សិប្បករតម្បាញបានយកសសៃសូត្រនេះមកត្បាញជាហូល ផាមួង ផាមួងចរបាប់ ផាមួងកទា ក្រមា និងផលិតផលប្រើប្រាស់ផ្សេងៗទៀត ឬសំបុកដង្កូវនាងយកមកកែច្នៃជាគ្រឿងសម្អាងសម្រាប់ស្ត្រីផងដែរ។លោក កែវ កង រស់នៅក្នុងភូមិពារាម ឃុំពាម ស្រុកបាទី ខេត្តតាកែវ បានឲ្យដឹងថាដើម្បីបានហូល ឬផាមួងមួយក្បិន គឺត្រូវចំណាយពេល ស្មារតីផ្ចិតផ្ចង់ ឧស្សាហ៍ព្យាយាមគ្រប់តំណាក់កាលទាំងអស់តាំងពីយកសូត្រមកបោកទឹកឲ្យស្អាត យកទៅរវៃចងពង់ យកទៅកុងចងម៉ូតផ្កា ឬសត្វ ជ្រលក់ពណ៌ជាច្រើន លើកតាមពណ៌ដែលចង់បានរវៃចូលត្រល់ ទើបយកទៅត្បាញ ហើយការត្បាញទៀតសោធន៍ទាមទារពេលវេលា ភាពអត់ធ្មត់ គំនិតច្នៃប្រឌិតក្បូរក្បាច់រចនា និងផ្ចិតផ្ចង់ក្នុងការត្បាញម្ដងមួយ សសៃៗ តម្រឹមក្រឡាគោម។ល។ឲ្យបានហ្មត់ចត់ទើបផលិតបានហូល ឬផាមួងមានភាព

ល្អប្រណិត។ ផលិតកម្មសូត្រនៅកម្ពុជាមិនទាន់បំពេញតម្រូវការទីផ្សារនូវឡើយ គឺនៅមានកសិករតិចជាង ១០០នាក់ប៉ុណ្ណោះ ដែលកំពុងដំណើរការអាជីវកម្មផលិតកម្មសូត្រនេះ និងផលិតសូត្របានតិចជាង ១តោនប៉ុណ្ណោះក្នុងឆ្នាំ២០១៤។ តាមការសិក្សារបស់អង្គការស្បៀង និងកសិកម្ម នៃអង្គការសហប្រជាជាតិ បានឱ្យដឹងថា កម្ពុជាត្រូវការសូត្រ (វត្ថុធាតុដើម) ប្រហែល ៤០០ តោនក្នុងមួយឆ្នាំ ខណៈពេលដែលកម្ពុជាផលិតសូត្របានត្រឹមតែតិចជាង ១% នៃតម្រូវការក្នុងស្រុក។ការអភិវឌ្ឍផលិតកម្មដំណាំមន និងសូត្រនៅមានកម្រិតនៅឡើយ ដោយសារប្រពៃណីទំនៀមទំលាប់ទាំងការដាំមន ការចិញ្ចឹមដង្កូវនាងការផលិតសសៃសូត្រ និងការត្បាញ មិនទាន់មានការផ្លាស់ប្តូរ ឬមានការវិវឌ្ឍន៍យឺតយ៉ាវ។ នេះអាចនិយាយបានថា ពួកគាត់នៅខ្វះបច្ចេកទេសដាំដុះដំណាំមន ការជ្រើសរើសពូជមន ពូជដង្កូវនាង ការចិញ្ចឹមដង្កូវនាង ការកែច្នៃសសៃសូត្រ ឧបករណ៍ប្រើប្រាស់ដូចជាកីតម្បាញ។ល។ ខ្វះពូជដង្កូវនាងដែលមានគុណភាពល្អ និងផ្តល់ទិន្នផលសូត្រខ្ពស់។ ដើម្បីចូលរួមអភិវឌ្ឍ និងអភិរក្សប្រពៃណីវប្បធម៌ដ៏មានតម្លៃដែលជាមរតករបស់ដូនតា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានអគ្គនាយកដ្ឋានកសិកម្មជាសេនាធិការ បាន និងកំពុងខិតខំធ្វើការសិក្សាស្រាវជ្រាវផ្សព្វផ្សាយ និងបណ្តុះបណ្តាលកសិករអំពីបច្ចេកទេសដាំដុះដំណាំមន និងការចិញ្ចឹមដង្កូវនាង ព្រមទាំងបានផ្តល់ពូជមន និងពូជដង្កូវនាងដែលជាពូជក្នុងស្រុក (ពូជសូត្រមាស) ពូជកូនកាត់CK1.7.4 និងពូជដែលទើបបង្កាត់បានថ្មីៗជាពូជមានសំបុកពណ៌ស ផ្តល់ទិន្នផលសូត្រខ្ពស់ជាងពូជក្នុងស្រុកដល់កសិករ និងសិប្បករ ដើម្បីបង្កើនផលិតកម្មសូត្ររបស់ពួកគាត់។ ទោះជាយ៉ាងណា ការបណ្តុះបណ្តាល និងការគាំទ្រដល់កសិករពុំទាន់អាចឆ្លើយតបបានទាំងស្រុងទៅតាមតម្រូវការជាក់ស្តែងនៅឡើយ ដោយសារចំណេះ ដឹង/ជំនាញរបស់មន្រ្តីបច្ចេកទេសទាំងថ្នាក់ជាតិ និងថ្នាក់ខេត្តទាក់ទងនឹងខ្សែប្រវាក់ផលិតកម្មសសៃសូត្រនៅមានកម្រិត ដែលទាមទារឱ្យមានការលើកកម្ពស់សមត្ថភាព ធនធានមនុស្សបន្ថែមទៀត ព្រមជាមួយការគាំទ្រធនធានថវិកា លើការងារស្រាវជ្រាវបណ្តុះបណ្តាល និងផ្សព្វផ្សាយ។

ឆ្លើយតបទៅនឹងបញ្ហានេះ អគ្គនាយកដ្ឋានកសិកម្មបានសហការជាមួយមជ្ឈមណ្ឌលកសិកម្មអន្តរជាតិកូរ៉េហៅកាត់ថា KOPIA បាន និងកំពុងអនុវត្តគម្រោងមួយឈ្មោះថា “ការធ្វើឱ្យប្រសើរឡើងនូវបច្ចេកវិទ្យាចិញ្ចឹមដង្កូវនាង និងការផលិតសរសៃសូត្រចេញពីដង្កូវនាងកូនកាត់ពូជ CK1-7-4”។ គោលបំណងគឺ ធ្វើឱ្យប្រសើរឡើងនូវផលិតកម្មសូត្រតាមរយៈការផ្សព្វផ្សាយពូជដង្កូវនាងកូនកាត់ CK1-7-4 ការបង្កាត់ពូជដង្កូវនាងអ៊ីប្រ៊ីត និងការអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗ ហើយគម្រោងនេះមានរយៈពេល០៣ឆ្នាំចាប់ពីឆ្នាំ២០២០ - ២០២២។

## ១. សកម្មភាពសំខាន់ៗរបស់គម្រោងរួមមាន៖

- ការបង្កាត់ពូជអ៊ីប្រ៊ីតថ្មី និងថែទាំពូជមេបា
- ការធ្វើឱ្យប្រសើរឡើងនូវការផលិតពងដង្កូវនាង និងការចិញ្ចឹមក្នុងលក្ខខណ្ឌប្រទេសកម្ពុជា
- ការចិញ្ចឹមដង្កូវនាងបង្ហាញ និងទិវាចម្ការតាមខេត្តគោលដៅ និង
- ការពង្រឹងសមត្ថភាពមន្ត្រីបច្ចេកទេស កសិករ និងសិប្បករអំពីបច្ចេកទេសដាំដុះដំណាំមន ការជ្រើសរើសពូជដង្កូវនាង និងចិញ្ចឹមដង្កូវនាង។

## ២. លទ្ធផលសម្រេចបានមានដូចខាងក្រោម ៖

- បណ្តុះបណ្តាល៖
    - មន្ត្រីបច្ចេកទេសចំនួន០៤រូប ទទួលបានការគាំទ្រផ្នែកបច្ចេកទេស
    - កសិករ សិប្បករ និងសហគ្រិន នៅខេត្តកណ្តាល សៀមរាប តាកែវ និងខេត្តបន្ទាយមានជ័យចំនួន ៦៦រូប ទទួលបានការបណ្តុះបណ្តាលបច្ចេកទេសដាំដុះដំណាំមន និងការចិញ្ចឹមដង្កូវនាង












*សកម្មភាពបណ្តុះបណ្តាល និងផ្តល់ចំណេះដឹងអំពីការចិញ្ចឹមថែទាំដង្កូវនាង ដាំដុះដំណាំមន នៅខេត្តកណ្តាល និង បន្ទាយមានជ័យ*

- ការចិញ្ចឹមថែរក្សាពូជមេបា CK1-7-4 ជាពូជដែលបង្កាត់បានក្នុងស្រុករវាងពូជនាំចូលពីប្រទេសកូរ៉េ និង ពូជក្នុងស្រុក (ពូជសូត្រមាស) និងពូជ Gumokjam និងការបង្កាត់ពូជដង្កូវនាងអ៊ីប្រ៊ីតថ្មីៗបន្ថែមទៀត ដើម្បីទទួលបានទិន្នផលសូត្រខ្ពស់ ហើយធន់នឹងអាកាសធាតុក្នុងប្រទេសកម្ពុជា










*ការចិញ្ចឹមថែរក្សាពូជដង្កូវនាងមេបា C.K1.7.4 និង Gumokjam*

ការបន្សាំពូជបង្កាត់ថ្មីទៅនឹងលក្ខខណ្ឌអាកាសធាតុនៃប្រទេសកម្ពុជា៖ ត្រូវបានធ្វើឡើងនៅទីតាំងមួយចំនួន ក្នុងប្រទេស រួមមាន មន្ទីរពិសោធន៍ដង្កូវនាងនៃអគ្គនាយកដ្ឋានកសិកម្ម ស្ថានិយ៍ពិសោធន៍កសិកម្មបន្ទាយដែក កសិករនៅខេត្តកណ្តាល តាកែវ សៀមរាប និងខេត្តបន្ទាយមានជ័យ។ គម្រោងបានចែកពូជដង្កូវនាងដល់សិប្បកម្មតម្បាញ M-Silk នៅខេត្តតាកែវ ចំនួន២០,០០០កូន សហគ្រាសតម្បាញ Color-Silk នៅខេត្តសៀមរាប ចំនួន២០,០០០កូន កសិករដាំដុះដំណាំមន និងចិញ្ចឹមដង្កូវនាងនៅឃុំពយចារ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យចំនួន៥០,០០០កូន និងកសិករនៅខេត្តកណ្តាល ចំនួន ៤០,០០០កូន សម្រាប់ចិញ្ចឹម តាមដានការលូតលាស់ និងទិន្នផលនៃពូជដង្កូវនាងផ្សេងៗក្នុងលក្ខខណ្ឌប្រទេសកម្ពុជា។

**តារាងទី១ ការប្រៀបធៀបការលូតលាស់ និងទិន្នផលពូជដង្កូវនាងផ្សេងៗ**

| ការលូតលាស់ និងទិន្នផល | ពូជស្លុត្រមាស | ពូជ C.K1.7.4 | ពូជ C.K.O | ពូជ C.K.P |
|---|---|---|---|---|
| ប្រវែងដង្កូវ ក្នុងវគ្គទី៥ (ម.ម) | ៤៤.៨០ | ៥៧.៩៨ | ៦០.៣៨ | ៥៩.២១ |
| ទម្ងន់ដង្កូវ ក្នុងវគ្គទី៥ (ក្រ) | ១.៤៧ | ១.៩៥ | ២.៩៦ | ២.៨៩ |
| ប្រវែងសំបុក (ម.ម) | ៣១.០០ | ៣២.១២ | ៣២.៩៥ | ៣៣.៦២ |
| អង្កត់ផ្ចិតសំបុក (ម.ម) | ១២.០០ | ១៤.២៦ | ១៦.១២ | ១៦.៣១ |
| កម្រាស់សំបុក (ម.ម) | ០.១៣ | ០.១៧ | ០.២៦ | ០.២៥ |
| ទម្ងន់សំបុក (ក្រ) | ០.១១ | ០.១៤ | ០.២១ | ០.២២ |















ការចែកពូជដង្កូវនាងដល់កសិករសហការក្នុងតាកែវ និងខេត្តសៀមរាប កណ្ដាល បន្ទាយមានជ័យ







ការចិញ្ចឹមដង្កូវនាងរបស់កសិករគោលដៅ ដើម្បីបន្សាំទៅនឹងអាកាសធាតុប្រទេសកម្ពុជា

- បានធ្វើពិសោធន៍ការភ្ញាស់ពងដង្កូវនាងដោយប្រើអាស៊ីត (Acid treatment) ហើយបានជោគជ័យដោយមានអត្រាញាស់ខ្ពស់។





ការភ្ញាស់ពងដង្កូវនាងដោយប្រើអាស៊ីត (Acid treatment)

- ការបោះពុម្ពឯកសារបច្ចេកទេស៖ គម្រោងបានបោះពុម្ពសៀវភៅបច្ចេកទេស និង Leaflets ស្តីពីការដាំដុះដំណាំមន និងការចិញ្ចឹមដង្កូវនាង និងចែកចាយដល់ស្ថាប័នពាក់ព័ន្ធ និងកសិករចិញ្ចឹមដង្កូវនាង ដើម្បីជំរុញការផ្សព្វផ្សាយ និងជំរុញវិស័យកោសេយវប្បកម្មឱ្យមានការរីកចំរើនឆាប់រហ័ស។



*Leaflets ស្តីពីការដាំដុះដំណាំមន និងការចិញ្ចឹមដង្កូវនាង*

## ៣. សេចក្តីសន្និដ្ឋាន

តាមរយៈការអនុវត្តគម្រោងនេះ អគ្គនាយកដ្ឋានកសិកម្ម សង្ឃឹមថា មន្ត្រីបច្ចេកទេស ក្រុមកសិករ សិប្បករ និងសហគ្រិន ក្នុងខេត្តគោលដៅទាំងអស់នឹងទទួលបាននូវចំណេះដឹង និងជំនាញច្បាស់លាស់ក្នុងការដាំដុះដំណាំមន និងចិញ្ចឹមដង្កូវនាង ហើយនឹងផលិតបានពូជដង្កូវនាងថ្មីបានច្រើន ផ្តល់ទិន្នផលសូត្រខ្ពស់ និងសមស្របទៅនឹងលក្ខខណ្ឌអាកាសធាតុ។ នាពេលដ៏ឆាប់ខាងមុខ វិស័យផលិតកម្មសូត្រនឹងមានការរីកចំរើន និងអាចផលិតសរសៃសូត្របានច្រើន ដើម្បីផ្គត់ផ្គង់សេចក្តីត្រូវការក្នុងស្រុក កាត់បន្ថយការនាំចូល និងអាចនាំចេញបានមួយចំនួន។




*សៀវភៅបច្ចេកទេស ស្តីពីការដាំដុះដំណាំមន និងការចិញ្ចឹមដង្កូវនាង*

## ៤. ទិសដៅបន្តរបស់គម្រោង ៖

- បន្តពង្រឹងសមត្ថភាពបច្ចេកទេសដល់មន្ត្រីបច្ចេកទេស កសិករ សិប្បករ និងអ្នកពាក់ព័ន្ធ
- បន្តចិញ្ចឹមរក្សាពូជមេបា និងបង្កាត់ពូជថ្មី
- ធ្វើទិវាបង្ហាញពីបច្ចេកទេសចិញ្ចឹមដង្កូវនាងដល់កសិករក្នុងខេត្តគោលដៅ
- ចងក្រងឯកសារសម្រាប់ធ្វើការផ្សព្វផ្សាយ។
- ចងក្រងទិន្នន័យពូជថ្មីសម្រាប់ចុះបញ្ជីពូជដង្កូវនាងថ្នាក់ជាតិ។



ផលិតផលពីសរសៃសូត្រ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក ស ក

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្ដីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំនព្វមាស ឆ្នាំ២០២១ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងនព្វមាសនេះ ការងារបង្កបង្កើនផលដំណាំរដូវវស្សាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ជាពិសេសស្រូវរដូវវស្សាសម្រេចបាន ២ ៨២៦ ២៣៣ហ.ត ស្មើនឹង១០៨,៣២% នៃផែនការចំនួន ២ ៦០៩ ០៦៥ហ.ត។ វិធានការជំរុញផលិតកម្មដំណាំ ការចិញ្ចឹមសត្វ និងវារីវប្បកម្មត្រូវបានដាក់ចេញ និងអនុវត្តយ៉ាងសកម្មដើម្បីជួយដល់កសិករ។ រីឯការចូលរួមទប់ស្កាត់បទល្មើស ជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផល បទល្មើសចលនាសត្វដោយខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងនព្វមាសនេះ គឺបានរៀបចំកិច្ចប្រជុំការងារចាំបាច់តាមរយៈការប្រជុំពីចម្ងាយ រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។ ចំពោះលទ្ធផល និងសកម្មភាពការងារតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ២០២១ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានគិតត្រឹមនព្វមាស ឆ្នាំ២០២១នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្ដាផ្នែក

### ១ ផ្នែកដាំដុះ

### ១.១ ផលិតកម្មដំណាំស្រូវរដូវវស្សា

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ២ ៨៥០ ២៤៤ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ១៦ ៦២៤ហ.ត ស្មើនឹង០,៥៨% និងដោយគ្រឿងយន្តចំនួន ២ ៨៣៣ ៦២០ហ.ត ស្មើនឹង៩៩,៤២%
- ផ្ទៃដីសាបសម្រេចបានចំនួន ១២ ៣៩២ហ.ត តិចជាងឆ្នាំមុនចំនួន ៣ ៣៩០ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ២ ៨២៦ ២៣៣ហ.ត ស្មើនឹង១០៨,៣២% នៃផែនការចំនួន ២ ៦០៩ ០៦៥ហ.ត លើសឆ្នាំមុន ១១២ ០១៧ហ.ត។

### ១.២ ការប្រមូលផលស្រូវស្រាលរដូវវស្សា

ការប្រមូលផលស្រូវស្រាលសម្រេចចំនួន ៥៦៤ ៧៩២ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ២ ២៦៨ ៧១៧តោន លើសឆ្នាំមុនចំនួន ៦០៦ ៦៥៦តោន និងទទួលបានទិន្នផលគិតជាមធ្យម ៤,០១៧តោន/ហ.ត។

### ១.៣ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្មរដូវវស្សា

-ដំណាំសាកវប្បកម្មអនុវត្តបានសរុបចំនួន ៥៥ ៣៩៦ហ.ត ស្មើនឹង១០៣,១៩% នៃផែនការចំនួន ៥៣ ៦៨៦ហ.ត តិចជាងឆ្នាំមុន ៩ ២៤៨ហ.ត

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៧៨២ ៩៦៧ហ.ត ស្មើនឹង៩៥,៤៩% នៃផែនការចំនួន ៨១៩ ៩៨៩ហ.ត តិចជាងឆ្នាំមុន ១១ ៣៣១ហ.ត។

### ១.៤ ការនាំចេញផលិតផលកសិកម្ម

#### ១.៤.១ ការនាំចេញអង្ករ

- ការនាំចេញអង្ករក្នុងខែកញ្ញា ឆ្នាំ២០២១ មានចំនួន ៦៧ ២៥១តោន កើនឡើងចំនួន ២៦ ៦៧៩តោន (៦៥,៧៦%) បើធៀបនឹងខែកញ្ញា ឆ្នាំ២០២០ មានចំនួន ៤០ ៥៧២តោន

- បរិមាណអង្ករនាំចេញក្នុងរយៈពេល៩ខែឆ្នាំ២០២១ មានចំនួន ៤១០ ៦៩៨តោន ថយចុះចំនួន ៧៨ ០៧៧តោន (-១៥,៩៧%) បើធៀបនឹងបរិមាណនាំចេញក្នុងរយៈពេល៩ខែឆ្នាំ២០២០ មានចំនួន ៤៨៨ ៧៧៥តោន

- ក្នុងរយៈពេល៩ខែឆ្នាំ២០២១ បរិមាណអង្ករបាននាំចេញទៅកាន់ទិសដៅសហភាពអឺរ៉ុបចំនួន ២២ប្រទេស មានបរិមាណសរុបចំនួន ១០៤ ២២២តោន (ថយចុះចំនួន ៥៧ ៣៩២តោន ស្មើនឹង -៣៥,៥១%) ទិសដៅប្រទេសចិន មានបរិមាណសរុបចំនួន ២០៣ ២៧៩តោន (កើនឡើងចំនួន ៣១ ៣៨៣តោន ស្មើនឹង ១៨,២៦%) ទិសដៅអាស៊ាន ចំនួន ៧ប្រទេស មានបរិមាណសរុបចំនួន ៤១ ៤៧៦តោន(ថយចុះចំនួន ២៥ ៩៥៧តោន ស្មើនឹង -៣៨,៤៩%) និងទិសដៅដទៃទៀតចំនួន ២៣ប្រទេស មានបរិមាណសរុប ៦១ ៧២១តោន (ថយចុះចំនួន ២៦ ១១១តោន ស្មើនឹង -២៩,៧៣%)

- ក្រុមហ៊ុននាំចេញអង្ករមានចំនួន ៥៩ក្រុមហ៊ុន ហើយបរិមាណអង្ករដែលបាននាំចេញដោយក្រុមហ៊ុនធំៗចំនួន ១០ មានរហូតដល់ ២៩៩ ៥៣៣តោន (៧២,៩៤%) និងក្រុមហ៊ុន៤៩ដទៃទៀតបាននាំចេញត្រឹមតែ ១១១ ១៦៥តោន (២៧,០៦%)។

**១.៤.២ ការនាំចេញស្រូវ**

ក្នុងរយៈពេល៩ខែឆ្នាំ២០២១ ការនាំចេញស្រូវមានចំនួន ២ ៥២៣ ២៦៣តោន ទៅកាន់ប្រទេសវៀតណាម (មានវិញ្ញាបនបត្រភូតគាមអនាម័យចំនួន ១ ៦២៧ ៧៤០,០២តោន) មានការកើនឡើងចំនួន ១ ១៣០ ៩៥៧តោន (៨១,២៣%) បើធៀបនឹងរយៈពេល៩ខែ ឆ្នាំ២០២០ មានចំនួន ១ ៣៩២ ៣០៦តោន។

**១.៤.៣ ការនាំចេញកសិផលផ្សេងៗ**

ក្នុងរយៈពេល៩ខែ ឆ្នាំ២០២១ មានបរិមាណនាំចេញដោយធៀបនឹងរយៈពេល៩ខែ ឆ្នាំ២០២០៖

- ដំឡូងមីស្រស់មានចំនួន ៥៧៥ ៩២០តោន (កើនឡើងចំនួន ៩,៤៧%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាម ចំនួន ៣៨៦ ៤២០តោន និងប្រទេសថៃចំនួន ១៨៩ ៥០០តោន

- ម្សៅដំឡូងមីមានចំនួន ២២ ៣៩៦,៧៤តោន (កើនឡើងចំនួន ១៣,៤១%) ក្នុងនោះនាំចេញទៅប្រទេសចិន ចំនួន ១៩ ៨៦៨,៦០តោន ប្រទេសថៃចំនួន ១ ៣៧៥,៨០តោន ប្រទេសអ៊ីតាលីចំនួន ៦៩៤,៣៤តោន សហរដ្ឋអាមេរិក ចំនួន ១៧០តោន ប្រទេសណេដឺឡែនចំនួន ១៥២តោន និងប្រទេសប៊ែលហ្ស៊ិកចំនួន ១៣៦តោន

- គ្រាប់ស្វាយចន្ទីមានចំនួន ៨៩២ ៥៣៥,៧១តោន (កើនឡើងចំនួន ៣៣៧,០៧%) នាំចេញទៅប្រទេសវៀតណាម ចំនួន ៨៨៥ ១៤០តោន ប្រទេសចិនចំនួន ៣ ៨៩៦,៩៤តោន ប្រទេសថៃចំនួន ៣ ៣០៥,៤០តោន ប្រទេសឥណ្ឌាចំនួន ៩៨,៦០តោន ប្រទេសជប៉ុនចំនួន ៤៤,១៣តោន ប្រទេសកូរ៉េចំនួន ១៦,៨៨តោន ប្រទេសអារ៉ាប់ចំនួន ១៤,៥១តោន ប្រទេសណេដឺឡែនចំនួន ៨,២១តោន ប្រទេសបង់ក្លាដែសចំនួន ៧តោន ប្រទេសឡាវចំនួន ៤តោន ប្រទេសស្វីសចំនួន ០,០២តោន ប្រទេសតូហ្គោចំនួន ០,០១តោន និងប្រទេសអារ៉ាប់រួមចំនួន ០,០១តោន

- គ្រាប់ពោតមានចំនួន ១៥៤ ៤៥៩,៣៤តោន (ថយចុះចំនួន -២០,៣៦%) នាំចេញទៅប្រទេសវៀតណាម ចំនួន ១១១ ១៧០តោន ប្រទេសថៃចំនួន ៤២ ៣៥០តោន កោះតៃវ៉ាន់ចំនួន ៨៧៦,២៩តោន ប្រទេសបង់ក្លាដេស ចំនួន ៤២,០៥តោន និងប្រទេសកូរ៉េចំនួន ២១តោន

- គ្រាប់សណ្តែកបាយមានចំនួន ២៥ ៣៣០តោន (កើនឡើងចំនួន ៤១៩,០៩%) នាំចេញទៅប្រទេសវៀតណាម

- គ្រាប់សណ្តែកសៀងមានចំនួន ២៧ ៩៦០,០៤តោន (កើនឡើងចំនួន ៣៤៧,៣៦%) នាំចេញទៅប្រទេសវៀតណាមចំនួន ១៩ ១១០តោន ប្រទេសថៃចំនួន ៨ ៨៥០តោន និងប្រទេសអារ៉ាប់រួមចំនួន ០,០៤តោន

- ផ្លែចេកស្រស់មានចំនួន ៣៤៣ ៨១២,៣៤តោន (កើនឡើងចំនួន ៤៦,២០%) នាំចេញទៅប្រទេសចិនចំនួន ៣០១ ៦២៨,៩៩តោន ប្រទេសវៀតណាមចំនួន ៤១ ១៦៩,៣៥តោន ប្រទេសជប៉ុនចំនួន ៥៣៣,៥២តោន និងប្រទេសសិង្ហបុរីចំនួន ៤៨០,៤៨តោន

- ផ្លែក្រូចថ្លុងមានចំនួន ៣៤ ៩១៨,៤៤តោន (កើនឡើងចំនួន ១៣០,៤៨%) នាំចេញទៅប្រទេសថៃចំនួន ៣៤ ៨៥៤តោន និងប្រទេសវៀតណាមចំនួន ៦៤,៤៤តោន

- ផ្លែស្វាយស្រស់មានចំនួន ១៧២ ៨៤៦,៨៣តោន (កើនឡើងចំនួន ១៧៤,៧១%) នាំចេញទៅប្រទេសវៀតណាមចំនួន ១៤៧ ៩៧៤,១៨តោន ប្រទេសថៃចំនួន ២៤ ៤៦៩,២៨តោន ប្រទេសចិនចំនួន ២១២តោន ប្រទេសកូរ៉េចំនួន ១២៤,៣៨តោន ទីក្រុងហុងកុងចំនួន ៥០,៧៨តោន ប្រទេសសិង្ហបុរីចំនួន ១៦,២០តោន និងប្រទេសគុយវ៉ែតចំនួន ០,០១តោន

- ដូងប្រេងមានចំនួន ៤៥ ៧៩៦,៦៩តោន (កើនឡើងចំនួន ០,៩៨%) នាំចេញទៅប្រទេសឥណ្ឌាចំនួន ៣៥ ០១៦,៦៩តោន និងប្រទេសម៉ាឡេស៊ីចំនួន ១០ ៧៨០តោន

- ម្រេចមានចំនួន ២៧ ៣១៦,៧២តោន (កើនឡើងចំនួន ៥៦២,៧១%) នាំចេញទៅប្រទេសវៀតណាមចំនួន ២៦ ៦៨៦,៦៨តោន ប្រទេសអាល្លឺម៉ង់ចំនួន ៣១៤តោន ប្រទេសថៃចំនួន ១៨០តោន ប្រទេសឥណ្ឌាចំនួន ៤២តោន ប្រទេសបារាំងចំនួន ៣១,១៧តោន ប្រទេសបែលហ្ស៊ិកចំនួន ១៥,៩៨តោន កោះតៃវ៉ាន់ចំនួន ១៥,០៤តោន ប្រទេសប៉ូឡូញចំនួន ៧,០៩តោន សាធារណរដ្ឋឆេកចំនួន ៦,១០តោន ប្រទេសជប៉ុនចំនួន ៣,៤០តោន ប្រទេសកូរ៉េចំនួន ៣,២៥តោន ប្រទេសរុស្ស៊ីចំនួន ២,៤០តោន ប្រទេសសិង្ហបុរីចំនួន ១,៩៧តោន សហរដ្ឋអាមេរិកចំនួន ១,៧៥តោន ប្រទេសស្វីសចំនួន ១,៦៤តោន ប្រទេសស៊ុយអ៊ែតចំនួន ១,២៩តោន ចក្រភពអង់គ្លេសចំនួន ១,២៤តោន ប្រទេសអូស្ត្រាលីចំនួន ០,៩០តោន ប្រទេសកាណាដាចំនួន ០,៥២តោន ប្រទេសកាហ្សាក់ស្ថានចំនួន ០,១៩តោន និងប្រទេសអារ៉ាប់រួមចំនួន ០,០១តោន

- ថ្នាំជក់មានចំនួន ២ ៥១៤,០៥តោន (ថយចុះចំនួន -៥៣,៥៨%) នាំចេញទៅប្រទេសវៀតណាមចំនួន ២ ៤៣២,៨០តោន ប្រទេសបែលហ្ស៊ិកចំនួន ៥៩,៤២តោន ប្រទេសហុងគ្រីចំនួន ១៩,៨០តោន ប្រទេសបូស្នៀ និងហឺហ្សេហ្គោវីណាចំនួន ១,៩០តោន ប្រទេសចិនចំនួន ០,១០តោន ប្រទេសឥណ្ឌូនេស៊ីចំនួន ០,០២តោន ប្រទេសសិង្ហបុរីចំនួន ០,០១តោន និងប្រទេសអាល្លឺម៉ង់ចំនួន ០,០០១តោន

- បន្លែចម្រុះមានចំនួន ៧៧,៥០តោន (ថយចុះចំនួន -១១,៥០%) នាំចេញទៅប្រទេសបារាំង

- ម្ទេសស្រស់មានចំនួន ៨០ ៣២៧,១២តោន (កើនឡើងចំនួន ៤៥,៦៤%) នាំចេញទៅប្រទេសថៃចំនួន ៨០ ៣២៧,១២តោន និងប្រទេសអារ៉ាប់រួមចំនួន ០,០០២តោន។

## ២ ផ្នែកផលិតកម្មកៅស៊ូ

### ២.១ ផ្ទៃដីកៅស៊ូ

- ផ្ទៃដីកៅស៊ូសរុបចំនួន ៤០៤ ១៦០ហ.ត ក្នុងនោះ ផ្ទៃដីចម្ការកៅស៊ូកសិ-ឧស្សាហកម្មចំនួន ៤៨ ៥៤៦ហ.ត ផ្ទៃដីចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ចចំនួន ១៩៤ ៤៥៤ហ.ត និងផ្ទៃដីចម្ការកៅស៊ូគ្រួសារចំនួន ១៦១ ១៦០ហ.ត។ ផ្ទៃដីចៀរជ័រចំនួន ៣១៤ ៣១៩ហ.ត ស្មើនឹង៧៨% និងផ្ទៃដីថែទាំចំនួន ៨៩ ៨៤១ហ.ត ស្មើនឹង២២%។

### ២.២ ផលិតកម្មកៅស៊ូ

- ផលិតផលជ័រកៅស៊ូរយៈពេល៨ខែ ឆ្នាំ២០២១ បានចំនួន ១៩៨ ០៦៦តោន កើនឡើងចំនួន ១៥ ៥៨០តោន ស្មើនឹង៩% ធៀបរយៈពេល៨ខែ ឆ្នាំ២០២០

- ផលិតផលឈើកៅស៊ូរយៈពេល៨ខែ ឆ្នាំ២០២១ បានចំនួន ៤ ៧៦៩ម$^3$។

### ២.៣ ការនាំចេញកៅស៊ូ

- បរិមាណជ័រកៅស៊ូបញ្ចេញលក់រយៈពេល៨ខែ ឆ្នាំ២០២១ បានចំនួន ១៩៤ ៥២៥តោន កើនឡើងចំនួន ១៤ ៦០៥តោន ស្មើនឹង៨% ធៀបរយៈពេល៨ខែ ឆ្នាំ២០២០

- បរិមាណឈើកៅស៊ូបញ្ចេញលក់រយៈពេល៨ខែ ឆ្នាំ២០២១ បានចំនួន ៤ ៣៧៩ម$^3$។

### ២.៤ តម្លៃកៅស៊ូ

- តម្លៃជ័រកៅស៊ូលក់មធ្យមក្នុងខែសីហាគឺ១ ៦៧០ដុល្លារ/តោន កើនឡើងចំនួន ៦១ដុល្លារ/តោន ស្មើនឹង៣,៧៦% ធៀបខែមុន និងកើនឡើងចំនួន ៤០៨ដុល្លារ/តោន ស្មើនឹង៣២% ធៀបខែសីហា ឆ្នាំ២០២០

- តម្លៃជ័រកៅស៊ូលក់មធ្យមរយៈពេល៨ខែ ឆ្នាំ២០២១គឺ១ ៦៧៣ដុល្លារ/តោន កើនឡើងចំនួន ៣៨៦ដុល្លារ/តោន ស្មើនឹង៣០% ធៀបរយៈពេល៨ខែ ឆ្នាំ២០២០

- តម្លៃឈើកៅស៊ូលក់មធ្យមក្នុងខែសីហាគឺ៣១៣ដុល្លារ/ម$^3$

- តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារនៅនឹងចម្ការក្នុងខែមិថុនាគឺទឹកជ័រ (DRC ១០០%) មានការប្រែប្រួលពី ៥ ៧៧៥៛/គ.ក្រ ដល់ ៦ ០០០៛/គ.ក្រ និងជ័រកក (DRC50%) មានការប្រែប្រួលពី ២ ៩០០៛/គ.ក្រ ដល់ ៣ ៤៥០៛/គ.ក្រ។

## ៣ ផ្នែកព្រៃឈើ

### ៣.១ ការងារព្រៃឈើ

- ចេញប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ចំនួន ៥កន្លែងមានផ្ទៃដីទំហំ៣ ៦១៩,៨៦ហ.ត ក្នុងព្រៃសហគមន៍រយាស ព្រៃសហគមន៍ខ្សាច់ពូន ព្រៃសហគមន៍ភូមិវាលវង់ ព្រៃសហគមន៍អូរអាចម៍កុក និងព្រៃសហគមន៍ប្រាំបីមុមពីរ

- ផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្តចំនួន ១១០គ្រឿង និងយានយន្តចំនួន ១៤៥គ្រឿង ជូនក្រុមហ៊ុនចំនួន ៩ក្រុមហ៊ុន និងអ្នកស្នើសុំចំនួន ១នាក់

- ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន ៩ក្រុមហ៊ុន និងអ្នកស្នើសុំចំនួន ៧នាក់ មានឈើហ៊ុបមូលចំនួន ១៨ ៥២៨ម៣ ឈើអារចំនួន ១ ៥២៧ម៣ ឈើជ្រុងចំនួន ៤ម៣ កូនឈើចំនួន ២៤៥ ២៩៥ដើម បង្គោលរបងចំនួន ៣៥ដើម បង្គោលក្រាក់ចំនួន ៤០ដើម អុសចម្រុះចំនួន ១៩០ ១៤៧ស្ទែរ គ្រែចំនួន ៧ឈុត ទ្វារចំនួន ៤៧សន្លឹក ឬស្សីចំនួន ៩៦តោន ធ្យូងចំនួន ៣ ០០០គ.ក្រ និងជ័រទឹកចំនួន ៤៩៦តោន

- ធ្វើសារពើភណ្ឌវាយតម្លៃបាន់ស្មានធនធានព្រៃឈើជូនក្រុមហ៊ុន សល សុភា ពាណិជ្ជ (ខេត្តស្ទឹងត្រែង) ក្រុមហ៊ុន ស៊ីងបាយអូរថេក (ខេមបូឌា) ខូអិលធីឌី (ខេត្តក្រចេះ និងខេត្តស្ទឹងត្រែង) ក្រុមហ៊ុន សាន ហ៊ាង (កម្ពុជា) អាហារ័ណ នីហារ័ណ ឯ.ក (ខេត្តឧត្តរមានជ័យ) ក្រុមហ៊ុនខេមបូឌា ដោន ផ្លេនថេសិន អិលធីឌី (ខេត្តព្រះវិហារ)។

### ៣.២ ការងារអភិរក្សសត្វព្រៃ

- ក្រុមការងារសិក្សាស្រាវជ្រាវ និងអង្កេតតាមដានវត្តមានសត្វព្រៃបានចុះសិក្សាស្រាវជ្រាវប្រមូលទិន្នន័យ និងតម្លើងម៉ាស៊ីនថតរូបស្វ័យប្រវត្តិចំនួន ១២គ្រឿង ដើម្បីធ្វើការថតចាប់យករូបភាពសត្វព្រៃគ្រប់ប្រភេទនៅក្នុងតំបន់ព្រៃឈើសហគមន៍វាលកន្សែងស្ថិតនៅក្នុងឃុំកំពង់ដំរី ស្រុកឆ្លូង ខេត្តក្រចេះ

- ចុះពិនិត្យម៉ាស៊ីនថតស្វ័យប្រវត្តចំនួន ១២គ្រឿងត្រូវបំពាក់សម្រាប់តាមដានវត្តមាន និងកត្តាគំរាមកំហែងចំពោះសត្វព្រៃ និងដំរីព្រៃនៅតំបន់ជួរភ្នំក្រវាញស្ថិតក្នុងភូមិសាស្ត្រឃុំឫស្សីជ្រុំ និងឃុំថ្មដូនពៅ ស្រុកថ្មបាំង ខេត្តកោះកុង

- ចុះពិនិត្យ និងប្រមូលម៉ាស៊ីនថតស្វ័យប្រវត្តចំនួន ៧គ្រឿងបានបំពាក់ដើម្បីថត និងតាមដាន វត្តមានសត្វព្រៃនៅក្នុងសហគមន៍ព្រៃឈើប្រាំបីមុម ក្នុងគោលបំណងប្រមូលទិន្នន័យ និងធាតុចូលបន្ថែមដើម្បីជួយសម្រួលដល់ការចងក្រងអត្ថបទចុះផ្សាយផ្សាយស្តីពីការសិក្សាស្រាវជ្រាវពីជីវចម្រុះនៅក្នុងតំបន់សហគមន៍ព្រៃឈើប្រាំបីមុម ខេត្តកំពង់ស្ពឺ

- ចុះពង្រឹងការថែរក្សាសត្វព្រៃចំនួន ១លើកនៅក្នុងសហគមន៍ព្រៃឈើវាលកន្សែង ខេត្តក្រចេះ និង ចុះពង្រឹងការថែរក្សាសត្វព្រៃចំនួន ១លើក នៅសហគមន៍ព្រៃឈើប្រាំបីមុម ខេត្តកំពង់ស្ពឺ និងចុះសិក្សាកំណត់តំបន់សក្តានុពលទេសចរណ៍ធម្មជាតិចំនួន ១លើកនៅខេត្តតាកែវ

- ចេញលិខិតអនុញ្ញាតដឹកជញ្ជូនសត្វព្រៃទៅកាន់មាត់ច្រកអន្តរជាតិសម្រាប់នាំចេញចំនួន ៩៥ច្បាប់ ក្នុងនោះ ៩១ច្បាប់សម្រាប់ការថែរក្សាសត្វក្រចៅកកាំ និង៤ច្បាប់ទៀតសម្រាប់ថែរក្សាសត្វឃ្មុំដែលមានទីតាំងស្ថិតនៅរាជធានីភ្នំពេញ ខេត្តកោះកុង កែប កំពត តាកែវ ពោធិ៍សាត់ កណ្តាល សៀមរាប កំពង់ធំ បន្ទាយមានជ័យ កំពង់ចាម ត្បូងឃ្មុំ ប៉ៃលិន និងខេត្តមណ្ឌលគិរី។

### ៣.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- ក្រុមហ៊ុនចំនួន៧កំពុងដំណើរការកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្តាមយកកូននាំចេញមានទីតាំងស្ថិតនៅក្នុងរាជធានីភ្នំពេញ ខេត្តកំពង់ធំ សៀមរាប កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង មានស្វាក្តាមចំនួន ៩៤ ២០៨ក្បាល ក្នុងនោះកូនកើតរយៈពេល៩ខែចំនួន ៤៧ ៩២៥ក្បាល ដឹកជញ្ជូនក្នុងស្រុកចំនួន ៣ ៦៣០ក្បាល និងដឹកជញ្ជូនទៅកាន់មាត់ច្រកអន្តរជាតិសម្រាប់នាំចេញទៅក្រៅប្រទេសចំនួន ១៦ ៤៧៥ក្បាល

- នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅបាននិងកំពុងថែរក្សាសត្វព្រៃចំនួន ១ ៦១៣ក្បាល (បក្សី៥៨ប្រភេទ ថនិកសត្វ៤៤ប្រភេទ និងល្មូន១៦ប្រភេទ) សង្គ្រោះសត្វព្រៃថ្មីចំនួន ៦៧៧ក្បាល ព្យាបាលបានចំនួន ២៨០ក្បាល និងបានស្តារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងដោះលែងសត្វព្រៃគ្រប់ប្រភេទទៅព្រៃធម្មជាតិចំនួន ៥៥៩ក្បាល

- ក្រុមល្បាតសហគមន៍ចំនួន ៣០នាក់ បានដើរល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន៥ គឺអារ៉ែង ឆាយរាប តំបន់ស្តារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)

- អង្កេតតាមដានប្រចាំឆ្នាំនៅស្ទឹងខៀវ ស្ទឹងអារ៉ែង ស្ទឹងដាច់ក្នុងខេត្តកោះកុង និងបឹងវាលវែងនៃខេត្តពោធិ៍សាត់ បានរកឃើញក្រពើភ្នំចំនួន ៩ក្បាល លាមកក្រពើចំនួន ១១២ដុំ និងស្នាមដានចំនួន ១៥កន្លែង

- ជួសជុលផ្លូវដោយក្រាលក្រួសក្រហមប្រវែង ៨ ៣៧៤ម៉ែត្រ និងកាប់ឆ្ការអនាម័យព្រៃទំហំ ១២ហ.ត នៅក្នុងតំបន់សួនសត្វ។

### ៣.៤ ការងារដាំដើមឈើ

- ដីកប្រឡាយការពារចម្ការគ្រញូងនៅស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើអន្លង់ថ្មខេត្តកំពង់ធំប្រវែង៦ ០០០ម៉ែត្រ

- ចុះសិក្សាពិនិត្យទីតាំងសម្រាប់បង្កើតស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើលើទីតាំងដីចម្ការម៉ៃសាក់របស់រដ្ឋមានទំហំ២០០ហ.ត ទីតាំងស្ថិតនៅខេត្តប៉ៃលិន និងបានចុះបញ្ជីដីស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើសំបួរមាសមានផ្ទៃដីទំហំ ២៦៦ ០៤៣ម៉ែត្រការ៉េ ស្ថិតនៅក្នុងខេត្តបាត់ដំបង

- ចុះពិនិត្យស្រាវជ្រាវ និងទប់ស្កាត់ការកាប់រានឈូសឆាយរំលោភដីស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើរមាសហែក-តាសួសនៅខេត្តស្វាយរៀង

- បាននិងកំពុងថែទាំចម្ការឈើសរុបទំហំ ៨២២ហ.ត ក្នុងនោះចម្ការពូជឈើទំហំ ៩៤ហ.ត ឡូត៍បង្ហាញកសិ-រុក្ខកម្មទំហំ ៤៤ហ.ត ចម្ការឈើដាំទំហំ ៦៥៤ហ.ត និងចម្ការរុក្ខទិវា ៩ កក្កដាទំហំ ៣០ហ.ត ស្ថិតក្នុងខេត្តកំពត កណ្តាល សៀមរាប ព្រះសីហនុ ស្វាយរៀង កំពង់ធំ និងខេត្តក្រចេះ

- ការដាំឈើជាចម្ការថ្មីសរុបចំនួន ៧ ៤៧០ហ.ត ក្នុងនោះដាំឈើដោយរដ្ឋមានទំហំ ១២៥ហ.ត (ខេត្តកំពង់ធំទំហំ ៨០ហ.ត និងខេត្តកំពង់ឆ្នាំងទំហំ ៤៥ហ.ត) និងដាំឈើដោយក្រុមហ៊ុនឯកជនដៃគូសហការ បុគ្គលឯកជន និងដៃគូសហការលក្ខណៈគ្រួសារមានទំហំ ៧ ៣៤៥ហ.ត និងដំណាំកសិកម្ម (ដាំពោតមានទំហំ ៣៥ហ.ត ធ្វើស្រែទំហំ ២៦៥ហ.ត និងឈូសឆាយដីថ្មីទំហំ ១០០ហ.ត)។

### ៣.៥ ការងារនីតិកម្ម និងវិវាទ

- សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃទទួលបានពីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងក្រុមអន្តរា-គមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័តនៃរដ្ឋបាលព្រៃឈើសរុបចំនួន ៦១៩ករណី (ព្រៃឈើចំនួន ៤៨៦ករណី សត្វព្រៃចំនួន ១៩ករណី និងកាប់រានដីព្រៃចំនួន ១១៤ករណី)

- វត្ថុតាងនៃបទល្មើសព្រៃឈើបានចាប់ឃាត់ និងដកហូតរួមមានឈើអារចំនួន ៩៦៧ម៣ ក្រាក់គ្រញូងចំនួន ០ម៣៤៤០ និង៨៦០គ.ក្រ ផ្ទៃដីព្រៃឈើកាប់រានទំហំ ២ ៦៩៩ហ.ត អនុផលព្រៃឈើនិងសម្ភារមួយចំនួនទៀត។ វត្ថុតាងជាសត្វព្រៃ និងសំណាកសត្វព្រៃបានប្រមូលតាមរយៈការប្រគល់-ទទួលចំនួន ២២៨ករណី ធ្វើកិច្ចសន្យាចំនួន ៣៧ករណី និងដកហូតចំនួន ៤៨ករណី រួមមាន៖ សត្វព្រៃរស់ចម្រុះប្រភេទចំនួន ៧៥១ក្បាល និងសត្វព្រៃងាប់ចម្រុះប្រភេទចំនួន ២ ១៩៦ក្បាល និង៦៧,៦០គ.ក្រ ចែជ្រូកព្រៃចំនួន៣ ទ្រូងអណ្តើកស្រែចំនួន១ ត្រចៀកទន្សាយក្រៀមចំនួន៥គូ និងកន្ទុយទន្សាយក្រៀមចំនួន ១១កន្ទុយ។

### ៣.៦ ការងារឧស្សាហកម្ម និងពាណិជ្ជកម្ម

- ពិនិត្យសំណើសុំបង្កើតរោងសន្និធិលក់ចែកចាយផលអនុផលព្រៃឈើប្រភេទធំ (ច្រកចេញចូលតែមួយ) ចំនួន ៨កន្លែង (ខេត្តបាត់ដំបង បន្ទាយមានជ័យ មណ្ឌលគិរី ព្រៃវែង កំពង់ស្ពឺ កណ្តាល និងខេត្តព្រះវិហារ) និងពន្យារសុពលភាពចំនួន ៩កន្លែង (រាជធានីភ្នំពេញ ខេត្តស្វាយរៀង ព្រៃវែង រតនគិរី កំពង់ធំ កណ្តាល និងខេត្តកំពង់ចាម)

- ពិនិត្យសំណើសុំបង្កើតរោងម៉ាស៊ីនអារកែច្នៃឈើចំនួន ៤កន្លែង (ខេត្តត្បូងឃ្មុំ ព្រះវិហារ និងខេត្តតាកែវ) និងពន្យារសុពលភាពរោងម៉ាស៊ីនអារកែច្នៃឈើ និងរោងសិប្បកម្មកែច្នៃចញ្ច្រាំកម្ទេចឈើដាំចំនួន ១០កន្លែង (រាជធានីភ្នំពេញ ខេត្តបាត់ដំបង ក្រចេះ មណ្ឌលគិរី បន្ទាយមានជ័យ ព្រះវិហារ និងខេត្តស្ទឹងត្រែង)

- ក្រុមហ៊ុនចំនួន៨នាំចេញផលិតផលរានទេវតា និងឈើកែច្នៃ ទៅក្រៅប្រទេសមានចំនួន ១ ១៤១ម៣ ជ័រទឹកចំនួន ២៤៦តោន និងចំណាំងកម្ទេចឈើប្រេងខ្យល់ចំនួន ៦ ៦៤០តោន និងក្រុមហ៊ុនចំនួន៣នាំចូលឈើកែច្នៃចំនួន ១ ៣៦៨ម៣

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន៩មានឈើកែច្នៃចំនួន ៨៥៩ម៣ ចំណាំងកម្ទេចឈើប្រេងខ្យល់ចំនួន ៧ ០០០តោន ឫស្សីកែច្នៃចំនួន ៥៨តោន និងជ័រទឹកចំនួន ២៤៦តោន

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលជូនក្រុមហ៊ុនចំនួន៤មានបរិមាណឈើកែច្នៃ (MDF, Wood Panel, Dark Red Meranti, Chanfuta, ឈើស្រល់) សរុបចំនួន ១ ៩៣៥ម៣។

### ៣.៧ ការងារចំណូលព្រៃឈើ

- ប្រមូលចំណូលសរុប ៦ ៣០០ ៥៦២ ៧១០រៀល និង២ ៤០៧ ៩៨៦,០៨ដុល្លារ។

## ៤ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

**៤.១ ការងារផលិតកម្មសត្វ៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តារាជធានី-ខេត្តរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយ

អំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើស្តូនដំណាំចំណីសត្វ ការផ្តល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ និងចុះពិនិត្យនិងកែសម្រួលឡជីវឧស្ម័នដែលបានសាងសង់រួចហើយ ដែលមានបញ្ហាបច្ចេកទេសនៅតាមខេត្តគោលដៅ។ កំពុងរៀបចំគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០២១ ដល់ឆ្នាំ២០៣០ ការសាងសង់ឡជីវឧស្ម័នក្នុងរយៈពេល៩ខែ ដើមឆ្នាំ២០២១ នេះសម្រាប់កម្មវិធី NBP សាងសង់ឡបានចំនួន៣៨១ឡ ក្នុងខេត្តគោលដៅចំនួន ១៤ខេត្ត និងគម្រោងចិនសាងសង់ឡបានចំនួន៧ឡ ក្នុងខេត្តព្រះវិហារ និងខេត្តពោធិ៍សាត់។

### ៤.២ ការងារសុខភាពសត្វ

- **លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖** បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យ និងបង្ក្រាបយ៉ាងសកម្មដោយក្រុមអន្តរាគមន៍របស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន ១២២ករណី ក្នុងនោះ ត្រួតពិនិត្យមានលិខិតអនុញ្ញាតត្រឹមត្រូវចំនួន៧៦ករណី និងមិនមានលិខិតអនុញ្ញាតត្រឹមត្រូវ៤៦ករណី។ រាជធានី-ខេត្តចំនួន ២៥បាន និងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ១៤៧ ៤១២លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។
- **ការងារផ្សព្វផ្សាយបច្ចេកទេស**

ចុះឃោសនាផ្សព្វផ្សាយស្តីពីជំងឺឆ្លងសត្វនៅតាមបណ្តាខេត្តចំនួន៥ ចុះណែនាំកសិករនិងអ្នកពាក់ព័ន្ធស្តីពីជំងឺឆ្លងសត្វនៅតាមបណ្តាខេត្តចំនួន២ ចុះផ្សព្វផ្សាយស្តីពីបច្ចេកទេសចិញ្ចឹមសត្វនិងជំងឺឆ្លងសត្វនៅតាមបណ្តាខេត្តចំនួន២។

- **ការងារនីតិកម្ម និងវិវាទ**

\- កំពុងប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការធ្វើអាជីវកម្មពិឃាតសត្វ ទីកន្លែងកែច្នៃបឋមផលិតផលសត្វ និងសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីគំរូសំណុំលិខិតដោះស្រាយបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ

\- កំពុងប្រជុំពិភាក្សាផ្ទៃក្នុងនៅនាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេស និងនីតិកម្ម និងកំពុងរៀបចំបន្តលិខិតបទដ្ឋានគតិយុត្តទំនាក់ទំនងការងារវិមជ្ឈការ និងវិសហមជ្ឈការ

\- ចុះពិនិត្យ និងតាមដានការអនុវត្តច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វនៅតាមបណ្តាខេត្តចំនួន៥ ប្រជុំផ្សព្វផ្សាយច្បាប់ និងកម្រងលិខិតបទដ្ឋានគតិយុត្តវិស័យសុខភាពសត្វ និងផលិតកម្មសត្វនៅតាមបណ្តាខេត្តចំនួន២។

### ៤.៣ ការងារស្រាវជ្រាវ

- **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១០៨ក្បាល។
- **ការងារស្រាវជ្រាវសុខភាពសត្វ៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺ និងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបចំនួន ១៤ ១៦៥វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី និងជំងឺប៉េស្តជ្រូកអាហ្រ្វិក (ASF) និងជំងឺដុំពកស្បែកគោ ក្របី (LSD)។ ជំងឺផ្តាសាយបក្សីមានផ្ទុះចំនួន១កន្លែងនៅភូមិព្រែកតាច្រែង ឃុំព្រែងនរិន្ទ ស្រុកឯកភ្នំ ខេត្តបាត់ដំបង កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២១។ ជំងឺប៉េស្តជ្រូកអាហ្រ្វិក (ASF) បានរកឃើញតាមរយៈការលួចនាំជ្រូកចូលពីប្រទេសថៃឡង់ដ៍ចំនួន២ករណី នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១ និងថ្ងៃទី៨ ខែមីនា ឆ្នាំ២០២១ នៅខេត្តបន្ទាយមានជ័យ និងជំងឺដុំពកស្បែកគោ-ក្របី (LSD) ផ្ទុះសរុបចំនួន៧៤កន្លែង ក្នុងនោះ ៩កន្លែងក្នុងខេត្តកណ្តាល ១០កន្លែងក្នុងខេត្តកំពង់ឆ្នាំង ១កន្លែងក្នុងខេត្តកំពង់ស្ពឺ ១០កន្លែងក្នុងខេត្តព្រៃវែង ១៩កន្លែងក្នុងខេត្តសៀមរាប ៥កន្លែងក្នុងខេត្តស្ទឹងត្រែង ៦កន្លែងក្នុងខេត្តក្រចេះ ៨កន្លែងក្នុងខេត្តបន្ទាយមានជ័យ ៦កន្លែងក្នុងខេត្តពោធិ៍សាត់ បណ្តាលឲ្យសត្វឈឺសរុបចំនួន ៦ ៣៨១ក្បាល និងងាប់គោ៨៥ក្បាល។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

\- ជាយត្រីអនុវត្តបញ្ចប់ត្រឹមចំនួន ១ ៣១០តោន ស្មើនឹង១១,៩១% នៃផែនការចំនួន ១១ ០០០តោន ប្រៀបធៀបនឹងមាស ឆ្នាំ២០២០ ថយចុះចំនួន ១៩០តោន

- នេសាទគ្រួសារដែននេសាទបានចំនួន ១៨៥ ០០០តោន ស្មើនឹង៦១,៦៧% នៃផែនការចំនួន ៣០០ ០០០តោន ប្រៀបធៀបនឹងឆមាស ឆ្នាំ២០២០ ថយចុះចំនួន ៣ ៩០០តោន

- នេសាទគ្រួសារតាមវាលស្រែបានចំនួន ៣៦ ០០០តោន ស្មើនឹង២៥,៧១% នៃផែនការចំនួន ១៤០ ០០០តោន ប្រៀបធៀបនឹងឆមាស ឆ្នាំ២០២០ ថយចុះចំនួន ២៦ ១០០តោន។

៥.១.២ នេសាទសមុទ្រ

បានចំនួន ៨៧ ៨០០តោន ស្មើនឹង៦៧,៥៤% នៃផែនការចំនួន ១៣០ ០០០តោន ប្រៀបធៀបនឹងឆមាស ឆ្នាំ២០២០ ថយចុះចំនួន ៥០០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គាបានចំនួន ១៥៤ ៧០០តោន ស្មើនឹង៣២,១៦% នៃផែនការចំនួន ៤៨១ ០០០តោន ប្រៀបធៀបនឹងឆមាស ឆ្នាំ២០២០ ថយចុះចំនួន ១៥៥ ២០០តោន

- ការចិញ្ចឹមក្រពើបានចំនួន ២៤៧ ៨០០ក្បាល ស្មើនឹង៧៥,០៩% នៃផែនការចំនួន ៣៣០ ០០០ក្បាល ប្រៀបធៀបនឹងឆមាស ឆ្នាំ២០២០ ថយចុះចំនួន ២៤ ៤៩០ក្បាល

- ការភ្ញាស់កូនត្រីពូជបានចំនួន ២៧៣ ៥២៩ ៩៣៨កូន ស្មើនឹង១០១,៣១% នៃផែនការចំនួន ២៧០ ០០០ ០០០កូន ប្រៀបធៀបនឹងឆមាស ឆ្នាំ២០២០ កើនឡើងចំនួនប្រមាណ ១១៤ ១២៩ ៩៣៨កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបបានចំនួន ៤០ ០៥០តោន ស្មើនឹង៥០,០៦% នៃផែនការចំនួន ៨០ ០០០តោន ប្រៀបធៀបនឹងឆមាស ឆ្នាំ២០២០ ថយចុះចំនួន ២ ១០០តោន

- ផលនេសាទសមុទ្របានចំនួន ៨ ៥០០តោន ស្មើនឹង៧០,៨៣% នៃផែនការចំនួន ១២ ០០០តោន ប្រៀបធៀបនឹងឆមាស ឆ្នាំ២០២០ កើនឡើងចំនួន ១០តោន

- ការផលិតទឹកត្រីបានចំនួន ៤១ ០២២ ០០០លីត្រ ស្មើនឹង៧៤,៥៩% នៃផែនការចំនួន ៥៥ ០០០ ០០០លីត្រ ប្រៀបធៀបនឹងឆមាស ឆ្នាំ២០២០ ថយចុះចំនួន ១ ៧៧៨ ០០០លីត្រ។

### ៥.៤ ការត្រួតពិនិត្យ និងបង្ក្រាបបទល្មើសជលផល

- សំណុំរឿងបទល្មើសជលផលមានចំនួន ២ ០៦៤ករណី ប្រៀបធៀបនឹងឆមាស ឆ្នាំ២០២០ កើនឡើងចំនួន ៣៥ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ១ ៩៧០ករណី និងសមុទ្រចំនួន ៩៤ករណី។

### ៥.៥ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់នាំចេញចំនួន ២ ៦៧៧តោន ស្មើនឹង៣៣,៤៦% នៃផែនការចំនួន ៨ ០០០តោន ប្រៀបធៀបនឹងឆមាស ឆ្នាំ២០២០ កើនឡើងចំនួន ១ ១៧៩តោន

- ផលនេសាទកែច្នៃនាំចេញចំនួន ១៥០តោន ស្មើនឹង៧,៥០% នៃផែនការចំនួន ២ ០០០តោន ប្រៀបធៀបនឹងឆមាស ឆ្នាំ២០២០ ថយចុះចំនួន ៨២តោន។

### ៥.៦ ការប្រមូលថវិកាសេវាជលផល

- ចំណូលចំនួន ៤៦៦ ០៩២ ៤២៨រៀល ស្មើនឹង១២៩,៩៨% នៃផែនការចំនួន ៣៥៨ ៦០០ ០០០រៀល ប្រៀបធៀបនឹងឆមាស ឆ្នាំ២០២០ ថយចុះចំនួន ១៩ ០២៥ ៩៣២រៀល។

## ៦ ផ្នែកអគ្គាធិការដ្ឋាន

- ចុះត្រួតពិនិត្យលើការងារអនុវត្តតួនាទីភារកិច្ចរបស់អធិការដ្ឋានរដ្ឋបាលជលផលចតុមុខ និងមេគង្គ

- ចុះពង្រឹង និងត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបការដឹកជញ្ជូនផល ផលិតផលជលផលនាំចូល នាំចេញ និងឆ្លងកាត់គ្មានការអនុញ្ញាតនៅខេត្តកណ្តាល ត្បូងឃ្មុំ តាកែវ ព្រៃវែង កំពត ស្វាយរៀង និងរាជធានីភ្នំពេញ

- ចុះធ្វើអធិការកិច្ចលើការងារដឹកនាំ និងគ្រប់គ្រងរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបន្ទាយមានជ័យ និងពិនិត្យលើចំណុចខ្វះខាតមួយចំនួនរបស់មន្ទីរដែរក្រសួងបានណែនាំឱ្យកែលម្អកន្លងមក

- ចុះត្រួតពិនិត្យការអនុវត្តលិខិតកែលម្អលេខ ១៥៣២កសក.អធ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ នៅខេត្តសៀមរាប

- ការទទួលពាក្យបណ្តឹងតាមរយៈប្រអប់សំបុត្រ និងតាមរយៈប្រព័ន្ធអ៊ិនធើណេតចំនួន ៥ករណី
- ស្រាវជ្រាវព័ត៌មានតាមបណ្តាគេហទំព័រពាក់ព័ន្ធនឹងវិស័យកសិកម្មចំនួន ៨៥៩ករណី លើវិស័យព្រៃឈើ១៨៤ករណី ជលផល១៩០ករណី សុខភាពសត្វនិងផលិតកម្មសត្វ១១៩ករណី កៅស៊ូ៩ករណី កសិ-ឧស្សាហកម្ម៥ករណី ក្សេត្រសាស្ត្រ ៥ករណី នីតិកម្មកសិកម្ម១ករណី និងវិស័យផ្សេងៗ៣៤៦ករណី
- ចូលរួមកម្មវិធីប្រជុំ សិក្ខាសាលា និងការងារសង្គមចំនួន ៣៤ករណី។

## ៧ ផ្នែករដ្ឋបាល

- បានទទួលលិខិតសរុបចំនួន ៥ ៨៩៧ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ២ ២៣៩ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ២ ៦០៧ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ១ ០៥១ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល
- បានបញ្ជូនឯកសារ និងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ៨ ៣២១ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ៣៥៩ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ១៩៧ច្បាប់
- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំដើម្បីក្តាប់ឱ្យបាននូវរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ ការរៀបចំកិច្ចប្រជុំនិងពិធីបុណ្យផ្សេងៗ ការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ៖ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម)។

## ៨ ផ្នែកបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសចំនួន ៥ ៨១១នាក់ (ស្រី១ ៤១២នាក់ ស្មើនឹង២៤,២៩%) រួមមាន៖
  + អង្គភាពថ្នាក់កណ្តាលចំនួន ២ ៩១២នាក់ (ស្រី៨២៤នាក់ ស្មើនឹង២៨,២៩%)
  + អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ២ ៨៩៩នាក់ (ស្រី៥៨៨នាក់ ស្មើនឹង២០,២៨%)
- តែងតាំងដំឡើងឋានៈ និងផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការសរុបចំនួន៩៣នាក់ (ស្រី៣៦នាក់)
- រៀបចំប្រកាសលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌចំនួន ១១នាក់
- រៀបចំប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងចំនួន ១៣នាក់
- រៀបចំប្រកាសដាក់ឱ្យមន្ត្រីរាជការចូលនិវត្តន៍ចំនួន ២០នាក់ (ស្ត្រី១២នាក់)
- រៀបចំប្រកាសដាក់ឱ្យមន្ត្រីរាជការចូលបម្រើការងារវិញចំនួន ១០នាក់
- រៀបចំប្រកាសស្តីពីការដំឡើងឋានន្តរស័ក្តិ និងថ្នាក់ប្រចាំឆ្នាំ២០២០ ជូនមន្ត្រីរាជការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន ១ ៥៩២នាក់ (ស្រី៤៥១នាក់)
- រៀបចំការបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសសរុបចំនួន ១ ០៩៧នាក់ (ស្រី៣០២នាក់) ក្នុងនោះ៖
  + ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមចំនួន ចំនួន១ ០៥១នាក់ (ស្រី២៩២នាក់)
  + ការបណ្តុះបណ្តាលក្រៅប្រទេសរយៈពេលខ្លី និងមធ្យមតាមរយៈប្រព័ន្ធ online ចំនួន ៤៦នាក់ (ស្រី១០នាក់)។

## ៩ ផ្នែកផែនការ និងស្ថិតិ

- រៀបចំពិនិត្យ និងផ្តល់ធាតុចូលលើសេចក្តីព្រាងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- រៀបចំផែនការថវិកាកម្មវិធីសម្រាប់ការគ្រប់គ្រងថវិកាឆ្នាំ២០២២
- រៀបចំសំណើសុំផ្តល់ធាតុចូលលើសេចក្តីព្រាងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា២០២១-២០៣០
- ពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងរបាយការណ៍ស្តីពីវឌ្ឍនភាពប្រចាំឆ្នាំ២០២០ ក្នុងការអនុវត្តក្របខ័ណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍នៃប្រព័ន្ធអង្គការសហប្រជាជាតិឆ្នាំ២០១៩-២០២៣
- រៀបចំផែនការយុទ្ធសាស្ត្រថវិកាបីឆ្នាំរំកិល២០២២-២០២៤ និងបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ពិនិត្យ និងកែសម្រួលផែនការវិនិយោគសាធារណៈបីឆ្នាំរំកិល២០២២-២០២៤ ជាមួយក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ចុះពិនិត្យ និងផ្ទៀងផ្ទាត់សន្និធិស្រូវពូជនៅខេត្តកំពង់ចាម ស្វាយរៀង មណ្ឌលគិរី ស្ទឹងត្រែង និងខេត្តកំពង់ស្ពឺ

- រៀបចំពិនិត្យ និងបញ្ជូនវិធានការគោលនយោបាយជំរុញវារីវប្បកម្មកម្ពុជាឆ្នាំ២០២១-២០២៣

- ចុះធ្វើការណែនាំ និងអង្កេតស្ទង់ទិន្នផលស្រូវប្រាំងឆ្នាំ២០២០-២០២១ ដោយសហការជាមួយមន្ត្រីស្ថិតិថ្នាក់ខេត្តស្រុក នៅខេត្តពោធិ៍សាត់ ក្រចេះ កំពង់ឆ្នាំង និងខេត្តបាត់ដំបង

- ចុះធ្វើការណែនាំ និងធ្វើអង្កេតស្ទង់ទិន្នផលស្រូវស្រាលដើមរដូវវស្សាឆ្នាំ២០២១-២០២២ ដោយសហការជាមួយមន្ត្រីស្ថិតិថ្នាក់ខេត្ត និងស្រុក នៅខេត្តមណ្ឌលគីរី និងខេត្តតាកែវ

- ចុះប្រមូលព័ត៌មានតម្លៃទីផ្សារកសិផលលក់ដុំក្នុងមួយសប្តាហ៍បីដងគឺថ្ងៃច័ន្ទ ពុធ និងសុក្រ និងតម្លៃលក់រាយម្តងក្នុងសប្តាហ៍នូវរៀងរាល់ថ្ងៃព្រហស្បតិ៍តាមបណ្តាទីផ្សារសំខាន់ៗ ទីតាំងប្រមូលទិញ និងកន្លែងលក់ដុំផលិតផលក្នុងបណ្តារាជធានី-ខេត្តចំនួន២៥រាជធានី-ខេត្ត

- រៀបចំសំណើសុំរបាយការណ៍តាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីប្រចាំត្រីមាសទី៤ (ទម្រង់M1) របាយការណ៍តាមដានអនុកម្មវិធីប្រចាំឆ្នាំ (ទម្រង់M2) និងរបាយការណ៍សមិទ្ធកម្មតាមដានការអនុវត្តថវិកាកម្មវិធី

- ចុះពិនិត្យបឋម និងវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមនៃគម្រោងពិពិធកម្មកសិកម្មកម្ពុជានៅខេត្តកំពង់ស្ពឺ កណ្តាល ក្រចេះ ស្ទឹងត្រែង រតនគិរី និងខេត្តមណ្ឌលគិរី។

## ១០ ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

- ចុះប្រតិបត្តិការចំណូលក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ(NRMIS) សរុបទឹកប្រាក់ចំនួន ៥៩ ២៧៦លានរៀល ស្មើនឹង១៦៧,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២១

- បញ្ចេញអាណត្តិបើកប្រាក់ពីក្រសួងសរុបចំនួន ៧០ ០៦៣លានរៀល ស្មើនឹង៤៦,៩% ធៀបនឹងឥណទានថ្មីក្រោយនិយ័តកម្ម

- រៀបចំសំណើសុំការអនុញ្ញាតទទួលយកសម្ភារ ឧបករណ៍ និងប្រតិករពីឃ្លាំងអាកាសយានដ្ឋានអន្តរជាតិភ្នំពេញដោយអនុវត្តគោលការណ៍ពន្ធ និងអាករជាបន្ទុករបស់រដ្ឋ

- រៀបចំសំណើសុំថវិកាជំពូក១ (គម្រោងវិនិយោគផ្ទាល់) ចំនួន ១ ៧៨៤ ០០០ ០០០រៀល ដើម្បីទូទាត់ថវិកាបុរេប្រទាននៅដំណាក់កាលទី១ និងថវិកាចំនួន ២ ២២៧ ៥០០ ០០០រៀល ស្មើនឹង៥០%នៃតម្លៃកិច្ចសន្យាដើម្បីទូទាត់ដំណាក់កាលទី២ ជូននាយកដ្ឋានវិស្វកម្មកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្មសម្រាប់ការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព សាងសង់ស្ថានីយបូមទឹកបណ្តែត អាងស្តុកទឹកបឋម និងភ្ជាប់បណ្តាញអគ្គិសនីនៅតាមបណ្តាសហគមន៍កសិកម្មចំនួន៦ក្នុងខេត្តកំពង់ចាម ព្រៃវែង និងខេត្តកំពង់ឆ្នាំង

- រៀបចំសំណើសុំពិនិត្យគាំទ្រផែនការសកម្មភាពឆ្នាំ២០២១ របស់កម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្នផ្នែកវារីវប្បកម្ម (CaPFish-Capture) ក្រោមហិរញ្ញប្បទានឥតសំណងរបស់សហភាពអឺរ៉ុប

- រៀបចំសំណើសុំថវិកាចំនួន ៥៩២ ៥៣២,០៦ដុល្លារអាមេរិក ដើម្បីបំពេញឡើងវិញចូលគណនីគម្រោងរបៀងអភិរក្សជីវចម្រុះមហាអនុតំបន់មេគង្គក្រោមហិរញ្ញប្បទានឥតសំណងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)

- ទទួលថ្លៃសម្បទានដីសេដ្ឋកិច្ចពីក្រុមហ៊ុនចំនួន ៣៤ក្រុមហ៊ុន

- ពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជីគណនេយ្យឆ្នាំ២០២០នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្វាយរៀង តាកែវ ព្រៃវែង ព្រះសីហនុ ក្រចេះ ស្ទឹងត្រែង និងខេត្តកំពត

- ទទួលឥណទានធានាចំណាយចំនួន ១៤គម្រោង និងបានរៀបចំឯកសារស្នើសុំសម្រាប់ដេញថ្លៃដើម្បីដំណើរការអនុវត្តនូវកិច្ចលទ្ធកម្ម

- បើកសំណើដេញថ្លៃ និងរៀបចំឯកសារកិច្ចសន្យាចំនួន ១០គម្រោងចុះពិនិត្យ និងវាយតម្លៃបញ្ចប់សុពលភាពសំណង់លើការងារជីកប្រឡាយការពារតំបន់ចម្ការឈើដាំ នៅខេត្តកំពង់ធំប្រចាំឆ្នាំ២០២០ ការងារជួសជុលទ្រុងសត្វទំនប់ស្នាក់ទឹកអនាម័យជើងព្រៃនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ ការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅតាមស្ថានីយពិសោធន៍កសិកម្មប្រចាំឆ្នាំ២០២០ស្ថិតនៅក្នុងខេត្តកំពង់ស្ពឺ និងខេត្តកណ្តាល

- ចូលរួមប្រជុំ ពិនិត្យ សិក្សា និងវាយតម្លៃមធ្យោបាយដឹកជញ្ជូនបទល្មើសព្រៃឈើគ្រប់ប្រភេទរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តមណ្ឌលគិរី ឧត្តរមានជ័យ ត្បូងឃ្មុំ ក្រចេះ កំពង់ធំ កំពត និងខេត្តកំពង់ស្ពឺ ដែលស្នើសុំជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ

- ចូលរួមប្រជុំពិនិត្យ និងវាយតម្លៃទ្រព្យសម្បត្តិរបស់នាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ និងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលស្នើសុំជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ

- ចូលរួមប្រជុំ ពិនិត្យ និងវាយតម្លៃលក់ផលឈើដាំដែលមានក្នុងទីតាំងដីស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ និងស្រុកសៀមបូក ខេត្តស្ទឹងត្រែង

- ចូលរួមពិនិត្យផ្ទៀងផ្ទាត់តារាងប្រៀបធៀបកើនឡើង និងថយចុះទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០២០ របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទកំពង់ចាម ត្បូងឃ្មុំ កំពង់ស្ពឺ ស្វាយរៀង ព្រៃវែង តាកែវ កំពង់ឆ្នាំង ក្រចេះ ព្រះសីហនុ និងខេត្តកំពត។

## ១១ ផ្នែកសវនកម្មផ្ទៃក្នុង

- រៀបចំផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុង២០២១-២០២៣
- រៀបចំផែនការសវនកម្មផ្ទៃក្នុងឆ្នាំ២០២១
- រៀបចំផែនការយុទ្ធសាស្ត្រថវិកា២០២២-២០២៤
- រៀបចំផែនការរដ្ឋទេយ្យបុរេប្រទានឆ្នាំ២០២១
- រៀបចំផែនការវិចារណកម្មចំណាយលើលទ្ធកម្មសាធារណៈឆ្នាំ២០២១ និងផែនការថវិកាឆ្នាំ២០២២
- រៀបចំរបាយការណ៍តាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីតាមទម្រង់ M1 ប្រចាំត្រីមាស និងរបាយការណ៍សមិទ្ធកម្មប្រចាំឆមាសទី១
- ចុះធ្វើសវនកម្មតាមផែនការសកម្មភាពសវនកម្មផ្ទៃក្នុងឆ្នាំ២០២១ចំនួន ១៣អង្គភាព ស្មើនឹង៣២,៥% នៃផែនការ ៤០សវនដ្ឋាន គឺមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ចាម កែប តាកែវ រាជធានីភ្នំពេញ ពោធិ៍សាត់ វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប អគ្គនាយកដ្ឋានកសិកម្ម វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា អគ្គនាយដ្ឋានកៅស៊ូ គម្រោងកាត់បន្ថយភាពក្រីក្រនិងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប (TSSD-AF) គម្រោងការគ្រប់គ្រងធនធានជលផលភូមិភាគឥសាន្ត និងគម្រោងកែលម្អការអប់រំឧត្តមសិក្សា។

## ១២ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- ចូលរួមកិច្ចប្រជុំ៧លើក ក្រោមក្របខ័ណ្ឌទ្វេភាគី និងពហុភាគី ចូលរួមកិច្ចប្រជុំ៨លើក (តាមប្រព័ន្ធវីដេអូពីចម្ងាយ) ក្រោមក្របខ័ណ្ឌអាស៊ានលើការងារក្រៅប្រទេស
- សម្របសម្រួលកិច្ចប្រជុំ១៩លើក សិក្ខាសាលា១លើកលើការងារក្នុងប្រទេស
- រៀបចំ និងសម្របសម្រួលការប្រារព្ធទិវាស្បៀងអាហារពិភពលោកឆ្នាំ២០២១
- សម្របសម្រួលជាមួយអង្គភាពជំនាញ និងគាំទ្រលើការស្នើគម្រោងហិរញ្ញប្បទានពីរដ្ឋាភិបាលជប៉ុន កូរ៉េ និងចិន
- សម្របសម្រួលការចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយដៃគូអភិវឌ្ឍន៍ រួមមាន សហព័ន្ធសហករណ៍ រ៉ៃអិនសិន អាល្លឺម៉ង់ (DGRV) សាកលវិទ្យាល័យ Konkuk ប្រទេសកូរ៉េ ក្រុមហ៊ុន Geotwo Co,Ltd ប្រទេសកូរ៉េ ក្រុមហ៊ុន Cardno Emerging Markets ប្រទេសអូស្ត្រាលី
- សម្របសម្រួលជាមួយអង្គភាពជំនាញក្រោមឱវាទ ដើម្បីផ្ដល់ធាតុចូលលើឯកសារពាក់ព័ន្ធក្រោមក្របខ័ណ្ឌកសិ-ពាណិជ្ជកម្មពិភាពលោក WTO
- សម្របសម្រួលកិច្ចការងារជាមួយអង្គការ Gret ស្ដីពីវិវឌ្ឍនាការនៃប្រព័ន្ធកសិអេកូឡូស៊ី និងស្បៀងអាហារប្រកបដោយសុវត្ថិភាព (ASSET) នៅប្រទេសកម្ពុជា
- សម្របសម្រួលកិច្ចការងារជាមួយអង្គការ Heifer ចុះកិច្ចព្រមព្រៀងអនុវត្តគម្រោងលើកកម្ពស់ផលិតផលមាន់ស្រែខ្មែរសម្រាប់មោទកភាពជាតិខ្មែរ
- សម្របសម្រួលកិច្ចការងារជាមួយអង្គការគោសប្បុរសដើម្បីកម្ពុជាចុះកិច្ចព្រមព្រៀងអនុវត្តគម្រោងគោសប្បុរសដើម្បីកម្ពុជា។

## ១៣ ផ្នែកនីតិកម្មកសិកម្ម

### ១៣.១ ការងារអាជីវកម្មជី-ថ្នាំកសិកម្ម

- ផ្ដល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២១១ក្រុមហ៊ុន សរុបចំនួន ២ ៤០០មុខ
- ផ្ដល់លិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២០៣ក្រុមហ៊ុន
- ផ្ដល់លិខិតអនុញ្ញាតនាំចេញថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៣ក្រុមហ៊ុន
- ផ្ដល់វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៥៨ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៦៣ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំ និងវេចខ្ចប់ជាថ្មីជីកសិកម្មចំនួន ១២ក្រុមហ៊ុន។

### ១៣.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ៦៥ក្រុមហ៊ុន សរុបចំនួន ៣៤៩សំណាក។

### ១៣.៣ ការងារអភិវឌ្ឍបទដ្ឋានគតិយុត្ត

- បានពិនិត្យលើសេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត្ត និងលិខិតផ្សេងៗចំនួន ១០ករណី
- បានពិនិត្យ និងផ្ដល់មតិលើសេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត្ត និងលិខិតផ្សេងៗចំនួន ១១ករណី។

### ១៣.៤ ការងារអនុវត្តច្បាប់

- អញ្ជើញក្រុមហ៊ុនពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្មចូលរួមប្រជុំណែនាំអំពីនីតិវិធីនៃការប្រកាសប្រតិវេទន៍ស្ដីពីការនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២លើក ស្មើនឹង១២ក្រុមហ៊ុន
- ចុះពិនិត្យការនាំចូលថ្នាំកសិកម្ម និងជីកសិកម្ម និងផ្ដល់សុពលភាពផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៧៨ក្រុមហ៊ុន
- ចុះពិនិត្យ និងវាយតម្លៃគ្រឹះស្ថានថ្នាំកសិកម្ម និងជីកសិកម្ម និងលាយផ្សំវេចខ្ចប់ជាថ្មីចំនួន ៣២ក្រុមហ៊ុន
- បានចុះធ្វើអធិការកិច្ចត្រួតពិនិត្យបទល្មើសថ្នាំកសិកម្ម និងជីកសិកម្មខេត្តគោលដៅចំនួន ១២ខេត្ត លើដេប៉ូសរុបចំនួន ៤៩ដេប៉ូ។

## ១៤ ផ្នែកមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- ថែទាំគេហទំព័រ (Web) និង Mobile App របស់ក្រសួង និងអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសរុបចំនួន១៧ និងគេហទំព័រមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី-ខេត្ត
- ដាក់ឲ្យដំណើរការប្រើប្រាស់អ៊ីម៉ែល (@maff.gov.kh) ផ្លូវការរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសម្រាប់ថ្នាក់ដឹកនាំប្រើប្រាស់ក្នុងការទំនាក់ទំនងផ្លូវការ
- តាមដានទិន្នន័យដែលផ្ទុកនៅលើ Cloud server នៃគេហទំព័រទាំង៤១
- តាមដានលើការផ្សព្វផ្សាយសកម្មភាពការងាររបស់អង្គភាពថ្នាក់កណ្ដាលលើគេហទំព័រសរុបចំនួនផុស៥៧ព័ត៌មាន
- តាមដានលើការផ្សព្វផ្សាយសកម្មភាពការងាររបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តលើគេហទំព័រសរុបចំនួនផុស ៣ ៤១៥ព័ត៌មាន
- ធ្វើការតាមដាន និងតំហែទាំប្រព័ន្ធបណ្ដាញអ៊ីនធើណេត និងម៉ាស៊ីនមេនៅក្នុងមជ្ឈមណ្ឌលឲ្យដំណើរការល្អ
- តាមដាន និងថែទាំម៉ាស៊ីន Firewall ដើម្បីទប់ស្កាត់ការចូលពីអ្នកខាងក្រៅ (Hacker)
- តម្លើងនិងកំពុងត្រួតពិនិត្យលើការប្រើប្រាស់ Network Attach Server (NAS) សម្រាប់មជ្ឈមណ្ឌលប្រើប្រាស់ក្នុងការទុកដាក់ឯកសារ
- ការរៀបចំទិន្នន័យក្នុងគេហទំព័រព័ត៌មានភូមិសាស្ត្រកសិកម្មរៀបចំផ្ទៃដីប្រមូលផល និងបរិមាណផលដំណាំសាកវប្បកម្មរយៈពេលខ្លីប្រចាំឆ្នាំ២០២០ សម្រាប់ទិន្នន័យដំណាំកសិកម្មរាជធានី-ខេត្តដែលរួមមាន៖ ដំណាំពោតស ដំឡូងផ្វា ដំឡូងមី បន្លែគ្រប់មុខ ម្ទេស និងឪឡឹក និងប្រភេទដំណាំឧស្សាហកម្មរយៈពេលខ្លីប្រចាំឆ្នាំ២០២០ សម្រាប់ទិន្នន័យកសិកម្ម រាជធានី-ខេត្តដែលរួមមាន៖ ដំណាំពោតក្រហម ដំឡូងមី សណ្ដែកដី សណ្ដែកបាយ សណ្ដែកសៀង ក្រចៅ ថ្នាំជក់ ល្ង អំពៅ និងដំណាំឈូក

- ចុះប្រមូលទិន្នន័យដំណាំសក្តានុពលក្នុងស្រុកសន្ទុក ខេត្តកំពង់ធំ ដើម្បីរៀបចំជាផែនទីដំណាំកសិកម្ម
- ទទួលសៀវភៅ ឯកសារបច្ចេកទេសកសិកម្ម ទស្សនាវដ្តី ដែលទទួលបានពីនាយកដ្ឋានកិច្ចការរដ្ឋបាល នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងផ្នែកផ្សេងៗសរុបចំនួន១៦៧ក្បាល/ច្បាប់
- ការផ្សព្វផ្សាយអំពីបណ្ណាល័យកសិកម្មអេឡិចត្រូនិក ដែលមានអ្នកចូលអានចំនួន ១០៧ ០២៨ដង/នាក់។

## ១៥ ផ្នែកផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- សហការជាមួយទូរទស្សន៍ជាតិកម្ពុជាចុះផលិតខ្សែវីដេអូបទយកការស្តីពីបច្ចេកទេសចិញ្ចឹមបង្កង ភ្ញាស់កូនបង្កងលក់ បច្ចេកទេសចិញ្ចឹមមាន់ ភ្ញាស់កូនមាន់លក់ ដាំបន្លែសុវត្ថិភាពក្នុងផ្ទះសំណាញ់នៅខេត្តបន្ទាយមានជ័យ បច្ចេកទេសចិញ្ចឹមនិងភ្ញាស់ពូជមាន់ខ្មៅ មាន់ស្រែ ត្រីអណ្តែង ត្រីឆ្តូញ ខ្យង កង្កែប ដាំបន្លែខាត់ណាដើម ខាត់ណាផ្កានៅខេត្តមណ្ឌលគិរី ក្រចេះ កណ្តាល និងខេត្តតាកែវ
- ចុះផលិត video បទយកការណ៍ និងផ្សព្វផ្សាយថ្មីចំនួន ១៣ប្រធានបទ
- ចាក់ផ្សាយឡើងវិញស្តីពីវេទិកាស្វែងយល់ពីកសិកម្មចំនួន ៨ប្រធានបទ
- ធ្វើការផលិត និងចាក់ផ្សាយថ្មីស្តីពីនាទីចុះស្រែជាមួយកសិករចំនួន ២ប្រធានបទ
- ចាក់ផ្សាយឡើងវិញស្តីពីនាទីចុះស្រែជាមួយកសិករចំនួន ៩ប្រធានបទ
- ផ្សព្វផ្សាយពីបច្ចេកទេសកសិកម្មនៅស្ថានីយវិទ្យុជាតិ FM105.70.75MHZ ចំនួន ៥៤ប្រធានបទ
- ជួយដោះស្រាយបញ្ហា និងផ្តល់ព័ត៌មានបច្ចេកទេសកសិកម្មនានាដល់កសិករ និងអតិថិជនចំនួន ១២៤សំណួរចម្លើយ មានខេត្តកណ្តាល តាកែវ រាជធានីភ្នំពេញ ត្បូងឃ្មុំ កំពង់ធំ កពង់ឆ្នាំង ស្ទឹងត្រែង រតនគិរី ស្វាយរៀង កំពត បាត់ដំបង ព្រៃវែង និងខេត្តកំពង់ចាម។

## ១៦ ផ្នែកកសិ-ឧស្សាហកម្ម

- បាននិងកំពុងបន្តរៀបចំសេចក្តីព្រាងច្បាប់ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា ប្រជុំពិភាក្សាលើសេចក្តីព្រាងច្បាប់នេះចំនួន១៦លើក ក្នុងនោះប្រជុំក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងច្បាប់នៃនាយកដ្ឋានកសិ-ឧស្សាហកម្មចំនួន ៨លើក ប្រជុំក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងច្បាប់នៃក្រសួងកសិកម្មចំនួន ៦លើក និងប្រជុំគណៈកម្មការបច្ចេកទេសរៀបចំតាក់តែងច្បាប់នៃក្រសួងកសិកម្មចំនួន ២លើក
- ចូលរួមកិច្ចប្រជុំជំរុញការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការ លើវិស័យកសិកម្មកម្ពុជា-ហុងគ្រី
- ចូលរួមកិច្ចប្រជុំពិនិត្យពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនៃការស្នើសុំបង្កើតរោងចក្រ សិប្បកម្មកែច្នៃកៅស៊ូ និងឈើកៅស៊ូ
- ចូលរួមប្រជុំលើកទី១របស់ក្រុមការងារអន្តរក្រសួង តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងជំរុញការអនុវត្តគោលនយោបាយ និងផែនការសកម្មភាពពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម
- ចូលរួមវគ្គបណ្តុះបណ្តាលមន្ទីរពិសោធន៍និម្មិតតាមប្រព័ន្ធអនឡាញស្តីពីការប្រមូលសំណាក ការរៀបចំប្រើប្រាស់ទុកដាក់សំណាក ការលាងសម្អាត និង ការវិភាគកាកសំណល់ថ្នាំកសិកម្ម និងការធ្វើបង្ហាញក្នុងមន្ទីរពិសោធន៍តាមវីដេអូ
- ចុះស្វែងយល់ពីការអនុវត្តជាក់ស្តែងស្តីពីវិញ្ញាបនបត្រសរីរាង្គនៅក្នុងសិប្បកម្មកែច្នៃគ្រាប់ស្វាយ ចន្ទីជ័យសំបូរនៅខេត្តកំពង់ធំ
- ចុះបណ្តុះបណ្តាលស្តីពីបច្ចេកទេសកែច្នៃបន្លែ ផ្លែឈើ និងគ្រាប់ធញ្ញជាតិនៅខេត្តព្រះសីហនុ
- ចុះបណ្តុះបណ្តាលស្តីពីការលើកកម្ពស់ស្តង់ដារគុណភាព និងសុវត្ថិភាពនៃផលិតផលកសិកម្មក្នុងខេត្តត្បូងឃ្មុំ
- ចុះបណ្តុះបណ្តាលស្តីពីបច្ចេកទេសក្រោយការប្រមូលផលនៃផលិតកម្មកសិកម្ម ក្នុងខេត្តពោធិ៍សាត់
- ចុះបណ្តុះបណ្តាលស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យាក្នុងខេត្តកំពង់ចាម
- ចុះសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្មរវាងកសិករ និងសហគមន៍អភិវឌ្ឍន៍កសិកម្មកម្ពុជាលើកិច្ចសន្យាដាំដុះចំបក់បារាំង (Macadamia) និងស្លឹកគ្រៃក្រអូប
- ចុះពិនិត្យលើសកម្មភាពនាំចេញស្វាយចន្ទីទៅកាន់ប្រទេសជប៉ុន។

## ១៧ ការស្រាវជ្រាវ ការអប់រំ និងការបណ្ដុះបណ្ដាលកសិកម្ម

### ១៧.១ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- ប្រមូលប្រភេទពូជដំណាំថ្មីៗបន្ថែមចំនួន ១៥ប្រភេទ សរុបចំនួន ១០៦សំណាក (ត្រសក់២៨សំណាក ល្ពៅ ៣៤សំណាក ឪឡឹក២សំណាក គ្រប់៤សំណាក ម្ទេស២សំណាក ចេក៥សំណាក អំពៅ៦សំណាក ដំឡូងផ្វា៩សំណាក ដំឡូងឈាមមាន់២សំណាក ដំឡូងដៃខ្លា១សំណាក ត្រាវ១សំណាក សណ្ដែក១សំណាក ពោត១សំណាក ស្វាយ៥សំណាក និងស្វាយចន្ទី៥សំណាក) មករក្សាទុកក្នុងធនាគារពន្ធុរបស់វិទ្យាស្ថាន និងបន្តការអភិរក្សពូជដំណាំនៅក្នុងវិទ្យាស្ថានចំនួន ៣៩ប្រភេទរួមមានស្រូវចំនួន ៦ ៧៧៦បញ្ជីក/សំណាក និងដំណាំផ្សេងៗចំនួន ៣៨ប្រភេទសរុបចំនួន ២៥១៧បញ្ជីក/សំណាក សរុបទាំងអស់មានចំនួន ៩ ២៩៣បញ្ជីក/សំណាក។ ដាំវាយតម្លៃ និងកំណត់លក្ខណៈលើដំណាំ៥មុខគឺមេទ្បុង ៥០សំណាក ម្ទេស៥០សំណាក ល្ពៅ៣០សំណាក គ្រប់៤០សំណាក និងដំឡូងផ្វា៣៦សំណាក សរុបមានចំនួន ២០៦ សំណាក

- ធ្វើពិសោធន៍ចំនួន ៨៤ប្រភេទនៅ៣១១កន្លែង ក្នុងនោះមានពិសោធន៍បន្សាំពូជលើស្រែកសិករ និងស្រែបង្ហាញចំនួន ១០៤កន្លែង។ បើកវគ្គបណ្ដុះបណ្ដាលកសិករចំនួន ១២លើក មានកសិករចូលរួមចំនួន ៤០០នាក់ (នារី២៥៩នាក់)

- ផ្ដល់បទសម្ភាសន៍តាមទូរស័ព្ទដល់កាសែត កោះសន្តិភាព កម្ពុជាថ្មី ភ្នំពេញប៉ុស្តិ៍ ខ្មែរថៃម Business Cambodia លើប្រធានបទ ១)គម្រោងស្រាវជ្រាវស្ដីពីពិពិធកម្មប្រជាករស្រូវសែនក្រអូប ២)គម្រោងស្រាវជ្រាវស្ដីពីបសិដ្ឋកម្មពូជស្រូវក្រអូបមិនប្រកាន់រដូវ ៣)គម្រោងស្រាវជ្រាវស្ដីពីការពង្រីកវិសាលភាពដាំដុះពូជស្រូវផ្កាមាលតីដែលធន់ទ្រាំការប្រែប្រួលអាកាសធាតុ

- រៀបចំបើកវគ្គបណ្ដុះបណ្ដាលកសិករចំនួន ២២លើកមានកសិករចូលរួមចំនួន ៨០០នាក់ (ស្រី៤៤០នាក់) និងធ្វើទិវាស្រែបង្ហាញចំនួន ២លើក មានកសិករចូលរួម៥០នាក់ (ស្រី៣៨នាក់)។ ចែកពូជស្រូវក្នុងចំណាត់ថ្នាក់ពូជស្រូវសុទ្ធល្អសរុបចំនួន ៧០០គ.ក្រ ដល់កសិករនៅខេត្តសៀមរាប និងខេត្តព្រៃវែងសម្រាប់ការងារបង្កបង្កើនផលស្រូវឆ្នាំ២០២១ ជាពូជស្រូវធានាបាននូវភាពសុទ្ធ និងទិន្នផលខ្ពស់

- មានអ្នកបើកស្រាវជ្រាវរកព័ត៌មានបច្ចេកទេសកសិកម្មរបស់វិទ្យាស្ថានសរុបចំនួន ៩០៧ ០៥៦នាក់ ហើយគិតជាមធ្យមមានប្រមាណ ៣ ៧៣២នាក់/ថ្ងៃ។

### ១៧.២ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតកំពុងសិក្សាក្នុងឆ្នាំសិក្សា២០២០-២០២១ សរុបចំនួន ៣ ២៥៦នាក់ ចែកចេញជា១០ មហាវិទ្យាល័យ គឺ៖ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រជលផល កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមហាវិទ្យាល័យវិទ្យាសាស្ត្រកៅស៊ូ និងសាលាក្រោយឧត្តម

- សាលាក្រោយឧត្តមបានរៀបចំពិធីជួបសំណេះសំណាល និងចែករំលែកបទពិសោធន៍ការប្រើប្រាស់កម្មវិធី Mendeley Reference Manager ក្នុងការគ្រប់គ្រងឯកសារយោងសម្រាប់ការសរសេរអត្ថបទវិទ្យាសាស្ត្រ ឬនិក្ខេបបទបញ្ចប់ការសិក្សា ដល់និស្សិតថ្នាក់ក្រោយបរិញ្ញា

- ចូលរួមខួបលើកទី១៣០ របស់សាកលវិទ្យាល័យតូក្យូ ប្រទេសជប៉ុន Tokyo University of Agriculture

- ចូលរួមប្រជុំជាមួយដៃគូសហប្រតិបត្តការ ISU-OSU-RUA លើ OIE Day1 Platform

- ចូលរួមប្រជុំក្រុមការងារបច្ចេកទេសដើម្បីពិនិត្យមើលបញ្ជីគ្រឿងបន្លាស់ម៉ាស៊ីនកសិកម្មជាមួយក្រុមហ៊ុន Angkor Green និងក្រុមហ៊ុន Yanmar

- ចូលរួម Life Mechatronics Symposium រៀបចំដោយ The Institute of Electrical Engineers of Japan និង ITC

- ចូលរួម Webinar (ជាវ៉ាគ្គីន) ស្តីពី 'Sustainable Hydropower Network Webinar (SHAASAN) in Asia

- ចូលរួមវេទិកាជួបពិភាក្សាតាមអនឡាញស្ដីពីកម្មវិធីថ្នាក់ពីរភាសា (បារាំង-ខ្មែរ) នៅកម្ពុជា៖ បញ្ហាប្រឈម និងចក្ខុវិស័យដែលមានអ្នកចូលរួមចំនួន ២១០នាក់ មកពី ក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងសាកលវិទ្យាល័យ និងវិទ្យាល័យមួយចំនួនប្រើប្រាស់ភាសាបារាំង

- ជួបពិភាក្សា ជាមួយនាយិកា និងក្រុមការងារនៃ Impact Hub ភ្នំពេញ គោលបំណងនៃកិច្ចប្រជុំ ដើម្បីរួមបញ្ចូលកម្មវិធីបង្រៀនមេរៀន គ្រូបង្រៀនរួមគ្នា និងឧបករណ៍សិក្សាតាមអនឡាញរបស់ Impact Hub ភ្នំពេញ ជាមួយកម្មវិធីសិក្សាមានស្រាប់ក្នុងដេប៉ាតឺម៉ង់កសិ-ធុរកិច្ច នៃមហាវិទ្យាល័យ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- រៀបចំកិច្ចប្រជុំពិភាក្សាស្តីពី "ការបង្កើតឯកសារកម្មសិទ្ធបញ្ញា (Interlectual property right policy and frame work development) ដែលរៀបចំដោយ ផ្នែកស្រាវជ្រាវ និងផ្សព្វផ្សាយ

- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសក្រោយប្រមូលផលស្វាយចន្ទី គាំទ្រថវិកាដោយគម្រោង HARVEST 2

- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការវិភាគសេរីស៊ីនពីសំបុកដង្កូវនាង ក្នុងគម្រោងដែលឧបត្ថម្ភដោយJICA ជារៀងរាល់ថ្ងៃអង្គារ តាមរយៈប្រព័ន្ធអនឡាញ នៃកម្មវិធី Google meet ។

### ១៧.៣ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០២០-២០២១ សរុបចំនួន ១ ១២៧នាក់ (ស្រី៤៦៤នាក់) លើជំនាញៈ កសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិស្វកម្មកសិកម្ម ព្រៃឈើ ជលផល សាកវប្បកម្ម សុរិយោដីនិងការគ្រប់គ្រងដី ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម មីក្រូហិរញ្ញវត្ថុ កែច្នៃអាហារ កុំព្យូទ័រ សេដ្ឋកិច្ចនយោបាយនិងស្បៀង និងភាសាអង់គ្លេស

- បាននិងកំពុងជំរុញការងារស្រាវជ្រាវ និងសហប្រតិបត្តិការជាមួយដៃគូសម្រាប់ការបណ្តុះបណ្តាលគម្រោងសិក្សាស្រាវជ្រាវសំខាន់ៗដែលកំពុងដំណើរការ គឺការពិសោធចិញ្ចឹមគោទឹកដោះ ការពិសោធចិញ្ចឹមបង្កា ការពិសោធបង្កាត់ពូជមាន់ ការសិក្សាពិសោធថ្នាំបណ្តេញសត្វល្អិត ការពិសោធចិញ្ចឹមពពែនៅតំបន់ភ្នំ ការសិក្សាស្រាវជ្រាវបង្កាត់កេសរកូល ការពិសោធដំណាំព្រីង ការសិក្សាពិសោធផលិតម្សៅឫស្សី ការបណ្តុះជាលិការុក្ខជាតិ ការពិសោធចិញ្ចឹមកង្កែប សាងសង់កសិដ្ឋានវារីសត្វ-រុក្ខជាតិ ការពិសោធចិញ្ចឹមត្រីបបែលនិងត្រីលម្អផ្សេងៗ ការសិក្សាផលិតកម្ម និងច្រវាក់តម្លៃស្វាយចន្ទី

- ដំណើរការបង្រៀននិស្សិតគ្រប់ជំនាញតាមប្រព័ន្ធ Online ប្រកបដោយភាពរលូន

- រៀបចំកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់៥ជំនាញចប់ជាស្ថាពរ និងបានការគាំទ្រពីក្រសួងអណាព្យាបាល និងបានស្នើសុំការគាំទ្រពីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីប្រើប្រាស់ជាផ្លូវការ

- ចុះសិក្សាអំពីវត្ថុធាតុដើមសម្រាប់ធ្វើថ្នាំពុលកសិកម្មធម្មជាតិចំនួន១០លើក

- ប្រជុំក្រុមប្រឹក្សាភិបាលវិទ្យាស្ថានជាតិសម្រាប់អាណត្តិឆ្នាំ២០២០-២០២៣ ចំនួន៣លើក

- សាងសង់អគារមួយសម្រាប់ចិញ្ចឹមត្រីនៅផ្នែកខាងក្រោម ចិញ្ចឹមមាន់នៅផ្នែកខាងលើ និងកំពុងដំណើរការចិញ្ចឹមត្រី និងបង្កាត់ពូជមាន់ពិសោធន៍នៅក្នុងវិទ្យាស្ថានជាតិ។

### ១៧.៤ វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០២០-២០២១ សរុបចំនួន ៦១០នាក់ (ស្រី២៧៤នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម ក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- ត្រៀមការពារសារណាបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្មផ្នែកអាហារូបករណ៍ជំនាន់ទី១៥ និងផ្នែកបណ្តុះបណ្តាលបន្តជំនាន់ទី១៨

- ពិសោធន៍លើជីសរីរាង្គពីការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់

- ពិសោធន៍តាមដានការបំផ្លាញរបស់កត្តាចង្រៃលើដំណាំខាត់ណាផ្កា

- ពិសោធន៍ដំណាំលើទឹកដោយប្រើប្រាស់ប្រភពទឹកពីអាងចិញ្ចឹមត្រីនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- ធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហមនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- ធ្វើពិសោធន៍លើការចិញ្ចឹមបង្កងពូជអូស្ត្រាលីចំនួន ១៦៥គូ និង៥៦០កូន

- ធ្វើពិសោធន៍លើការចិញ្ចឹមសាកល្បងពូជកន្ធាយក្នុងស្រុកចំនួន ៤៥០ក្បាល

- ធ្វើការសាកល្បងចម្រាញ់ប្រេងស្វាយចន្ទីសម្រាប់ផលិតជាគ្រឿងក្រអូប

- ចូលរួមបណ្ដុះបណ្ដាលកសិករជាមួយដៃគូរបស់ក្រុមហ៊ុន និងធ្វើការស្រាវជ្រាវរួមគ្នាអំពីការកែច្នៃកសិផលលើដំណាំស្វាយចន្ទី ល្ហុង ល្ពៅ ក្រូចថ្លុង ស្លឹកគ្រៃ និងម្រេច។

**១៧.៥ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

- ត្រួតពិនិត្យទូទៅការការពារ និងថែទាំចម្ការពិសោធន៍ក្លូនកូនកៅស៊ូស៊ីដលីង និងច្បារបង្កាត់ពូជ
- ស្រង់ទិន្នន័យ បញ្ចូល និងវិភាគទិន្នន័យចម្ការពិសោធន៍ក្លូន (ទិន្នផលជ័រ) សរុបចំនួន ១២ចម្ការពិសោធន៍
- រៀបចំទីតាំងនិងស្រង់ទិន្នន័យជំងឺ Oidium នៃចម្ការពិសោធន៍ក្លូនក្នុងស្ថានីយបានចំនួន១០ចម្ការ
- ត្រួតពិនិត្យការថែទាំកូនកៅស៊ូដែលបំបៅរួចដើម្បីដាំពង្រីកនៅក្នុងច្បារពូជ
- ស្រង់ទិន្នន័យមាឌឈើតាមក្លូននីមួយៗបានចំនួន ២ចម្ការពិសោធន៍
- ចុះត្រួតពិនិត្យចម្ការបង្ហាញលើការអនុវត្តកសិកម្មល្អលើការយកផលទឹកជ័រ និងចម្ការកែលម្អបច្ចេកទេសលើការយកផលទឹកជ័ររបស់កៅស៊ូគ្រួសារនៅខេត្តមណ្ឌលគិរី
- ត្រួតពិនិត្យការចៀរជ័រ ការសាប្រមូលផលទឹកជ័រ ស្រង់ទិន្នន័យជ័រកៅស៊ូទិន្នន័យដើមចៀរ និងជំងឺស្ងួតមុខចៀរតាមពិធីសាពិសោធន៍គ្រប់ចម្ការពិសោធន៍
- លាបថ្នាំសម្គាល់បច្ច័យនីមួយៗ និងវាស់ទំហំដើមតាមដានការលូតលាស់គ្រប់ចម្ការពិសោធន៍ និងរៀបចំដាក់ផ្ទាំងឈ្មោះចម្ការពិសោធន៍
- បណ្ដុះបណ្ដាលមន្ត្រីក្នុងការរៀបចំលាយសូលុយស្យុងវត្ថុធាតុគីមី និងវិភាគរកស្តង់ដារសរីរទឹកជ័រ (LD) លើប៉ារ៉ាម៉ែត្រ Inorganic Phosphorus (Pi), Sucrose (Suc) និង Thiol (R-SH)
- យកសំណាក និងវិភាគ LD ចម្ការពិសោធន៍ការប្ដូរផ្ទាំងចៀរបានចំនួន១ស្មើនឹង២០សំណាក
- អនុវត្តការបំបៅកូនកៅស៊ូនៅថ្នាលបណ្ដុះកូនកៅស៊ូឆ្នាំ ២០២០-២០២១
- ត្រួតពិនិត្យការកែច្នៃកៅស៊ូសន្លឹក(RSS)និងការជួសជុលឧបករណ៍កែច្នៃកៅស៊ូសន្លឹកនៅក្នុងស្ថានីយ
- វិភាគកៅស៊ូ RSS ចំនួន៥៤សំណាកដើម្បីវាយតម្លៃគុណភាពនៃការកែច្នៃតាមស្តង់ដា CSR។

## III-សេចក្ដីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាសម្រេចបាន ២ ៨២៦ ២៣៣ហ.ត ស្មើនឹង១០៨,៣២% នៃផែនការចំនួន ២ ៦០៩ ០៦៥ហ.ត និងការប្រមូលផលស្រូវស្រាលសម្រេចចំនួន ៥៦៤ ៧៩២ហ.ត ដោយទទួលបរិមាណផលសរុបចំនួន ២ ២៦៨ ៧១៧តោន លើសឆ្នាំមុនចំនួន ៦០៦ ៦៥៦តោន និងទទួលទិន្នផលគិតជាមធ្យម ៤,០១៧តោន/ហ.ត។ ក្រសួងបានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការស្ដារការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ការជំរុញឱ្យចុះត្រួតពិនិត្យ និងចាត់វិធានការជាក់ស្ដែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វឈើក្នុងតំបន់ផ្ទុះជំងឺ បទល្មើសព្រៃឈើ និងបទល្មើសជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រងការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងបានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្ដាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្ដុះបណ្ដាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រឱ្យសម្រេចបាននូវលទ្ធផលល្អប្រសើរតាមផ្នែកនីមួយៗស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ

- បន្តរៀបចំកែលម្អលំដាប់ផលកសិកម្មរដូវវស្សាឆ្នាំ២០២១

- បន្តធ្វើការជំរុញផលិតកម្មស្បៀងសម្រាប់ឆ្លើយតបទៅនឹងហានិភ័យនៃការឆ្លងរាលដាលជំងឺកូវីដ-១៩

- បន្តជំរុញការនាំចេញផលិតផលកសិកម្មទៅកាន់ទីផ្សារអន្តរជាតិពិសេសប្រទេសចិន

- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណ និងគុណភាពតាមផែនការកំណត់ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្ដែង

- បន្តជំរុញ និងបណ្ដុះបណ្ដាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងបន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាន និងស្ថានីយ

- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់នឹងជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្ម

- បន្តអង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡត៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្ដាខេត្តដែលមានសក្ដានុពលកៅស៊ូ។

### ២ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗ ចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្ដែង

- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្ដារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- បន្តពង្រឹង និងផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមសត្វដល់កសិករ

- ចុះពិនិត្យអនាម័យសត្តឃាតដ្ឋាន ផ្សព្វផ្សាយអំពីលក្ខណៈ និងសញ្ញាណជំងឺជ្រូកគ្រុនចៀកខៀវ ប៉េស្ត ជំងឺផ្ដាសាយបក្សី ជំងឺអាសន្នរោគ ជំងឺឆ្លង(ជំងឺចុងអង្កាំ របេងជ្រូក គោ) បន្តតាមដានស្ថានភាពជំងឺស៊ូណូស និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត

- ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យ កន្លែងផ្ទុះជំងឺ និងកន្លែងដែលរាលដាលជំងឺផ្ដាសាយបក្សី (H5N1) និងជំងឺ A(H1N1)

- ជំរុញការអនុវត្តកម្មវិធីផ្សព្វផ្សាយលើកកម្ពស់ការអប់រំយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការប្រើប្រាស់ចំណីសត្វ និងបសុឱសថដល់អាជីវករ និងអ្នកប្រើប្រាស់

- បន្តចុះវាយតម្លៃកសិដ្ឋានចិញ្ចឹមសត្វស្របតាមបច្ចេកទេស និងគោលការណ៍អនុវត្តការចិញ្ចឹមសត្វល្អ តាមខេត្តគោលដៅ

- បន្តរៀបចំឯកសារស្ដីពីអត្ថប្រយោជន៍នៃការគ្រប់គ្រងកាកសំណល់សត្វ។

### ៣ ផ្នែកព្រៃឈើ

- ខិតខំបន្តត្រួតពិនិត្យ តាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រ សិប្បកម្មកែច្នៃ និងអាជីវកម្មឈើឱ្យបានហ្មត់ចត់ ព្រមទាំងចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតដើម្បីលុបបំបាត់សកម្មភាពដឹកជញ្ជូនឈើខុសច្បាប់ឱ្យមានប្រសិទ្ធភាពខ្ពស់

- បន្តពង្រឹង និងពង្រីកសហគមន៍ព្រៃឈើចូលរួមគ្រប់គ្រងថែរក្សាធនធានព្រៃឈើ តាមដានត្រួតពិនិត្យ ការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ឱ្យបានល្អ ព្រមទាំងបណ្ដុះផ្នត់គំនិតបង្កើតមុខរបរថ្មីៗបន្ថែមទៀត ដើម្បីបង្កើនចំណូលតាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម ការចិញ្ចឹមសត្វ សំដៅកាត់បន្ថយការពឹងអាស្រ័យលើផល និងអនុផលព្រៃឈើ ជាពិសេសខិតខំ

ជំរុញការផ្សព្វផ្សាយ អប់រំ បណ្តុះបណ្តាល បំពាក់បំប៉នដល់សហគមន៍មូលដ្ឋានយល់ដឹងពីផលប្រយោជន៍ព្រៃឈើ

- បន្តផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទប្បញ្ញត្តិ បទបញ្ជា លិខិតបទដ្ឋានគតិយុត្ត ជាពិសេសសេចក្តីជូនដំណឹងលេខ១៣៤៨ សជណ.កជ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីឱ្យបានជ្រួតជ្រាបដល់មូលដ្ឋាន ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង រាជធានី-ខេត្តទូទាំងប្រទេស ព្រមទាំងមានចំណាត់ការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ និងមានប្រសិទ្ធភាពខ្ពស់ពាក់ព័ន្ធនឹងការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីធ្វើកម្មសិទ្ធិ

- បន្តជំរុញការដាំដុះស្តារព្រៃឈើឡើងវិញដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋ។

## ៤ ផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលឱ្យបានតឹងរ៉ឹងបំផុត

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"។

## ៥ ផ្នែកពាក់ព័ន្ធផ្សេងៗ

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់ជី-ថ្នាំកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់ជី-ថ្នាំកសិកម្ម ដើម្បីសុខភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្តែង រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា អភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាឱ្យមានផលិតភាពខ្ពស់ដោយគិតគូរទៅលើការប្រែប្រួលអាកាសធាតុ និងស្តង់ដារ។

ថ្ងៃ ច័ន្ទ ១២កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

# សកម្មភាពថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ





ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុញ្ញាតឱ្យលោក Alexandre Huynh នាយកអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO) ប្រចាំព្រះរាជាណាចក្រកម្ពុជា និងសហការីចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ





ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសហការី អញ្ជើញចុះពិនិត្យលើខ្សែច្រវាក់ផលិតកម្ម និងការកែច្នៃម្រុំ និងខ្ញីខ្មៅសម្រាប់ប្រើប្រាស់ជាអាហារបំប៉នសុខភាពក្នុងកសិដ្ឋានក្រុមហ៊ុន Lexmin ដែលមានទីតាំងស្ថិតក្នុងភូមិអភិវឌ្ឍន៍យោធិនពិការកោះស្លា (តំបន់អភិវឌ្ឍន៍តេជោសែន) ស្រុកឈូក ខេត្តកំពត





ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អមដំណើរដោយឯកឧត្តម ពុំ សុថា ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល និងមន្ត្រីជំនាញមួយចំនួនទៀត អញ្ជើញចុះពិនិត្យកសិដ្ឋានបង្កងទូលទន្លេជុំ ដែលមានទីតាំងស្ថិតនៅក្នុងភូមិថ្មល់ជាតិ ឃុំបារាយណ៍ ស្រុកបារាយណ៍ ខេត្តកំពង់ធំ






ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ  អមដោយឯកឧត្តមរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការក្រសួង និងឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលជាប្រធានរដ្ឋបាលព្រៃឈើ អញ្ជើញចូលរួមកិច្ចប្រជុំតាមរយៈប្រព័ន្ធអនឡាញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្រោមប្រធានបទ ពង្រឹងកិច្ចសហប្រតិបត្តិការរវាងក្រសួងទាំងពីរលើការគ្រប់គ្រងដីរដ្ឋ






ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានប្តូរវេនរដ្ឋមន្ត្រីកសិកម្ម និងព្រៃឈើអាស៊ាន បានធ្វើជាសហប្រធានជាមួយ ឯកឧត្តម Wang Lingjun អនុរដ្ឋមន្ត្រីអគ្គរដ្ឋបាលគយ(GACC) នៃសាធារណៈរដ្ឋប្រជាមានិតចិន ដើម្បីដឹកនាំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន-ចិន លើកទី៧





ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីភាពក្នុងពិធីប្រគល់-ទទួលយានយន្តបំពាក់ទូរត្រជាក់ យានយន្តដឹកផលិតផលកសិកម្ម និងមធ្យោបាយដឹកជញ្ជូនរ៉ឺម៉កកង់បី ជូនដល់សហគមន៍កសិកម្ម ក្នុងក្របខ័ណ្ឌគម្រោងស្តីពី "ការលើកកម្ពស់ផលិតផលមាន់ស្រែខ្មែរ សម្រាប់មោទនភាពជាតិខ្មែរ"




ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលជលផលបានបន្តដំណើរមកពិនិត្យរោងសិប្បកម្មកែច្នៃផលត្រីស្រស់របស់កសិដ្ឋានដែលមានទីតាំងនៅខណ្ឌសែនសុខ រាជធានីភ្នំពេញ




ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពិនិត្យផលិតកម្មបន្លែ (hydroponic) របស់កសិករ នៅភូមិឈើល្វីង ឃុំតាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ




ឯកឧត្តម **នុត ច័ន្ទសុខា** រដ្ឋលេខាធិការប្រចាំការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអញ្ជើញចុះសួរសុខទុក្ខ និងពិនិត្យកសិដ្ឋានចិញ្ចឹមគោយកកូន និងយកសាច់ជាលក្ខណៈគ្រួសាររបស់កសិករ ហួត លាង នៅភូមិតារាម ឃុំចុងជាច ស្រុកតំបែរ ខេត្តត្បូងឃ្មុំ



ឯកឧត្តម **ហ៊ួត ម៉ុនណារី** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញចូលរួមជាអធិបតីភាព ក្នុងពិធីចែកពូជស្រូវជូនប្រជាកសិករចំនួន៦៦៣គ្រួសារ នៅក្នុងភូមិសាស្រ្តខណ្ឌដង្កោ រាជធានីភ្នំពេញ



ឯកឧត្តម **ហាស់ សារ៉េត** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជួបសំណេះសំណាល និងចែកកូនត្រីអណ្ដែង និងសម្ភារចិញ្ចឹមត្រីមួយចំនួនទៀតជូនកសិករក្នុងអំឡុងពេលនៃការឆ្លងរាលដាលជំងឺកូវីដ-១៩ នៅខេត្តស្វាយរៀង



ឯកឧត្តម **ឈី លន់** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញចុះពិនិត្យចម្ការល្ពៅរបស់ប្រជាកសិករ នៅខេត្តត្បូងឃ្មុំ



ឯកឧត្តម **ហ៊ាន វណ្ណហាន** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញចុះពិនិត្យ និងសួរសុខទុក្ខដល់កសិករដាំបន្លែសុវត្ថិភាព និងការចិញ្ចឹមត្រី នៅភូមិ៤ ឃុំត្រពាំងច្រេស ស្រុកកូនមុំ ខេត្តរតនគិរី



ឯកឧត្តម **គឹម សុន** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសហការី អញ្ជើញចុះពិនិត្យការដាំបន្លែផ្ទះសំណាញ់របស់ប្រជាកសិករ នៅស្រុកចន្ទ្រា ខេត្តស្វាយរៀង




ឯកឧត្តម **ចាន់ សារុទ្ធ** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំស្ដីពី "ការចាប់ផ្ដើមគម្រោងការគាំទ្រមជ្ឈមណ្ឌលកសិកម្ម នៅខេត្តក្រចេះ"



# កង្វល់ម្រឹគព្រៃ

*បទពាក្យប្រាំពីរ*

សូរិយាចែងចាំងពាសភស្តុធា
បក្សីម្រឹគាស្រែកខ្សៀវខ្សារ
សប្បាយអឺងកងលើបុព្វតា
ក្នុងព្រៃព្រឹក្សាគ្មានកង្វល់។

សហាសវត្សទំនើបថ្មី
បក្សាម្រឹគព្រៃចលាចល
ល្អួនចតុប្បាទជួបអំពល់
ឧរង្គស្គាល់យល់តែកលិយុគ។

សត្វព្រៃតូចធំគ្រប់សន្តាន
ជួបភ័យរំខានកើតក្តីទុក្ខ
គឺមនុស្សអប្រិយចូលអុកឡុក
បំផ្លាញក្តីសុខភាពសប្បាយ។

បរបាញ់ឆក់ទាក់កាប់សម្លាប់
រុករានចងចាប់បង្ខាំងវាយ
ទ្រូងចុកពើតផ្សាស្មើរបែកធ្លាយ
វាចារាយមាយចង់តែស្លាប់។

ចាបចៀបចាបពូកចាបព្រៃវែង
លលកប្រជែងពោលរ៉ាយរ៉ាប់
រៀបរាប់ប្រាប់គ្នាជាទម្លាប់
ពីរឿងក្តីស្លាប់ទុក្ខទារុណ។

មនុស្សយកពួកគេទៅធ្វើម្ហូប
ចាបមាសចាកលោករងទុក្ខធ្ងន់
រៀបចំសម្លាប់គេបោចមុន
ឈឺផ្សាពេកពន់បោចទាំងរស់។

*(សូមរង់ចាំអានបន្តនៅទស្សនាវដ្តីកសិកម្មលេខ៨០)*

*ដោយលោក៖ អ៊ូ វណ្ណារ៉េត រដ្ឋបាលព្រៃឈើ*





